**អត្ថបទស្រាវជ្រាវ**

វ៉ុល២, លេខ១១, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

# អ្វីដែលជំរុញឲ្យគោលនយោបាយនៅធនាគារពិភពលោកបរាជ័យ?

## *ការមើលឃើញពីខាងក្នុងអំពីគំរូជំនួយថ្មីដល់ឧត្តមសិក្សា៖ បរិបទ ការបន្ទោស និងភាពមិនចេះខុស*[1]

អត្ថបទស្រាវជ្រាវជាភាសាអង់គ្លេសដោយបណ្ឌិត ជេរីមី រ៉ាប់ផ្លៃ* និងបណ្ឌិត អ៊ុន លាង **
បកប្រែ និងកែសម្រួលដោយ[2] បណ្ឌិត អ៊ុន លាង

**មូលន័យសង្ខេប**

អត្ថបទនេះវិភាគអំពីបទអន្តរាគមន៍ថ្មីៗរបស់ធនាគារពិភពលោក ដែលធ្វើឡើងក្នុងគោលបំណងលើកកម្ពស់គុណភាពឧត្តមសិក្សា និងសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សានៃប្រទេសដែលមានប្រាក់ចំណូលទាប។ ចំណុចចាប់ផ្តើមនៃបទពិសោធន៍ជាក់ស្តែងរបស់យើង គឺការវិភាគប្រកបដោយការរិះគន់ទៅលើគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ (២០១០-២០១៥) ដែលធនាគារពិភពលោកបានដាក់ឲ្យអនុវត្តនៅប្រទេសកម្ពុជា ដែលជាគម្រោងមួយចម្លងទាំងស្រុងចេញពីមូលនិធិផ្តួចផ្តើមសិក្សាជាន់ខ្ពស់នៅប្រទេសបង់ក្លាដែស។ ចេញពីទស្សនវិស័យពីខាងក្នុងដែលកម្រមាន យើងអះអាងថា គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ នៅប្រទេសកម្ពុជាចុងក្រោយបំផុត គឺបរាជ័យ ពីព្រោះធនាគារពិភពលោក យល់ច្រលំទាំងស្រុងអំពីបរិបទនៅប្រទេសកម្ពុជា។ យើងប្រើប្រាស់ករណីនេះដើម្បីវិភាគពីកំហុសដែលធ្ងន់ធ្ងរជាងនេះ នោះគឺអំពីរបៀបដែលធនាគារពិភពលោក *'គិត'* និងរំលេចឲ្យឃើញថា តើស្ថាប័នអភិវឌ្ឍន៍ដ៏មានឥទ្ធិពលជាងគេបំផុតក្នុងពិភពលោក ចាត់ចែងរក្សាជំនឿក្នុងភាពមិនចេះខុសរបស់ខ្លួនដោយរបៀបណា បើទោះបីជាជួបប្រទះភាពបរាជ័យក៏ដោយ?

[1] អត្ថបទជាភាសាអង់គ្លេស Rappleye, Jeremy & Leang, Un (2018). "What Drives Failed Policy at the World Bank? An inside account of new aid modalities to higher education research, context, blame, and infallibility, Comparative Education", *Vol. 54, issue 2, 250- 274*។ អត្ថបទនេះទទួលបានសិទ្ធិបកប្រែពី Taylor & Francis Group, Ref: AF/CCED/P20/0512។

[2] ដើម្បីឲ្យការបកប្រែនេះមានភាពងាយស្រួលយល់ក្នុងចំណោមអ្នកអានទូទៅ អ្នកដែលមិនធ្លាប់ធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកមិនធ្លាប់អានអក្សរសិល្ប៍វិជ្ជាជាន់ខ្ពស់អំពីការរិះគន់លើដំណើរការអភិវឌ្ឍន៍នៅជុំវិញពិភពលោក និងដើម្បីបន្តអង្កេតលើការប្រែប្រួលដែលកើតមានឡើងចាប់តាំងពីការបញ្ចប់គម្រោងលើកទី១ ជាពិសេសបទពិសោធន៍ថ្មីៗដែលកំពុងកើតមានឡើងបន្ទាប់ពីមានការដាក់ឲ្យអនុវត្តគម្រោងលើកទី២ របស់ធនាគារពិភពលោក ហើយនិងដើម្បីស្វែងយល់ និងប្រៀបធៀប ក៏ដូចជាបញ្ជាក់ឡើងវិញពីទឡ្ហីករណ៍របស់អ្នកនិពន្ធ អ្នកបកប្រែ និងកែសម្រួល (ជាអ្នកនិពន្ធទី២នៃអត្ថបទដើម) នឹងបន្ថែមការពន្យល់លម្អិតខ្លះៗនៅក្នុងកំណត់សម្គាល់នៅជើងទំព័រនៃអត្ថបទនេះ។ កំណត់សម្គាល់បន្ថែមទាំងនេះមិនមាននៅក្នុងអត្ថបទជាភាសាអង់គ្លេសទេ។

***លោកបណ្ឌិត ជេរីមី រ៉ាប់ផ្លៃ** គឺជាសាស្ត្រាចារ្យរងនៃសាកលវិទ្យាល័យក្យូតូ ប្រទេសជប៉ុន។
****លោកបណ្ឌិត អ៊ុន លាង** គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

**ពាក្យគន្លឹះ៖** *ធនាគារពិភពលោក[3] សេដ្ឋកិច្ចពុទ្ធិសកល[4] ការអភិវឌ្ឍដែលបរាជ័យ[5] ការផ្ទេរគោលនយោបាយ[6] បរិបទ[7] និយាមវិទ្យាសាស្ត្រដាច់ខាត[8] ជំនឿ[9]*

## ❖ សេចក្តីផ្តើម

នៅក្នុងខែកក្កដា ឆ្នាំ២០១០ ធនាគារពិភពលោក (សមាគមអភិវឌ្ឍន៍អន្តរជាតិ) បានពង្រីកកម្ចីវិនិយោគរបស់ខ្លួនជាលើកដំបូងមកកាន់ប្រទេសកម្ពុជា ផ្តោតជាពិសេសលើអនុវិស័យអប់រំឧត្តមសិក្សា។ គម្រោងនេះ ត្រូវបានចាត់ថ្នាក់ជាគម្រោងមួយក្នុងចំណោមគម្រោងប្រភេទថ្មីជាងគេបំផុត នៃគម្រោងកម្ចីការអភិវឌ្ឍធនធានមនុស្សរបស់ធនាគារពិភពលោក ក្រោមប្រធានបទ *ការអប់រំដើម្បីសេដ្ឋកិច្ចពុទ្ធិ* ហើយគម្រោងដែលមានរយៈពេល ៥ឆ្នាំ និងទឹកប្រាក់ចំនួន ២៣លានដុល្លារសហរដ្ឋអាមេរិក[10] នៅក្នុងប្រទេសកម្ពុជានេះ មានឈ្មោះថា "គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា" រួមមានបួនផ្នែក។ ក្នុងនោះ ផ្នែកទី១៖ ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំឧត្តមសិក្សា ផ្នែកទី២៖ ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ប្រកបដោយការប្រកួតប្រជែង ផ្នែកទី៣៖ អាហារូបករណ៍សម្រាប់និស្សិតងាយរងគ្រោះ និងផ្នែកទី៤៖ ការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង។ ផ្នែកទី១ ទី៣ និងទី៤ គ្រាន់តែជាការតំណាងឲ្យការពង្រីកឲ្យ "ខ្ពស់ទៅលើ" នៃបទអន្តរាគមន៍របស់ធនាគារពិភពលោក ដែលធ្លាប់បានធ្វើតាំងពីយូរយារណាស់មកហើយ ក្នុងកម្រិតអប់រំបឋមសិក្សា និងកម្រិតអប់រំមធ្យមសិក្សា ដូចជាការរៀបចំសិក្ខាសាលាទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីរបស់ក្រសួង ការចេញថវិកាបង់ថ្លៃសិក្សាសម្រាប់សិស្សក្រីក្រ ការផ្តល់អាហារូបករណ៍ឲ្យនិស្សិតជួបការលំបាក និស្សិតនារី និងនិស្សិតជនជាតិដើមភាគតិច ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ក្រសួង និងការតាមដានត្រួតពិនិត្យដែលផ្តោតលើលទ្ធផល។ល។

ប៉ុន្តែ ផ្នែកទី២ គឺមានលក្ខណៈពិសេស ក្នុងន័យថា គម្រោងបែបនេះមានតិចតួចណាស់ពីមុនមក ក្នុងអនុវិស័យអប់រំផ្សេងទៀត និងក្នុងបរិបទដែលពឹងផ្អែកលើជំនួយជាសាកលផ្សេងទៀត។ ផ្នែកទី២ នឹងផ្តល់ហិរញ្ញប្បទានស្រាវជ្រាវ រហូតដល់ ២០០.០០០ ដុល្លារ សហរដ្ឋអាមេរិក ដោយផ្ទាល់ទៅកាន់សាកលវិទ្យាល័យនៅកម្ពុជា (ដែលធនាគារពិភពលោកហៅថា គ្រឹះស្ថានឧត្តមសិក្សា) ដើម្បីលើកកម្ពស់គុណភាពស្រាវជ្រាវ និងគុណភាពរៀន និងបង្រៀន។ មូលនិធិទាំងនេះ ហៅថា *ហិរញ្ញប្បទានការស្រាវជ្រាវ និងនវានុវត្តន៍* ដែលត្រូវបានបែងចែកតាមរយៈគោលការណ៍ប្រកួតប្រជែង និងមានគោលបំណងពង្រឹងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ក្នុងការស្វែងរកដំណោះ

---

[3] ធនាគារពិភពលោក គឺជាស្ថាប័នរូបិយវត្ថុអន្តរជាតិ ដែលផ្តល់ជំនួយឥតសំណង និងកម្ចីទៅឲ្យរដ្ឋាភិបាលប្រទេសក្រីក្រសម្រាប់គោលបំណងអនុវត្តគម្រោងបង្កើនមូលធន។

[4] សេដ្ឋកិច្ចពុទ្ធិសកល សំដៅលើកំណើនសេដ្ឋកិច្ចដែលពឹងផ្អែកលើបរិមាណ គុណភាព និងការទទួលបានព័ត៌មានដែលមាននៅក្នុងពិភពលោក ជាជាងពឹងផ្អែកលើមធ្យោបាយផលិតកម្មជាប្រពៃណី។

[5] ការអភិវឌ្ឍដែលបរាជ័យ សំដៅលើការអនុវត្តគម្រោងអភិវឌ្ឍន៍ ប៉ុន្តែមិនសម្រេចបានគោលបំណងរបស់គម្រោងដែលបានកំណត់ទុក ឬមិនអាចបង្កើតបានជាគ្រឹះសម្រាប់ការអភិវឌ្ឍក្នុងពេលអនាគត។

[6] ការផ្ទេរគោលនយោបាយ គឺជាគោលនយោបាយដែលបង្កើតឡើងនៅកន្លែងណាមួយ ក្នុងពេលណាមួយ រួចត្រូវបានចម្លង ឬនាំចូលមកកាន់កន្លែងមួយផ្សេងទៀត ក្នុងពេលតែមួយ ឬក្នុងពេលមួយផ្សេងទៀតដើម្បីអនុវត្ត។

[7] បរិបទ សំដៅលើកាលៈទេសៈដែលបង្កើតបានជាព្រឹត្តិការណ៍ ការអះអាង ឬគំនិត ហើយក្នុងន័យនេះវាអាចត្រូវបានយល់ដឹង។

[8] និយាមវិទ្យាសាស្ត្រដាច់ខាត (Nomothetic) សំដៅលើលទ្ធភាពបង្កើតគ្រឹះនៃទ្រឹស្តីបទវិទ្យាសាស្ត្រដែលអាចអនុវត្តបានក្នុងគ្រប់កាល និងលំហ។

[9] ជំនឿ ដំណើរចុះចិត្តស៊ប់ដោយយល់ថាជាការពិត។

[10] គម្រោងនេះមានលក្ខណៈជាកម្ចី៥០% និងជាជំនួយឥតសំណង៥០%។ នៅក្នុងសៀវភៅណែនាំការគ្រប់គ្រងហិរញ្ញវត្ថុ បានដាក់ចេញ និងបែងចែកយ៉ាងច្បាស់ថាប្រភេទសកម្មភាពណា ដែលអាចប្រើប្រាស់កញ្ចប់ថវិកាមួយណាបាន ដែលក្នុងនោះកម្ចីត្រូវបានឲ្យប្រើប្រាស់តែទៅលើ៖ ការបញ្ជូនបុគ្គលិកសិក្សាឲ្យទៅបន្តការសិក្សានៅក្រៅប្រទេស អាហាររូបករណ៍អាទិភាពពិសេស និងហិរញ្ញប្បទានលើការស្រាវជ្រាវ និងនវានុវត្តន៍។

ស្រាយចំពោះបញ្ហាការអភិវឌ្ឍនានានៅកម្រិតថ្នាក់មូលដ្ឋាន/ថ្នាក់ជាតិ ដោយភាពច្នៃប្រឌិត (World Bank 2010, 6)។

មូលដ្ឋានគ្រឹះដ៏ទូលំទូលាយ នៅពីក្រោយបទអន្តរាគមន៍នៃគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សានៅកម្ពុជា គឺជាការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ក្នុងការកំណត់អាទិភាពកម្ចីជាសាកលរបស់ធនាគារពិភពលោក។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៩០ ធនាគារពិភពលោកបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់ជាខ្លាំងទៅលើតួនាទីការអប់រំឧត្តមសិក្សា (World Bank 1994) ដែលជាអនុវិស័យមួយ ត្រូវបានបំភ្លេចចោលជាច្រើនទសវត្សរ៍មកហើយ ដោយសារតែឥទ្ធិពលនៃការវិភាគពីកម្រិតចំណេញ (ខាងសេដ្ឋកិច្ច) ដែលទទួលបានមកពីការវិនិយោគលើវិស័យអប់រំ ក្នុងចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៨០[11] និងគោលនយោបាយលំអៀងមកលើការពង្រីកការអប់រំមូលដ្ឋានក្នុងយុគសម័យក្រោយសេចក្តីថ្លែងការណ៍ទីក្រុងចមធៀន (Jomtiem) ក្នុងឆ្នាំ១៩៩០[12] (Heyneman 2003)។ ខណៈពេលដែលអ្នករិះគន់មួយចំនួនមើលឃើញថា របត់នៃការផ្លាស់ប្តូរនេះ តាមពិត គឺជាផ្នែកមួយនៃការប៉ុនប៉ងរបស់ធនាគារពិភពលោក ក្នុងការតែងតាំងខ្លួនឯងឡើងវិញជា *"ធនាគារពុទ្ធិសកល"* ហើយទទួលបានភាពស្របច្បាប់ឡើងវិញ បន្ទាប់ពីកម្ចីដ៏ច្រើនលើសលុបរបស់ខ្លួនផ្សារភ្ជាប់ជាមួយការរៀបចំរចនាសម្ព័ន្ធឡើងវិញ[13] ក្នុងឆ្នាំ១៩៨០ ទទួលបានការរិះគន់យ៉ាងខ្លាំង (Kamat 2012; សូមមើលផងដែរ Edwards and Storen 2016; Heyneman 2003) សម្រាប់អ្នកធ្វើការនៅខាងក្នុងធនាគារពិភពលោក គោលនយោបាយថ្មីនេះ គឺជាការឆ្លើយតបប្រកបដោយវិចារណញ្ញាណទៅនឹងរបត់ជាសារវន្ត ក្នុងការបង្កើតទ្រព្យសម្បត្តិ និងការលូតលាស់ក្នុងយុគ *"សេដ្ឋកិច្ចពុទ្ធិសាកលថ្មី"*។ នៅខាងក្នុងធនាគារពិភពលោក ការគិតថ្មីបែបនេះ ត្រូវបានរំលេចចេញយ៉ាងច្បាស់ជាមួយរបាយការណ៍ ក្រោមចំណងជើងថា *កសាងសង្គមពុទ្ធិ៖ ការប្រឈមថ្មីរបស់ការអប់រំឧត្តមសិក្សា បោះពុម្ពឆ្នាំ២០០២* (*Constructing Knowledge Societies: New Challenges for Tertiary Education*) ដែលបានអះអាងដូចខាងក្រោម៖

- វឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមអាចសម្រេចបាន គឺមានតែតាមរយៈឧត្តមភាព និងការអនុវត្តពុទ្ធិតែប៉ុណ្ណោះ។
- ការអប់រំឧត្តមសិក្សា គឺចាំបាច់សម្រាប់ការបង្កើត ការផ្សព្វផ្សាយ និងការអនុវត្តពុទ្ធិ និងសម្រាប់ការកសាងសមត្ថភាពបច្ចេកទេស និងសមត្ថភាពអាជីព។
- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសស្ថិតក្នុងអន្តរកាលកំពុងប្រឈមនឹងការផាត់ចេញឲ្យកាន់តែឆ្ងាយថែមទៀតពីសេដ្ឋកិច្ចពិភពលោក ដែលមានការប្រកួតប្រជែងកាន់តែខ្លាំងឡើងៗ ព្រោះតែប្រព័ន្ធអប់រំឧត្តមសិក្សារបស់ពួកគេ មិនទាន់ត្រូវបានរៀបចំឲ្យបានគ្រប់គ្រាន់ដើម្បីទាញផលចំណេញពីការបង្កើត និងការប្រើប្រាស់ពុទ្ធិ។
- រដ្ឋាភិបាលមានទំនួលខុសត្រូវ ក្នុងការបង្កើតក្របខណ្ឌដែលមានលក្ខណៈអំណោយផលក្នុងការជំរុញឲ្យគ្រឹះស្ថានឧត្តមសិក្សាឲ្យមានលក្ខណៈច្នៃប្រឌិត និងឆ្លើយតបឲ្យបានប្រសើរ ទៅនឹងតម្រូវការសេដ្ឋកិច្ច

[11] ការវិភាគនេះអះអាងថា ផលចំណេញសម្រាប់សង្គម គឺមានកម្រិតច្រើនជាងផលចំណេញសម្រាប់បុគ្គល នៅពេលមានការវិនិយោគលើការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ហើយការវិនិយោគលើការអប់រំឧត្តមសិក្សា នឹងនាំឲ្យមានផលចំណេញសម្រាប់បុគ្គលច្រើនជាងសម្រាប់សង្គម។

[12] ក្នុងឆ្នាំ១៩៩០ ប្រតិភូប្រហែល១.៥០០នាក់ មកពីប្រទេសចំនួន១៥៥ ដែលមានតំណាងមកពីខាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានជួបប្រជុំគ្នានៅក្នុងសន្និសីទពិភពលោក ស្តីអំពីការអប់រំសម្រាប់ទាំងអស់គ្នានៅទីក្រុងចមធៀន ប្រទេសថៃ។ សន្និសីទនេះ បានអំពាវនាវឲ្យប្រទេសទាំងអស់ផ្តល់ឱកាសឲ្យពលរដ្ឋខ្លួនទាំងអស់ទទួលបានការអប់រំជាមូលដ្ឋាន។ អ្នកចូលរួមនៅក្នុងសន្និសីទនេះ បានអនុម័តសេចក្តីថ្លែងការណ៍ និងក្របខណ្ឌសកម្មភាពជាសាកលអំពីការអប់រំសម្រាប់ទាំងអស់គ្នា៖ សម្រេចឲ្យបានតម្រូវការរៀនសូត្រជាមូលដ្ឋាន។

[13] ការរៀបចំរចនាសម្ព័ន្ធឡើងវិញ គឺជាយន្តការកំណែទម្រង់សេដ្ឋកិច្ចដែលប្រទេសមួយត្រូវតែទទួលយកធ្វើតាម ដើម្បីអាចធានាបាននូវកម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ និង/ឬធនាគារពិភពលោក។ ការរៀបចំរចនាសម្ព័ន្ធឡើងវិញនេះ គឺជាយន្តការគោលនយោបាយសេដ្ឋកិច្ច ដែលរួមមានការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល និងបើកចំហពាណិជ្ជកម្មដោយសេរីជាដើម។ល។

ពុទ្ធិសាកលដែលមានលក្ខណៈប្រកួតប្រជែងខ្លាំង... (World Bank 2002, xix)។

យុទ្ធវិធីថ្មីនេះជឿថា មិនថាប្រទេសមួយស្ថិតនៅទីណាក៏ដោយ មានធនធានធម្មជាតិអ្វីក៏ដោយ មានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបែបណាក៏ដោយ ទ្រព្យសម្បត្តិអាចត្រូវបានបង្កើតឡើងតាមរយៈការវិនិយោគលើសាកលវិទ្យាល័យ ដើម្បីធ្វើឲ្យសាកលវិទ្យាល័យមានលក្ខណៈ *'ថ្នៃប្រឌិតឡើង'* ហើយហេតុនេះ អាចមានលទ្ធភាពទាញយកប្រយោជន៍ពី *'ការបង្កើត និងការប្រើប្រាស់ពុទ្ធិ'*។ ការអភិវឌ្ឍ និងនវានុវត្តន៍នឹងអាចកើតមានព្រមគ្នា ហើយការស្រាវជ្រាវនៅសាកលវិទ្យាល័យ នឹងក្លាយទៅជាក្បាលម៉ាស៊ីនដឹកនាំការរីកចម្រើនសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងសេដ្ឋកិច្ចពុទ្ធិថ្មីបែបនេះ។

អត្ថបទនេះពិនិត្យយ៉ាងយកចិត្តទុកដាក់លើការសង្កត់ធ្ងន់នាពេលថ្មីៗនេះរបស់ធនាគារពិភពលោក អំពីការស្រាវជ្រាវនៅសាកលវិទ្យាល័យ តាមរយៈការបើកកកាយពីដំណើរការនៃកញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍ និងនវានុវត្តន៍ក្នុងប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ២០១០ និង២០១៥ [14]។ ជាការពិតការសិក្សាប្រកបដោយការរិះគន់ចំពោះធនាគារពិភពលោក មិនមែនជារឿងថ្មីសុទ្ធសាធនោះទេនៅក្នុងអក្សរសិល្ប៍វិជ្ជាជាន់ខ្ពស់ (Academic Literature)[15]។ ជាញឹកញាប់ ការសិក្សាទាំងនេះ មានទម្រង់ជាការរិះគន់លើនិយាមគោលនៃគម្រោងជាយុទ្ធសាស្ត្រផ្នែកអប់រំរបស់ធនាគារពិភពលោក (ឧទាហរណ៍ Robertson 2012) ឬជាការវិភាគថា តើធនាគារពិភពលោកទទួលបានភាពជោគជ័យក្នុងការលើកកម្ពស់ការផ្លាស់ប្តូរ ដែលជំរុញដោយចក្ខុវិស័យបែបមនោគមវិជ្ជានៅក្នុងកម្រិតពិភពលោកដោយរបៀបណា (Verger, Edwards, and Altinyekan 2014)។ ប្រធានបទដែលបន្តមានជាហូរហែរមកនេះ គឺពិតជាមានទំនាក់ទំនងគ្នា ជាពិសេសការរិះគន់ដែលវិភាគស៊ីជម្រៅលើភូមិសាស្ត្រនយោបាយ លក្ខខណ្ឌកម្ចី ការអះអាងដែលប្រឆាំងនឹងការរកឃើញដែលមានភស្តុតាងច្បាស់លាស់ គួបផ្សំនឹងការព្រងព្រៀងមតិដែលបានមកពីការរៀបចំឡើង ដើម្បីធានាថាគោលនយោបាយរបស់ធនាគារពិភពលោក ត្រូវបានដាក់បញ្ចូលទៅបរិបទក្នុងស្រុកជាក់លាក់ណាមួយ (ឧទាហរណ៍ Brehm and Silova 2010, Edwards 2012, 2013, 2015; Jones 2007; Klees, Samoff, and Stromquist 2012; Mundy 2002; Steiner-Khamsi 2012; Verger 2012)។

ខណៈដែលស្នាដៃមុននេះ មានសារសំខាន់ អត្ថបទថ្មីនេះមានលក្ខណៈប្លែកពីគេ ដោយទាញការយកចិត្តទុកដាក់ ត្រឡប់ទៅកាន់ភាពដាច់ពីគ្នា រវាងចក្ខុវិស័យគោលនយោបាយរបស់ធនាគារពិភពលោក និងតថភាពជាក់ស្តែងក្នុងប្រទេសដែលទទួលកម្ចី ដោយលើកយកឧទាហរណ៍ជាក់ស្តែង តាមរយៈសកម្មភាពថ្មីរបស់ធនាគារពិភពលោក ក្នុងអនុវិស័យឧត្តមសិក្សា ដែលបានដាក់ឲ្យដំណើរការនៅប្រទេសកម្ពុជា (សូមមើល Brehm 2018 ផងដែរ)។ យើងព្យាយាមបំភ្លឺបន្ថែមលើអ្វីដែលត្រូវបានសង្ស័យជាយូរយារណាស់មកហើយ ប៉ុន្តែវាមិនសូវត្រូវបានលាតត្រដាង ដោយឈរលើភស្តុតាងជាក់ស្តែងនោះគឺ៖ តើបទអន្តរាគមន៍របស់ធនាគារពិភពលោក មានលក្ខណៈ **"ចក្ខុវិកល[16]បរិបទ"** (Contextually Blind) បែបណាហើយនិងថា តើកត្តានេះនាំឲ្យមានភាពបរាជ័យបែបណា។ តាមរយៈវិសាលភាពនេះ ការវិភាគរបស់យើង នឹងរួមចំណែកក្នុងការយល់ឃើញកាន់តែស៊ីជម្រៅពីឬសគល់នៃភាពបរាជ័យជាទូទៅនៃ "ការអភិវឌ្ឍ" ដែលដឹកនាំដោយបស្ចិមប្រទេស ក្នុងរយៈពេលជាង៦០ឆ្នាំ ដើម្បីនាំយកអ្វីដែលខ្លួនបានសន្យាមក

---

[14] កញ្ចប់ថវិកា ការអភិវឌ្ឍ និងនវានុវត្តន៍ត្រូវបានបន្តរហូតដល់ខែធ្នូ ឆ្នាំ២០១៦ ដោយមូលហេតុថា គម្រោងភាគច្រើនមិនអាចបញ្ចប់ការស្រាវជ្រាវឲ្យបានទាន់ពេលវេលា ឬមិនអាចចំណាយកញ្ចប់ថវិកាដូចដែលបានគ្រោងទុកឲ្យអស់។ មូលហេតុទាំងនេះនឹងត្រូវបង្ហាញជូនក្នុងអត្ថបទនេះ។

[15] អក្សរសិល្ប៍វិជ្ជាជាន់ខ្ពស់ សំដៅលើអត្ថបទសិក្សាស្រាវជ្រាវដោយអ្នកសិក្សានៅតាមសាកលវិទ្យាល័យ គ្រឹះស្ថានអប់រំជាន់ខ្ពស់ ឬស្ថាប័នស្រាវជ្រាវនានា ដែលមានការជជែកវែកញែក និងការពិភាក្សាដោយអ្នកសិក្សាជាច្រើន ខុសពីស្នាដៃអក្សរសិល្ប៍ផ្សេងទៀតដូចជា ចម្រៀង ប្រលោមលោក និងកំណាព្យជាដើម។

[16] ក្នុងវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ចក្ខុវិកលមានន័យថា ការខ្វាក់ភ្នែក។

"អោយ"[17] នោះ (ឧទាហរណ៍ Dichter 2003; Easterly 2006; Ferhuson 1990)។ **ទោះបីជាយ៉ាងនេះក៏ដោយ ភាពប្លែកពីគេរបស់អត្ថបទមួយនេះ គឺមានភាពច្បាស់លាស់បំផុត ក្នុងន័យថា យើងបង្ហាញយ៉ាងច្បាស់អំពីកំហុសជាមូលដ្ឋាននៃ 'ការគិត' របស់ធនាគារពិភពលោក អំពីបរិបទ ដែលក្រោយមក បែរជាត្រឡប់ទៅបន្ទោសប្រទេសទទួលកម្ចីវិញ ដែលជាហេតុនាំឲ្យអ្នកគិតនៅក្នុងធនាគារពិភពលោក រក្សាជំនឿលើភាពមិនចេះខុសរបស់ពួកគេ។**

របកគំហើញ និងការវិភាគដែលបង្ហាញនៅទីនេះ ពឹងផ្អែកជាចម្បងលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកនិពន្ធទី១ ដែលបានធ្វើការនៅក្នុងធនាគារពិភពលោករយៈពេលពីរឆ្នាំ ជាអ្នកប្រឹក្សាយោបល់រយៈពេលខ្លី គាំទ្រផ្នែកទី២ (ហិរញ្ញប្បទាននវានុវត្តន៍ និងការស្រាវជ្រាវ) នៃគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា។ ចាប់តាំងពីសរទរដូវឆ្នាំ២០១៣ ដល់សរទរដូវឆ្នាំ២០១៥ ធនាគារពិភពលោកបានជ្រើសរើសលោកឲ្យជួយគាំទ្រយ៉ាងយកចិត្តទុកដាក់ និងធ្វើការដោយផ្ទាល់ជាមួយសាកលវិទ្យាល័យនៅកម្ពុជា ដែលជាអ្នកទទួលបានហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ ប៉ុន្តែកំពុងជួបការលំបាកក្នុងការអនុវត្តគម្រោង។ លោកបានធ្វើដំណើរចំនួន ៧ដង ទៅកម្ពុជាក្នុងអំឡុងពេល ២ឆ្នាំនេះ ដើម្បីទៅត្រួតពិនិត្យលើគម្រោងស្រាវជ្រាវទាំង៤៥ (អនុវត្តដោយសាកលវិទ្យាល័យចំនួន២៤) ដែលក្នុងគម្រោងនីមួយៗយ៉ាងតិចបំផុតបានធ្វើការជាមួយគ្នា២ដងក្នុងអំឡុងពេលនោះ, បានរៀបចំសិក្ខាសាលាអំពីវិធីសាស្ត្រស្រាវជ្រាវថ្នាក់ជាតិ,

[17] អ្នកបកប្រែ សរសេរ "*អោយ*" តាមលោក សរ សារុន ដែលអាចធ្វើឲ្យទៅជានាម "អំណោយ" ដែលអត្ថបទនេះចង់និយាយ គឺ "*អោយ*" ទៅអ្នកដទៃ (សូមមើល ការអធិប្បាយរបស់លោកក្នុងសៀវភៅ "អត្ថាធិប្បាយទស្សនវិជ្ជា៖ ប្រធានបទវប្បធម៌ទូទៅ ប្រធានបទចិត្តវិទ្យា ប្រធានបទសង្គមវិទ្យា ប្រធានបទទស្សនវិជ្ជា" រោងពុម្ពចតុមុខ បោះពុម្ពក្នុងឆ្នាំ១៩៧៤ ទំព័រ១៥៩-១៦០)។ នៅក្នុងកម្រិតអន្តរជាតិ មានការសិក្សាជាច្រើនអំពីជំនួយអន្តរជាតិជាអំណោយ ដែលតាមពិត មានលក្ខណៈដោះដូរយកអ្វីមួយទៅវិញ ដូចជា ការពន្យល់នៅក្នុងអត្ថបទរបស់ ឃេលី គ្រីស្ទីន ដា ស៊ីលវ៉ា (Kelly Cristiane da Silva) ដែលមានចំណងជើងថា AID as Gift: an initial approach, Retrieved from http://socialsciences.scielo.org/scielo.php?script=sci_arttext&pid=S0104-93132008000100004; អត្ថបទរបស់ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (Department for International Development) ដែលមានចំណងជើងថា Foreign aid as a gift relationship: a brief literature review for Guess Who's Coming to Dinner. Appendix Four, Retrieved from https://www.gov.uk/dfid-research-outputs/foreign-aid-as-a-gift-relationship-a-brief-literature-review-for-guess-who-s-coming-to-dinner-appendix-four។ ប៉ុន្តែ នៅកម្ពុជាការសិក្សាបែបនេះពុំទាន់មានទេ។ ការសិក្សាវិភាគទៅលើជំនួយអន្តរជាតិកន្លងមក គឺមានតែអំពីផលប៉ះពាល់ជាវិជ្ជមាន ឬប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តគម្រោងជំនួយអន្តរជាតិតែប៉ុណ្ណោះ ហើយមិនដែលចោទសួរអំពីគោលបំណងនៃជំនួយនោះទេ។ ប្រសិនបើមានការវិភាគរិះគន់ខ្លះៗ ភាគច្រើននៃការសិក្សាទាំងនោះបានចោទសួរពីកត្តាដែលនាំឲ្យការអនុវត្តគម្រោងមួយមិនមានប្រសិទ្ធភាព និងប្រសិទ្ធផល។ សំណួរបែបនេះទាក់ទងទៅនឹងនយោបាយបរិបាលនៅក្នុងប្រទេសកម្ពុជា ជាជាងការស្វែងយល់ពីតក្កវិជ្ជានៃការតាក់តែងគម្រោងសម្រាប់កម្ពុជា ដូចជាអត្ថបទរបស់ អៀ សុផល ជាដើម (Sophal Ear, 2013, Aid Dependence in Cambodia: How Foreign Assistance Undermines Democracy, New York: Columbia University Press)។ ក្រៅពីនេះ ក៏មានការសិក្សាខ្លះៗផ្សេងទៀតដែរ ដែលពិភាក្សាតែពីដំណើរអភិវឌ្ឍន៍ថាជាអំណោយ ដោយចោទសួរតែអំពីនយោបាយបរិបាលក្នុងស្រុកតែប៉ុណ្ណោះ ដូចជាការសិក្សារបស់លោកស្រី ខារ៉ូឡាញ ហ៊្យូច (Caroline Hughes, 2006, The politics of gifts: Tradition and regimentation in contemporary Cambodia, Journal of Southeast Asian Studies 37(03): 469 – 489)។ និយាយបែបនេះ មិនមែនមានន័យថា នយោបាយក្នុងស្រុកមានលក្ខណៈសុក្រិតពេញលេញអាចដោះស្រាយបញ្ហាអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែផ្ទុយទៅវិញ ដោយសារចាប់តាំងពីការបញ្ចប់ទៅនៃសង្គ្រាមស៊ីវិលនៅដើមឆ្នាំ១៩៩០ គំរូអភិវឌ្ឍន៍នៃជំនួយអន្តរជាតិបានហូរចូលយ៉ាងគំហុកមកកាន់កម្ពុជា និងចាក់គ្រឹះយ៉ាងរឹងមាំឡើងក្នុងចំណោមភ្នាក់ងារអភិវឌ្ឍន៍ក្នុងស្រុក ទាំងក្នុងចំណោមភ្នាក់ងាររដ្ឋ និងសង្គមស៊ីវិល ហើយនេះជាមូលហេតុចម្បងមួយ ដែលអត្ថបទនេះ ព្យាយាមរំលេចឲ្យឃើញពីកំហុសតក្កវិជ្ជានៅពីក្រោយការតាក់តែងគម្រោងអភិវឌ្ឍន៍នេះ ដើម្បីជាមេរៀនមួយក្នុងការពិនិត្យលើតក្កវិជ្ជានៃគម្រោងអភិវឌ្ឍន៍នានាក្នុងប្រទេសកម្ពុជា។ អត្ថបទបកប្រែនេះ បានកើតឡើងស្របពេលនឹងគ្រោះមហន្តរាយនៃការរីករាលដាលជំងឺកូវីដ១៩ ដែលបានធ្វើឲ្យមានការរង្គោះរង្គើរួចជាស្រេចនូវអ្វីដែលគេជឿជាក់ថា មិនអាចដើរថយក្រោយបាននៃចរន្តតំបន់នីយកម្មនិយម សាកលភាវូបនីយកម្មនិយម លំហូរមនុស្ស និងទំនិញដោយសេរី។ល។ ជាជំហរបុគ្គល ខ្ញុំនៅតែជឿជាក់ ដូចដែល ថូម៉ាស មាក់ហ្វូ បានលើកឡើងដែរថា *គ្រប់សង្គមទាំងអស់នៅតែបន្តការជំនះប្រឹងប្រែងដើម្បីសម្រេចឲ្យបានសុខុមាលភាពសេដ្ឋកិច្ច និងស្ថិរភាពនយោបាយជាអតិបរិមាជូនដល់ពលរដ្ឋរបស់ខ្លួន* (Thomas R. McFaul, 2010, The Future of Truth and Freedom in the Global Village: Modernism and the Challenges of the Twenty-first Century, Santa Barbara: ABC- CLIO, LLC, p.159)។ បញ្ហាស្នូលនៅទីនេះ គឺថាតើកម្មវិធីអប់រំបែបណា ជាពិសេសកម្រិតឧត្តមសិក្សា ដែលអាចឆ្លើយតបចំពោះរឿងនេះបាន?

បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារនៃគម្រោងផ្នែកទី២ របស់អគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា (ហៅដោយខ្លីថា នាយកដ្ឋានឧត្តមសិក្សា) និងបានចូលរួមបេសកកម្ម សរសេរបាយការណ៍ និងធ្វើការវាយតម្លៃពីខាងក្នុងជាមួយធនាគារពិភពលោក ដែលធ្វើឡើងនៅរៀងរាល់៦ខែម្ដង។ បើទោះបីជាលោកបានរិះគន់ដោយត្រង់ៗទៅលើការអភិវឌ្ឍ ដែលដឹកនាំដោយម្ចាស់ជំនួយមុនពេលចាប់ផ្តើមការងាររបស់ខ្លួនក៏ដោយ (ឧទាហរណ៍ Rappleye 2011a; 2011b) ការប៉ុនប៉ងដើម្បីមើលឲ្យឃើញការអភិវឌ្ឍការអប់រំចេញពី *'ខាងក្នុង'* ហាក់ដូចជាឱកាសកម្រដែលគាត់មិនអាចបោះបង់ចោលនោះទេ។ ដូច្នេះ ការណ៍ដែលមើលឃើញនេះរឹតតែមានតម្លៃ និងមានទម្ងន់ក្នុងការរិះគន់បន្ថែមទៀត។ ធនាគារពិភពលោក បានជ្រើសរើសលោកឲ្យធ្វើការ ទោះបីជាលោកមានការចេញផ្សាយអត្ថបទប្រកបដោយការរិះគន់ទៅលើគោលបំណងនៃគម្រោងអភិវឌ្ឍន៍ទាំងនេះក៏ដោយ ការណ៍នេះសបញ្ជាក់យ៉ាងច្បាស់ពីសម្មតិកម្មគន្លឹះមួយដែលអត្ថបទនេះចង់បង្ហាញ៖ ធនាគារពិភពលោក យ៉ាងហោចណាស់ក្នុងចំណោមអ្នកដែលធ្វើការងារក្នុងគម្រោងជាក់ស្តែងទាក់ទងនឹងការរៀបចំផែនការ និងការអនុវត្តគម្រោងហាក់ដូចជាមិនបានអើពើនឹង (ការស្រាវជ្រាវ) អក្សរសិល្ប៍វិជ្ជាជាន់ខ្ពស់នោះទេ។ អត្ថបទនេះ គឺជាអត្ថបទដំបូង ក្នុងចំណោមអត្ថបទ ៣ផ្សេងទៀត ដែលគ្រោងនឹងសរសេរឡើងចេញពីបទពិសោធន៍ទាំងនេះ។ អត្ថបទនេះប៉ុនប៉ង លាតត្រដាងពីផលប៉ះពាល់ចេញពីបទពិសោធន៍ទាំងនេះ ដែលអាចមានមកលើវិស័យសិក្សាធិការជាន់ខ្ពស់។

អ្នកនិពន្ធទី២ ធ្វើការនៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា[18]នៃរាជរដ្ឋាភិបាលកម្ពុជាក្នុងអំឡុងពេល២ឆ្នាំដូចគ្នានេះដែរ។ ជាអតីតគ្រូបង្រៀននៅសាកលវិទ្យាល័យឈានមុខគេមួយនៅប្រទេសកម្ពុជា និងក៏ជាអ្នកដែលមានការរិះគន់លើការអភិវឌ្ឍដែលដឹកនាំដោយបរទេស (ឧទាហរណ៍ Un 2012; 2013) លោកលះបង់តួនាទីជាគ្រូបង្រៀនដែលមានឋានៈប្រសើរនេះ និងលះបង់ការទទួលយកការងារជាអ្នកប្រឹក្សាយោបល់របស់ម្ចាស់ជំនួយ ដែលមានប្រាក់ខែខ្ពស់ ដើម្បីចូលរួមជាមួយក្រសួងអប់រំ នៅពេលដែលក្រសួងត្រូវការមនុស្សដែលមានគុណសម្បត្តិផ្នែកស្រាវជ្រាវ ឬសិក្សាជាន់ខ្ពស់ ដើម្បីដឹកនាំការអនុវត្តគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ថ្មីមួយនេះ។ គាត់ត្រូវបានគេតែងតាំងឲ្យធ្វើជាអ្នកគ្រប់គ្រង ការអនុវត្តគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ទាំងមូល។ ហេតុនេះ ជាស្វ័យប្រវត្តិ គាត់បានក្លាយជាដៃគូការងារតំណាងឲ្យក្រសួងអប់រំ ធ្វើការងារជាមួយទីប្រឹក្សារយៈពេលខ្លី (សំដៅដល់អ្នកនិពន្ធទី១)។ តាមរយៈទំនាក់ទំនងការងារដ៏ជិតស្និទ្ធនេះ អ្នកនិពន្ធទាំងពីរអាចមានលទ្ធភាពក្នុងការមើលឃើញថា តើគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ត្រូវបានគេគិតយ៉ាងដូចម្តេច ទាំងពីខាងក្នុង និងពីខាងក្រៅការិយាល័យធនាគារពិភពលោក ជាទីដែលភាពខុសគ្នាខាងការយល់ឃើញ ការបន្ទោស និងជាទីដែលការធ្វើយុត្តិកម្មកើតមានឡើងផងដែរ។ តាមរយៈយុទ្ធវិធីសហប្រតិបត្តិការនេះហើយ ដែលយើងអាចអភិវឌ្ឍរូបភាពដ៏ពេញលេញអំពីកត្តាចម្បងៗ ដែលនាំទៅកាន់ភាពបរាជ័យនៃគម្រោងហិរញ្ញប្បទាន

[18] សម្រាប់ភាពងាយស្រួល នៅក្នុងអត្ថបទនេះ យើងនឹងប្រើពាក្យ ក្រសួងអប់រំ។ ទោះបីជាយ៉ាងនេះក៏ដោយ សព្ទដែលត្រឹមត្រូវជាង នោះគឺ អគ្គនាយកដ្ឋានឧត្តមសិក្សា (ឬសាមញ្ញបំផុត នាយកដ្ឋានឧត្តមសិក្សា ពាក្យខ្លីដែលធនាគារពិភពលោកប្រើ)។ នាយកដ្ឋានឧត្តមសិក្សា គឺជាអ្នកអនុវត្តន៍គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា។ នៅប្រទេសកម្ពុជា អំណាចរបស់នាយកដ្ឋានឧត្តមសិក្សាដែលឋិតនៅក្រោមក្រសួងអប់រំមានព្រំដែនកំណត់ ពីព្រោះថា គ្រឹះស្ថានឧត្តមសិក្សាជាច្រើនមិនឋិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងអប់រំនេះទេ។ នេះជារចនាសម្ព័ន្ធដែលជាមរតកនៃយុគសម័យសូវៀត ដែលគ្រឹះស្ថានឧត្តមសិក្សាទាំងនោះមានតួនាទីបណ្តុះបណ្តាលអ្នកជំនាញសម្រាប់បម្រើការងារឲ្យក្រសួង ស្ថាប័នរបស់ពួកគេរៀងៗខ្លួន។ ភាពលម្អិតទាំងនេះ មិនគួរជាការបារម្ភនៅទីនេះទេ ដើម្បីរក្សាភាពខុសគ្នានេះឲ្យមានលក្ខណៈច្បាស់លាស់សម្រាប់អ្នកអានដែលចាប់អារម្មណ៍ពីលក្ខណៈលម្អិតជាក់លាក់នៃបរិបទកម្ពុជា យើងនៅតែប្រើពាក្យ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ហើយយើងប្រើពាក្យ ក្រសួង សម្រាប់គោលបំណងទូទៅ។

ការស្រាវជ្រាវ និងនវានុវត្តន៍ នៅប្រទេសកម្ពុជា ដែលយើងនឹងបង្ហាញនៅខាងក្រោមនេះ។

មានចំណុចពីរទៀត ដែលយើងនឹងលើកយកមកពិភាក្សានៅក្នុងសេចក្តីផ្តើមនេះ។ ចំណុចទី១៖ ទោះបីជាយើងរិះគន់ទៅលើគម្រោងហិរញ្ញប្បទានការស្រាវជ្រាវ និងនវានុវត្តន៍ នៅប្រទេសកម្ពុជាក៏ដោយ អ្វីដែលយើងលើកយកមកបកស្រាយនៅក្នុងអត្ថបទនេះ យើងមិនបានសំដៅទៅលើគ្រប់ការងាររបស់ធនាគារពិភពលោកទេ។ ប៉ុន្តែតិច ឬច្រើន យើងត្រូវដាក់ការសង្ស័យបែបនេះ ដោយផ្អែកលើរបៀបដែលធនាគារពិភពលោកធ្វើបញ្ញត្តិនីយកម្មលើបរិបទ ជាវិធីដែលហាក់មានលក្ខណៈដូចគ្នានៅក្នុងគ្រប់ដំណើរការរបស់ធនាគារពិភពលោកនៅទូទាំងពិភពលោក។ លើសពីនេះ វាអាស្រ័យលើជំហររបស់អ្នកវាយតម្លៃ ការយល់ឃើញអំពីគម្រោងហិរញ្ញប្បទានការស្រាវជ្រាវ និងនវានុវត្តន៍ អាចនឹងមានភាពខុសគ្នា។ ជាការពិត សាកលវិទ្យាល័យខ្លះរីករាយនឹងទទួលយកហិរញ្ញប្បទាននេះ ដោយមិនខ្វល់ថា នៅពេលក្រោយមកដំណើរការរបស់គម្រោងមិនមានភាពរលូន និងមានការជាប់គាំងខ្លះៗនោះទេ។ អ្វីដែលយើងលើកយកមកពិភាក្សានៅទីនេះ គឺជាកំណត់ត្រានៃបទពិសោធន៍ជាក់ស្តែង ដែលរង់ចាំការឆ្លើយតបពីសំណាក់អ្នកដទៃ ហើយមិនមែនជាការអះអាងដាច់ខាតនោះទេ ថាយើងសម្រេចបាននូវវត្ថុវិស័យភាព ដែលនេះជាជំហរដែលនឹងអាចចម្លង **មាយាការអព្ភោហារិកភាពបរិបទ**[19] (Contextual Transcendence Illusion) ដែលយើងនឹងធ្វើការរិះគន់ដូចខាងក្រោម។

ចំណុចទី២៖ អ្នកអានប្រហែលជាឆ្ងល់ថា ការណ៍ដែលយើងយកចិត្តទុកដាក់ លើភាពចាំបាច់នៃការរួមចំណែកនៃការស្រាវជ្រាវតាមបែបសង្គមសាស្ត្រក្នុងអត្ថបទនេះ មានន័យបែបណា? ចម្លើយដ៏ខ្លី គឺថាបំណងរបស់យើង គឺចង់បង្ហាញពីភាពចាំបាច់នៃការមើលឃើញចេញពីអ្នកពាក់ព័ន្ធទាំងឡាយរួមទាំងអ្នកនិពន្ធផងដែរ ដែលជាគំនិតប្រឈមនឹងរូបភាពដែលគួសវាសដោយធនាគារពិភពលោកសម្រាប់ដាក់ថ្លឹងថ្លែងការវិនិច្ឆ័យនេះឲ្យមានតុល្យភាព។ ហេតុនេះ ជំហររបស់អ្នកនិពន្ធមានលក្ខណៈស្រដៀងទៅនឹងរបៀបសិក្សាបែបពិន្ទុវិទ្យា ប៉ុន្តែក៏អាចមានការតវ៉ាពីសំណាក់នរវិទូផងដែរថា យើងមិនបានអនុញ្ញាតឲ្យមានអ្នកពាក់ព័ន្ធណាម្នាក់បកស្រាយ ក្រៅតែអំពីពួកយើងដែលជាអ្នកនិពន្ធ។ ជាអកុសល មិនមាននរណាម្នាក់នៅក្នុងថ្នាក់សម្រេចចិត្តជាន់ខ្ពស់ ក្រៅពីអ្នកនិពន្ធទាំងពីរនាក់ ដែលមានសុឆន្ទៈក្នុងការនិយាយ "*ការពិត*" បែបនេះ។ ហេតុនេះ ទោះបីជាការចូលរួមមានដែនកំណត់ក៏ដោយ ការរួមចំណែករបស់អ្នកនិពន្ធ ពិតជាបានចូលរួមចំណែកក្នុងការឆ្លើយតប ទៅនឹងការអំពាវនាវថ្មីៗរបស់លោក អែនដឺសុន-ឡេវីត (Anderson-Levitt) ដែលស្នើ "ឲ្យមានការសិក្សាបន្ថែមទៀត នៅទីតាំងផ្ទាល់របស់ធនាគារពិភពលោក... ជាទីដែលពុទ្ធិត្រូវបានបង្កើត" ដើម្បី "ផ្តល់ឲ្យមនុស្សគ្រប់គ្នានូវឧបករណ៍ដ៏ប្រសើរក្នុងការកត់សម្គាល់ និងចោទសួរពីអនុត្តរភាពអំណាចរបស់ធនាគារពិភពលោក" (Anderson-Levitt 2012, 452)។ ជាថ្មីម្តងទៀត ក្រៅពីសេចក្តីបារម្ភអំពីអំណាចរបស់ធនាគារពិភពលោក អ្នកនិពន្ធ នៅតែសង្ឃឹមថា អត្ថបទមួយនេះនឹងជំរុញការគិតស៊ីជម្រៅអំពីប្រធានបទក្លាស៊ិចអំពីបរិបទ ដែលអាចជួយឲ្យយើងស្រមៃអំពីតក្កវិជ្ជាដែលកប់យ៉ាងជ្រៅ ក្នុងការបង្កើតឲ្យមានការយល់ច្រលំអំពីបរិបទ។

## ❖ បញ្ញត្តិនីយកម្ម (ខុស) អំពីបរិបទ៖ គម្រោងជាមូលដ្ឋាន

ការធ្វើការងារនៅក្នុងការិយាល័យធនាគារពិភពលោក ផ្តល់កាលានុវត្តភាពដោយផ្ទាល់ឲ្យយើងមើលឃើញពីរបៀបដែលធនាគារពិភពលោកធ្វើបញ្ញត្តិនីយកម្មអំពី "បរិបទ" ក្នុងស្រុក។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលបំផុតនោះ គឺយុទ្ធវិធី និងរបៀបដែលធនាគារពិភពលោកកំពុងអនុវត្ត ហាក់ដូចជាមិនដែលទទួលឥទ្ធិពលពីការស្រាវជ្រាវរបស់បញ្ញវន្តជាន់ខ្ពស់ ដែលបានធ្វើឡើងក្នុងអំឡុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះទាល់តែ

[19] ការយល់ច្រលំកើតចេញពីប្រធានវិស័យភាពដែលមើលរំលងបរិបទជាក់ស្តែង និងមានបំណងបង្កើត "បរិបទ" មួយដែលមានលក្ខណៈវត្ថុវិស័យ។

សោះ។ នៅក្នុងផ្នែកនេះ អ្នកនិពន្ធនឹងគូសវាសប្លង់នៃបញ្ញត្តិកម្មជាមូលដ្ឋាន ស្តីពីយុទ្ធវិធីបីយ៉ាងផ្សេងគ្នារបស់ធនាគារពិភពលោកក្នុងការយល់ពី "បរិបទ" នៅប្រទេសកម្ពុជា[20] ដែលឆ្លុះបញ្ចាំងអំពីការមានបញ្ហាយ៉ាងច្បាស់លាស់ ដែលត្រូវបានផ្តល់ឲ្យតាមរយៈការវិនិច្ឆ័យចេញមកពីអត្ថបទស្រាវជ្រាវជាន់ខ្ពស់ (ផ្នែកសង្គមសាស្ត្រ)។ ភាពច្បាស់លាស់នៃបញ្ញត្តិនៅទីនេះ ទៅលើបញ្ហាគន្លឹះអំពីបរិបទក្នុងដំណាក់កាលដំបូង ជួយឲ្យយើងចង្អុលបង្ហាញពីប្រភពច្បាស់លាស់នៃភាពបរាជ័យនៃគោលនយោបាយ នៅពេលក្រោយ។

វាជារឿងធម្មតាទៅហើយ នៅពេលដែលឮបុគ្គលិកធនាគារពិភពលោក ជាពិសេសបុគ្គលិកជនជាតិបរទេស ប្រើប្រាស់សព្ទដូចជា "វប្បធម៌ខ្មែរ" ដើម្បីពន្យល់អំពីបញ្ហា ដែលពួកគេបានជួបប្រទះក្នុងការងារប្រចាំថ្ងៃ។ ជាឧទាហរណ៍ "វប្បធម៌ខ្មែរ" ត្រូវបានគេប្រើជាញឹកញាប់ដើម្បីពន្យល់ពីមូលហេតុដែល៖ គ្មានរដ្ឋលេខាធិការណាម្នាក់ប្រឆាំងនឹងការសម្រេចចិត្តគន្លឹះរបស់រដ្ឋមន្ត្រី ឬមូលហេតុដែលបុគ្គលិកខ្មែរជួនកាលមកប្រជុំ ៣០នាទី ក្រោយម៉ោងកំណត់ជាដើម។ ការយល់ឃើញនេះ អ្នកនិពន្ធ នឹងឲ្យប្រភេទសព្ទថាជា *"ផ្នត់គំនិតបរិបទ"* (Contextual Cliché) សម្រាប់ប្រើប្រាស់ជាពហុន័យនៃបញ្ញត្តិដ៏ស្មុគស្មាញអំពី "វប្បធម៌" ដើម្បីបង្ហាញការពន្យល់មិនចេះអស់អំពីហេតុផល ដែលនាំឲ្យផែនការអន្តរាគមន៍ មិនសម្រេចបានលទ្ធផលដូចការរំពឹងទុក។ ជាការសន្មតមួយ ផ្នត់គំនិតទាំងនេះ គឺជាបិសាច (ដែលមិនងាយនឹងស្លាប់) នៃទ្រឹស្តីទំនើបនីយកម្មនិយមជាមួយភាពលំអៀងមកលើសម័យទំនើបដ៏ខ្ពស់របស់វា ក្នុងការធ្វើឲ្យវប្បធម៌នេះទៅជាការពិត និងបង្ហាញថា វប្បធម៌នេះ គឺជាឧបសគ្គចម្បងឆ្ពោះទៅកាន់ភាពវិជ្ជមាន និងការផ្លាស់ប្តូរប្រកបដោយវឌ្ឍនភាព។ ជារឿយៗ ផ្នត់គំនិតនេះ នៅតែតាមបន្លាចការព្យាយាមស្វែងរកអត្ថន័យក្នុងកិច្ចការប្រចាំថ្ងៃនៅកម្រិតប្រតិបត្តិនៅឯការិយាល័យរបស់ធនាគារពិភពលោក បើទោះបីជាដំហរបែបនេះ មិនមានការឲ្យតម្លៃពីសំណាក់អ្នកសិក្សាជាន់ខ្ពស់ក្នុងពេលថ្មីៗនេះក៏ដោយ។ ដំហរនេះ គឺបណ្តាលមកពីការមិនមានភាពបត់បែន មិនមានការយល់ដឹងពីប្រវត្តិសាស្ត្រ និងជាការប៉ុនប៉ងបង្កើតកញ្ចក់សម្រាប់សម្លឹងមើលអ្នកដទៃ (Anderson-Levitt 2012; Kipnis 2011) តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក៏ដោយ *"ផ្នត់គំនិតបរិបទ"* គឺមិនត្រូវបានលើកឡើងសូម្បីតែបន្តិចនៅក្នុងការបោះពុម្ពជាផ្លូវការរបស់ធនាគារពិភពលោក ចាប់តាំងពីឆ្នាំ១៩៨០ មកម្ល៉េះ ហើយបទពិសោធន៍របស់អ្នកនិពន្ធទាំងពីរ ក៏មិនបានរកឃើញថា ដំហរនេះបានដើរតួនាទីចម្បងក្នុងការសម្រេចចិត្តធ្វើផែនការរបស់ធនាគារពិភពលោកដែរ។ ប៉ុន្តែផ្ទុយទៅវិញ ការយល់ឃើញអំពីបរិបទដូចដែលបានលើកឡើង បានដើរតួនាទីនៅពីក្រោយខ្នង ក្នុងការបកស្រាយអំពីភាពមិនដំណើរការនៃកិច្ចការប្រចាំថ្ងៃ បន្ទាប់ពីគម្រោងជួបការលំបាកក្នុងអំឡុងពេលអនុវត្ត។

មួយវិញទៀត យុទ្ធវិធីរបស់ធនាគារពិភពលោក ដែលមានភាពស្មុគស្មាញជាងនេះ ក្នុងការធ្វើបញ្ញត្តិនីយកម្មនៃបរិបទ និងជាគន្លឹះនៃទស្សនៈរបស់យើងនៅទីនេះ នោះគឺជាអ្វីដែលយើងនឹងហៅថាជាយុទ្ធវិធី *"ប្រភេទសព្ទបរិបទទូទៅ"* (Common Contextual Categories Approach)។ យុទ្ធវិធីនៅទីនេះ មានលក្ខណៈជាអនុមានញែក ដែលបង្កើតបាននូវទស្សនទានស្រដៀងៗគ្នាអំពីបរិបទនៃប្រទេសមួយ ដោយយកប្រភេទសព្ទដែលចាត់ទុកថា អាចដំណើរការបានជាលក្ខណៈសាកលមកអនុវត្ត។ តួយ៉ាង ឯកសារវាយតម្លៃគម្រោងផ្លូវការរបស់ធនាគារពិភពលោក សម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា សរសេរក្នុងឆ្នាំ២០១០ គឺមានលក្ខណៈតំណាងបែបនេះ៖

> អនុវិស័យឧត្តមសិក្សានៅកម្ពុជា ទាំងឯកជន និងសាធារណៈ បានឆ្លងកាត់វឌ្ឍនភាព និងពង្រីកខ្លួនគួរឲ្យកត់សម្គាល់ ក្នុង

[20] នៅពេលដែលមានភាពមិនច្បាស់លាស់ យើងដាក់ពាក្យបរិបទនៅក្នុងអញ្ញប្រកាស " " ដើម្បីទាញភាពខុសគ្នារវាងការយល់ឃើញដ៏ចង្អៀតរបស់ធនាគារពិភពលោកអំពី "បរិបទ" ដែលខុសអំពីបរិបទទូលំទូលាយ នោះគឺតថភាពនៃស្ថាប័ន និងភាពស្មុគស្មាញខ្លាំងនៃប្រវត្តិសាស្ត្រ-សង្គមកម្ពុជា ដូចដែលគេមានបទពិសោធន៍ផ្ទាល់។ ភាពខុសគ្នានេះ គឺជាការចាំបាច់មួយសម្រាប់ពង្រីក និងពង្រឹងទស្សនៈរបស់អ្នកនិពន្ធនៅក្នុងសេចក្តីសន្និដ្ឋាន។

> រយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ អត្រាចុះឈ្មោះចូលរៀន បានកើនឡើងយ៉ាងគំហុកពីជាង១០.០០០ នាក់ក្នុងឆ្នាំ១៩៩២ ដល់១៣៧.២៥៣ (រួមមាន១២.៨០២ជានិស្សិតអាហារូបករណ៍) ក្នុងឆ្នាំ២០០៨ ដែលក្នុងនោះមានប្រហែល៦០% បានចុះឈ្មោះនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាឯកជន។ បច្ចុប្បន្ន មានគ្រឹះស្ថានសាធារណៈចំនួន៣២ និងគ្រឹះស្ថានឯកជនចំនួន៤៥ ដែលមានទីតាំងចំនួន១១១ (រួមទាំងទីតាំងសាខាផងដែរ ជាពិសេសនៅតាមទីរួមខេត្ត) (World Bank 2010, 2)។

ទោះបីជាឯកសារវាយតម្លៃគម្រោងផ្លូវការ មានកម្រាស់រហូតដល់១០៥ ទំព័រក៏ដោយ ផ្នែក "បរិបទជាយុទ្ធសាស្ត្រ" នេះគឺមានតែ ២ ទំព័រតែប៉ុណ្ណោះ។ ពុំមានការវិភាគឲ្យបានស៊ីជម្រៅណាមួយ អំពីស្ថានភាពរបស់សាកលវិទ្យាល័យនៅប្រទេសកម្ពុជាត្រូវបានធ្វើឡើងនោះទេ លើកលែងតែពីអ្វីដែលបានសរសេរខាងលើ ហើយក៏មិនមាននៅក្នុងអត្ថបទស្រាវជ្រាវគន្លឹះ៣ ដែលបានរៀបចំដោយអ្នកប្រឹក្សាយោបល់រយៈពេលខ្លី ក្នុងបេសកកម្មកំណត់បញ្ហា ដែលនាំទៅដល់ការធ្វើពង្រាងឯកសារវាយតម្លៃសម្រាប់បង្កើតគម្រោងផ្លូវការ និងការបង្កើតគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សានេះដែរ (McNamara 2007; Orivel 2008; Sloper 2004)។ កម្រាស់ ១០៣ទំព័រ ដែលនៅសល់ ផ្តោតជាចម្បងទៅលើសូចនាករម៉ាក្រូសេដ្ឋកិច្ច របៀបដែលគម្រោងគួរតែត្រូវបានរៀបចំឡើង ព័ត៌មានលំអិតអំពីយន្តការកម្ចី និងការវាយតម្លៃពីបញ្ហាប្រឈមផ្សេងៗ (ឧទាហរណ៍ ផលប៉ះពាល់បរិស្ថាន)។

នៅទីនេះ អនុញ្ញាតឲ្យយើងពិនិត្យមើលការសន្មតទុកជាមុនយ៉ាងច្បាស់លាស់ចំនួន៣ ដែលមាននៅក្នុង*យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ* ក្នុងនោះការសន្មតទុកជាមុននីមួយៗសុទ្ធតែមានបញ្ហាទាំងអស់។ ការសន្មតទី១៖ ប្រភេទសព្វទូទៅបានដាក់ចេញយ៉ាងច្បាស់ពីរូបភាពនៃលក្ខខណ្ឌទូទៅ។ ការពិពណ៌នារបស់ឯកសារវាយតម្លៃគម្រោងផ្លូវការខាងលើនេះផ្តល់ជាការកត់សម្គាល់ថា សាកលវិទ្យាល័យនៅកម្ពុជា គឺមានលក្ខណៈសម្បត្តិដូចគ្នាទៅនឹងសាកលវិទ្យាល័យនានា នៅជុំវិញពិភពលោក។ ការសន្មតទី២៖ ប្រភេទសព្វដែលបានជ្រើសរើសមកប្រើប្រាស់ ផ្តល់ជាការកត់សម្គាល់ថាប្រភេទសព្វខ្លួនវា គឺជាបុព្វហេតុចម្បង។ ការពិពណ៌នារបស់ឯកសារវាយតម្លៃគម្រោងផ្លូវការខាងលើនេះ ផ្តល់ជាការកត់សម្គាល់ថាអថេរគន្លឹះ ដែលឯកសារនេះបានលើកឡើង រួមមាន អត្រាចុះឈ្មោះ កំណើនគ្រឹះស្ថានសិក្សា ការបែងចែកតាមតំបន់ភូមិសាស្ត្រ តុល្យភាពរវាងវិស័យសាធារណៈ និងឯកជន គឺជាអថេរចម្បង ដែលត្រូវពិចារណាក្នុងការកំណត់អំពីទំនាក់ទំនង និងហេតុ និងផល ហើយកត្តាទាំងនេះ គឺសំខាន់បំផុតក្នុងការរៀបចំគម្រោង។ ការសន្មតទី៣៖ យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ បានបង្រួញការយកចិត្តទុកដាក់ទៅកាន់អថេរដែលចេញពីស្ថាប័នដែលនឹងត្រូវសិក្សា នោះគឺគ្រឹះស្ថានឧត្តមសិក្សាតែមួយគត់ ជាជាងពិភាក្សាពីបរិបទទូលំទូលាយនៃប្រវត្តិសាស្ត្រ សង្គម និងនយោបាយ។ ទោះបីជាយើងទទួលស្គាល់ថា *យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ* ជាទូទៅមានការយល់ដឹងអំពីបរិបទជាង *ផ្នត់គំនិតបរិបទ* នៅក្នុងចំណោមបុគ្គលិកធនាគារពិភពលោក *យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ* អាចនាំឲ្យមានកំហុសឆ្គងជាង។ ការអនុវត្តយុទ្ធវិធីប្រភេទសព្វបរិបទទូទៅ បានធ្វើអនុមានញែកចក្ខុវិស័យនៃ "បរិបទ" ប៉ុន្តែគឺជាអ្វីដែលស្ថិតនៅក្នុងភាពគ្រោះថ្នាក់ជានិច្ច ពីព្រោះមានការភ័ន្តច្រលំថា នេះជាតថភាពជាសារវន្ត ជាអ្វីដែលលុបបំបាត់រួចជាស្រេចតាំងពីដំបូងនូវការប៉ុនប៉ងណាមួយក្នុងការស្វែងរកអថេរដែលមានលក្ខណៈជាក់លាក់សម្រាប់បរិបទណាមួយ។

សំខាន់ជាងនេះទៅទៀត យើងកត់សម្គាល់ឃើញថា ភាពខ្វះចន្លោះនៃ *យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ* ត្រូវបានរំលេចឲ្យឃើញដោយអ្នកសិក្សាជាន់ខ្ពស់ជាច្រើនលើកជាច្រើនសាក្នុងអំឡុងជាង១០០ឆ្នាំមកហើយ ជារយៈពេលមួយចាស់ជាងវត្តមានរបស់ធនាគារពិភពលោកខ្លួនឯងទៅទៀត។ *យុទ្ធវិធីប្រភេទសព្វបរិបទទូទៅ* របស់ធនាគារពិភពលោក គឺជាឧទាហរណ៍យ៉ាងច្បាស់ក្រឡែតអំពីអ្វីដែល លោក ម៉ាក្ស វេប័រ[21]

[21] ម៉ាក្ស វេប័រ (១៨៦៤–១៩២០) គឺជាសង្គមវិទូ ទស្សនវិទូ អ្នកច្បាប់ និងសេដ្ឋវិទូនយោបាយជនជាតិអាល្លឺម៉ង់ ដែលទ្រឹស្តីរបស់លោក មានឥទ្ធិពលលើដំណើរការអភិវឌ្ឍន៍សង្គមបស្ចិមប្រទេសទំនើប។

(Max Weber) បានឲ្យឈ្មោះប្រភេទសព្វនេះថា ជា "ប្រភេទឧត្តមគតិ"។ សម្រាប់ លោក វេប័រ បញ្ហាវិធីសាស្ត្រចម្បងនៃគ្រប់វិទ្យាសាស្ត្រសង្គម ត្រូវបានបង្កើតឡើងដោយ "ប្រភេទឧត្តមគតិ" មិនមែនត្រូវបានដោះស្រាយ ដោយ "ប្រភេទឧត្តមគតិ" នោះទេ គឺថា៖ តើនៅត្រឹមកម្រិតណាដែលប្រភេទសព្វវត្ថុវិស័យមានមូលន័យសង្ខេប ដែលបង្កើតឡើងដោយអ្នកអង្កេតម្នាក់ អាចជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់តំណាងឲ្យគំនិត ដែលកៀកនឹងភាពជាក់ស្តែង និងអាចជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់តំណាងឲ្យអត្ថន័យបរិបទប្រធានវិស័យនៃអ្វីដែលគាត់កំពុងអង្កេត? ប្រភេទឧត្តមគតិ គឺជាការអង្កេត និងការធ្វើមូលន័យសង្ខេបជាប្រចាំ និងដដែលៗ ហើយមិនមែនជាចុងបញ្ចប់នោះទេ។ តាំងពីឆ្នាំ១៩៣០ សាវ័ករបស់ លោក វេប័រ ដែលគួរឲ្យកត់សម្គាល់ជាងគេ គឺអ្នកវិទ្យាសាស្ត្រសង្គមដ៏ល្បីល្បាញ លោក អែលហ្វ្រែដ ស្ស៊ុត[22] (Alfred Schütz) ដែលជាអ្នកគិតយ៉ាងសកម្មនៅសហរដ្ឋអាមេរិក បានព្រមានចំពោះអ្នកទាំងឡាយណាដែលមាននិន្នាការប្រើប្រាស់វិធីសាស្ត្រ "ប្រភេទឧត្តមគតិ"៖

> ការអង្កេតអំពីអាកប្បកិរិយាសង្គមដទៃ គឺអាចមានគ្រោះថ្នាក់យ៉ាងពិតប្រាកដ នៅពេលដែលអ្នកអង្កេតនោះ ដាក់ប្រភេទឧត្តមគតិរបស់ខ្លួនជំនួសឲ្យគំនិតរបស់មនុស្ស/សង្គម[23] ដែលខ្លួនកំពុងអង្កេត។ គ្រោះថ្នាក់នឹងរឹតតែខ្លាំងឡើង នៅពេលដែលអ្នកអង្កេតមិនយកចិត្តទុកដាក់ដោយផ្ទាល់ទៅលើអ្នកដែលខ្លួនកំពុងអង្កេត ប៉ុន្តែគិតអំពីអ្នកដែលខ្លួនកំពុងអង្កេត ថាជា "ករណីប្រវត្តិសាស្ត្រ" ដែលត្រូវបានកំណត់មូលន័យសង្ខេបរួចជាស្រេច ថាបែបនេះ ឬបែបនោះ។ នៅទីនេះ មិនត្រឹមតែអ្នកអង្កេតប្រើប្រាស់ប្រភេទឧត្តមគតិខុស ក្នុងការស្វែងយល់ពីអាកប្បកិរិយាមនុស្ស/សង្គមប៉ុណ្ណោះទេ តែគាត់នឹងមិនអាចរកឃើញកំហុសខ្លួនឯងផងដែរ ពីព្រោះគាត់មិនដែលប្រឈមនឹងអ្វីដែលគាត់អង្កេត ថាជាមនុស្ស/សង្គមពិត (Schütz [1932] 1967, 205)។

អ្នកស្រាវជ្រាវជាន់ខ្ពស់ទាំងនេះសង្កត់ធ្ងន់ ទៅលើការណ៍ដែលអ្នកអង្កេត ចាំបាច់ត្រូវសួរអ្នកដែលខ្លួនត្រូវអង្កេតក្នុងបរិបទជាក់លាក់ណាមួយ ពីរបៀបដែលពួកគេបកស្រាយពីអ្វីដែលហៅថាចាំបាច់ ពីព្រោះការបកស្រាយនេះ ជាសកម្មភាពសង្គមដ៏ចម្បងមួយ *(Verstehen)* (សូមមើលផងដែរ Brehm 2017)។ បើទោះបីជាមានការឆ្លុះបញ្ចាំងដ៏ស៊ីជម្រៅបែបសង្គមសាស្ត្រនេះក៏ដោយ យុទ្ធវិធីរបស់ធនាគារពិភពលោកជាចម្បងក្នុងការធ្វើបញ្ញត្តិកម្មបរិបទ សំដៅលើយុទ្ធវិធីប្រភេទសព្វបរិបទទូទៅ មិនត្រឹមតែមិនបានផ្លាស់ប្តូរ ចាប់តាំងពីស្ថាប័ននេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៤៤ ប៉ុណ្ណោះទេ ប៉ុន្តែវាបែរជារឹតតែខ្លាំងឡើងថែមទៀត។ ឧបករណ៍វិភាគគោលនយោបាយថ្មីបំផុត របស់ធនាគារពិភពលោក ហៅថា ប្រព័ន្ធប៉ាន់ប្រមាណវាយតម្លៃ និងចំណុចដៅធៀបសម្រាប់លទ្ធផលអប់រំ (SABER) (សូមមើល Kless and Edwards 2014) គឺជាឧទាហរណ៍នៃការបន្តយ៉ាងក្លាហាននៃការអនុវត្តយុទ្ធវិធីប្រភេទឧត្តមគតិដែលគ្មានន័យនេះ។

នៅកម្រិតមួយដែលជ្រៅជាងនេះ មិនមែនយុទ្ធវិធី *"ផ្ទត់គំនិតបរិបទ"* ហើយក៏មិនមែនយុទ្ធវិធី *"ប្រភេទសព្វបរិបទទូទៅ"* ទេ ដែលជាយុទ្ធសាស្ត្រផ្តាច់មុខដែលបុគ្គលិកធនាគារពិភពលោកបានប្រើប្រាស់ក្នុងនាមជាអ្នកចូលរួមក្នុងបរិបទ។ ក្នុងន័យនេះ បរិបទសម្រាប់អ្នកដែលធ្វើការនៅធនាគារពិភពលោក មានន័យថា *"ជារបស់កម្ពុជា"* ជាវត្ថុវិស័យ *"ដែលនៅទីនោះ"* ហើយមិនមានការជាប់ពាក់ព័ន្ធអ្វីទាល់តែសោះជាមួយធនាគារពិភពលោក។ ចេញពីទស្សនវិស័យធនាគារពិភពលោក មូលនិធិសម្រាប់គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា គឺគ្រាន់តែត្រូវបានផ្ទេរទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចផ្ទេរបន្តទៅកាន់ក្រសួងអប់រំ ហើយក្នុងករណីគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ត្រូវបានបើកបន្តឲ្យទៅ និងប្រើប្រាស់ដោយអ្នកស្រាវជ្រាវនៅ

[22] អែលហ្វ្រែដ ស្ស៊ុត (១៨៩៩–១៩៥៩) គឺជាទស្សនវិទូ និងបាតុភូតវិទូសង្គម ជនជាតិអូទ្រីស ដែលបានបូកបញ្ចូលរវាងបាតុភូតវិទ្យា និងមូលដ្ឋានគ្រឹះទស្សនវិជ្ជាអំពីសង្គម និងសេដ្ឋកិច្ច។

[23] សង្គម ជាការបន្ថែមរបស់អ្នកបកប្រែ និងកែសម្រួលជាភាសាខ្មែរ។

សាកលវិទ្យាល័យ។ ទោះបីជាធនាគារពិភពលោក ជួនកាលធ្វើការតាមដាន ការប្រើប្រាស់ថវិកានេះយ៉ាងយកចិត្តទុកដាក់ ឬណែនាំពីវឌ្ឍនភាពទៅរក "សូចនាករគន្លឹះៗរបស់គម្រោង" ក៏ដោយ ធនាគារពិភពលោក ស្រមើស្រមៃពីជញ្ជាំងខណ្ឌចែកគ្នារវាងខ្លួនឯង និងប្រទេសទទួលកម្ចីយ៉ាងច្បាស់លាស់។ អត្តរូបភាពដែលមាននៅខាងក្នុងធនាគារពិភពលោក គឺជញ្ជាំងដែលបិទជិតមិនមានខ្យល់ និងពន្លឺអាចចូលបាន និងមិនឲ្យមើលឃើញរវាងអ្នកឲ្យខ្ចី និងអ្នកខ្ចី នេះគឺជាការស្រមើស្រមៃដ៏ងាយស្រួល ដែលរារាំងធនាគារពិភពលោកមិនឲ្យមើលឃើញខ្លួនឯងថាជាផ្នែកមួយនៃបរិបទក្នុងប្រទេសកម្ពុជា។

ជាថ្មីម្តងទៀត ធនាគារពិភពលោក បរាជ័យមិនព្រមយកចិត្តទុកដាក់ពីការព្រមានជាញឹកញាប់របស់អ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនដែលថា ទោះបីជាក្នុងពេលដែលអង្កេតបាតុភូតអប់រំអន្តរជាតិ ម្នាក់ៗត្រូវតែដើរតួរជានិច្ច មិនត្រូវដកឃ្លាធ្វើជាអ្នកអង្កេតដែលមិនមានការជាប់ពាក់ព័ន្ធអ្វីនោះទេ (Sobe and Kowlczyk 2014)។ អ្នកស្រាវជ្រាវជាន់ខ្ពស់ខ្លះ បានហៅកំហុសនៃការដែលមានលទ្ធភាពអាចឈរនៅក្រៅបរិបទនេះថាជា *"ល្បែងអាទិទេព"* ដែលអះអាងថា *"មើលឃើញអ្វីៗទាំងអស់ ដោយមិនចាំបាច់ឈរនៅទីតាំងនោះឡើយ"* (Haraway 1988)។ សូម្បីតែក្នុងកម្រិតការិយាល័យ នៅធ្វើការងារផ្ទាល់ដែលមានបុគ្គលិកនៅជាប់នឹងបរិបទ មានលទ្ធភាពក្នុងការទទួលស្គាល់បរិបទ ទាំងការអង្កេត និងបទអន្តរាគមន៍នៅក្នុងការងារប្រចាំថ្ងៃក៏ដោយ វាហាក់ដូចជាមានការយល់ដឹងតិចតួចណាស់ ដូចករណីនៅប្រទេសកម្ពុជា ដែលវត្តមានធនាគារពិភពលោក គឺជាផ្នែកមួយនៃផ្ទាំងទស្សនីយភាពនៃបរិបទមួយនៅទីនោះ។ យើងចាត់ប្រភេទសព្ទនេះ ថាជា *"អព្ភោហារិកភាពបរិបទ"*[24] (Contextual Transcendence) ហើយមើលឃើញវាថាជាបញ្ញត្តិ ដែលគ្រោះថ្នាក់ជាងគេបំផុតក្នុងចំណោមបញ្ញត្តិទាំងបី ដែលបានរៀបរាប់ខាងលើ៖ នៅពេលដែលសកម្មភាពការងាររបស់ធនាគារពិភពលោកដំណើរការក្នុងទីងងឹតបែបនេះ វិបាកដែលចេញពីភាពបរាជ័យទាំងឡាយណា ដែលកើតមានក្រោយការអនុវត្តគម្រោង *ចាំបាច់* ត្រូវតែជាកំហុសដែលកើតឡើងដោយប្រទេសទទួលកម្ចី។

## ❖ គំរូគោលនយោបាយ៖ គម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សា នៅប្រទេសបង់ក្លាដែស

យោងទៅលើវដ្តនៃការបង្កើតគម្រោងអភិវឌ្ឍន៍របស់ធនាគារពិភពលោក ជាធម្មតា វាត្រូវការរយៈពេលពី៤ ទៅ១០ឆ្នាំ ទំរាំទិសដៅថ្មី ដែលដាក់ចេញក្នុងសៀវភៅ *កសាងសង្គមពុទ្ធិ* (Constructing Knowledge Societies 2002) ត្រូវបានយកទៅបង្កើតជាកម្មវិធីអន្តរាគមន៍ជាក់ស្តែងនៅក្នុងកម្រិតប្រទេសណាមួយ។ ក្នុងឆ្នាំ២០០៧ ការរៀបចំបានចាប់ដំណើរការសម្រាប់ការប្រតិបត្តិចក្ខុវិស័យនេះនៅប្រទេសបង់ក្លាដែស ហើយទទួលបានការសម្រេចចិត្តអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាលធនាគារពិភពលោកក្នុងឆ្នាំ២០០៩ មានឈ្មោះថា "គម្រោងពង្រឹងគុណភាពឧត្តមសិក្សា"។ សសរស្តម្ភនៃបទអន្តរាគមន៍គម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សាដែលមានទឹកប្រាក់ចំនួន៩១លានដុល្លារសហរដ្ឋអាមេរិក គឺមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់[25]។ ចក្ខុវិស័យគោលនយោបាយគឺសាមញ្ញ៖ បង្កើតកញ្ចប់ថវិកាឲ្យបានច្រើន សម្រាប់សាកលវិទ្យាល័យដើម្បីធ្វើការស្រាវជ្រាវ។ ហិរញ្ញប្បទានទាំងនេះ ត្រូវបានផ្តល់ឲ្យសាកលវិទ្យាល័យ ទាំងសាធារណៈ និងឯកជនដោយឈរលើគោលការណ៍ប្រកួតប្រជែង។ អ្នកស្រាវជ្រាវ

---

[24] សភាពនៃបរិបទដែលហួសពី ឬឯករាជ្យពីប្រធានវិស័យភាព។

[25] មានភស្តុតាងខ្លះៗបង្ហាញថា មុនកម្មវិធីនេះកើតឡើង គម្រោងបែបនេះអាចត្រូវបានរកឃើញនៅប្រទេសស៊ីលី (Chile) និងអាហ្សង់ទីន ទាញចេញពីគំរូដែលបានមកពីចក្រភពអង់គ្លេស (សូមមើល Marquis 2000)។ ចំណាកគំរូពីអាមេរិកឡាទីន មកកាន់ "អាស៊ីប៉ូស៊ីហ្វិក" គឺអាចទៅរួច ដោយហេតុថា ការណ៍នេះជាន់គ្នានឹងការមកដល់នៃអ្នកគ្រប់គ្រងផ្នែកថ្មីមួយនេះ ជាអ្នកដែលមកពីតំបន់អាមេរិកឡាទីន។ ការមកដល់នៃកម្មវិធីផ្សេងទៀតរបស់អាមេរិកឡាទីនដូចជា កម្មវិធីនៅប្រទេសអេសស្កូឡាញ៉ូវ៉ា (Escuela Nueva) បានមកដល់ប្រទេសវៀតណាមនៅអំឡុងពេលនេះដែរ នេះអាចជាភស្តុតាងគាំទ្រការអះអាងបែបនេះបាន។ នៅក្នុងកម្រិតដែលការណ៍នេះអាចជាការពិត វាក៏គាំទ្រនូវអ្វីដែល ស្តេនន័រ-ខាមស៊ី (Steiner-Khamsi 2004) ធ្លាប់បានហៅវាថាជា "វិបាកម៉ារីអូរ៉ូគឺ (Maris O' Rourke Effect)"។ នោះ គឺជាវិបាកដែលលទ្ធផលរបស់វា មិនដូចទៅនឹងអ្វីដែលធ្លាប់កើតមាននៅក្នុងប្រទេសដែលអនុវត្តគំរូដើម។

និងថ្នាក់ដឹកនាំសាកលវិទ្យាល័យ គ្រាន់តែសរសេរពាក្យស្នើសុំខ្លីមួយ តាមបែបស្តង់ដារចំនួន៣-៥ទំព័រ។ គណៈកម្មការសាកលវិទ្យាល័យបង់ក្លាដែស ដែលមានស្រាប់នឹងដើរតួរជាអ្នកពិនិត្យពាក្យស្នើសុំ ជ្រើសរើស និងគ្រប់គ្រងថវិកា។ ការជ្រើសរើស ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ហើយបើកទទួលសំណើលើពាក្យស្នើសុំ ៤ប្រភេទ ប្រភេទនីមួយៗផ្តោតលើប្រធានបទ៖ ការរៀន និងការបង្រៀន (ប្រភេទទី១) ការស្រាវជ្រាវ (ប្រភេទទី២) ការផ្ទេរបច្ចេកវិទ្យាដ៏ទូលំទូលាយពីសាកលវិទ្យាល័យទៅសហគមន៍ (ប្រភេទទី៣) និងការតភ្ជាប់ឧស្សាហកម្មជាមួយសាកលវិទ្យាល័យ និងការធ្វើពាណិជ្ជកម្មចេញពីរបកគំហើញស្រាវជ្រាវ (ប្រភេទទី៤ (HEQEP 2013)។ ទំនោរនៃការជ្រើសរើស ត្រូវបានផ្តោតលើគម្រោងណា ដែលបង្ហាញពីការប៉ុនប៉ងភ្ជាប់សាកលវិទ្យាល័យទៅនឹងទីផ្សារការងារ (HEQEP 2013, i)។

ការទទួលបានសម្ភារ គឺជាចំណុចចម្បងបំផុតនៃមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់នៅប្រទេសបង់ក្លាដែស។ នៅក្នុងរយៈពេល២ឆ្នាំដំបូងនៃការអនុវត្តគម្រោង (២០១០-២០១១) គម្រោងចំនួន១៩៤ ត្រូវបានផ្តល់ថវិកាឲ្យធ្វើសកម្មភាព ដែលក្នុងនោះគម្រោងនីមួយៗ មានទឹកប្រាក់ចន្លោះពី ៣.៧០០ ដល់ ៦០.០០០ ដុល្លារសហរដ្ឋអាមេរិក។ ការផ្តោតជាចម្បងគឺទៅលើការទិញសម្ភារវិទ្យាសាស្ត្រចុងក្រោយបំផុត ការរៀបចំជួសជុលមន្ទីរពិសោធន៍ ការធ្វើសេវាបណ្ណាល័យឲ្យមានលក្ខណៈស្វ័យប្រវត្តិ និងការកែលម្អបន្ទប់បង្រៀនឲ្យមានលក្ខណៈឌីជីថល (ក្តាខៀន ម៉ាស៊ីនបញ្ចាំងរូបភាព និងសម្ភារបំពងសំឡេង។ល។) គម្រោងដែលមិនផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ គឺមានលក្ខណៈចង្អៀត ដោយត្រឹមតែជាការធ្វើដំណើរទៅបរទេស និងការរៀបចំសិក្ខាសាលាជាតិ/អន្តរជាតិ។ ដូចដែលរបាយការណ៍វាយតម្លៃពាក់កណ្តាលការអនុវត្តគម្រោងនៃមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់បង្ហាញ ភាពជោគជ័យដ៏ធំធេងរបស់មូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់ គឺស្ថិតនៅលើការកែលម្អខាងសម្ភារ៖

> កុំព្យូទ័រសម្រាប់មន្ទីរពិសោធន៍ ៧០គ្រឿង កុំព្យូទ័រ ២២៣៦ គ្រឿង សម្ភារផ្សព្វផ្សាយពហុព័ត៌មាន ៧៦៨គ្រឿង [ស៊ិក] ត្រូវបានដាក់ឲ្យសិស្សនិស្សិត និងសាស្ត្រាចារ្យប្រើប្រាស់ រួមជាមួយមន្ទីរពិសោធន៍កម្រិតពិភពលោកចំនួន៣០ ដែលក្នុងនោះ មានឧបករណ៍វិទ្យាសាស្ត្រទំនើបចុងក្រោយ យ៉ាងតិចចំនួន៤១ ដែលពុំធ្លាប់មាននៅក្នុងសាកលវិទ្យាល័យនៅប្រទេសបង់ក្លាដែសពីមុនមក ឯដេប៉ាតឺម៉ង់ចំនួន២៧ បានកសាងបន្ទប់រៀនទំនើប និងដេប៉ាតឺម៉ង់ចំនួន៥០ បានជួសជុសបន្ទប់រៀន និងបន្ទប់សិក្ខាសាលារបស់ពួកគេ ឯសាកលវិទ្យាល័យចំនួន៥ បានបំពាក់ប្រព័ន្ធបណ្ណាល័យស្វ័យប្រវត្តិ...សៀវភៅចំនួន ១៥០.០០០ ក្បាលត្រូវបានបញ្ជាទិញ ហើយអត្ថបទទស្សនាវដ្តីវិទ្យាសាស្ត្រ២២.០០០ ចំណងជើងត្រូវបានដាក់ឲ្យប្រើប្រាស់ (HEQEP 2013, ii)។

ករណីសាកលវិទ្យាល័យកសិកម្មបង់ក្លាដែស ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របសុសត្វ គឺជាឧទាហរណ៍យ៉ាងច្បាស់នៅទីនេះ។ ដោយទទួលបានថវិកា ៥០.០០០ ដុល្លារសហរដ្ឋអាមេរិក ដេប៉ាតឺម៉ង់ចំណាយថវិកាជាង៩០% ទៅលើការជួសជុសបន្ទប់រៀនរបស់ខ្លួន បំពាក់ម៉ាស៊ីនបញ្ចាំងរូបភាព កុំព្យូទ័រ ប្រព័ន្ធសំឡេង និងសម្ភារការិយាល័យ។ ថវិកា៥% ផ្សេងទៀត ត្រូវបានចំណាយទិញរថយន្តដឹកទំនិញសម្រាប់ធ្វើជារថយន្តសង្គ្រោះបន្ទាន់នៅកសិដ្ឋាន សម្រាប់ការព្យាបាល និងពិនិត្យជំងឺសត្វ ហើយថវិកាដែលនៅសល់ ប្រើសម្រាប់បញ្ជូនសាស្ត្រាចារ្យចំនួន ៥នាក់ ទៅទទួលការបណ្តុះបណ្តាលផ្ទាល់រយៈពេល ៣ថ្ងៃនៅប្រទេសម៉ាឡេស៊ី (HEQEP 2013, 1)។ ស្ទើរតែគ្រប់គម្រោងទាំងអស់ មានការបែងចែកថវិកាក្នុងសមាមាត្រប្រហាក់ប្រហែលគ្នានេះ។

ហេតុអ្វីបានជាការទទួលបានធនធានរូបវន្ត គឺជាចំណុចស្នូលនៃគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សា? ចម្លើយគឺថា ធនាគារពិភពលោក យល់ឃើញពីបរិបទប្រទេសបង់ក្លាដែស ថាជាប្រទេសដែលសម្បូរទៅដោយ អ្នកមានសញ្ញាបត្របណ្ឌិត ប៉ុន្តែសម្ភារ និងមន្ទីរពិសោធន៍មានសភាពមិនល្អ ហេតុនេះមិនមានលទ្ធភាព ប្រែក្លាយអ្នកស្រាវជ្រាវដែលទទួលបានការបណ្តុះបណ្តាលខ្ពស់ឲ្យផលិតបាននូវលទ្ធផលស្រាវជ្រាវប្រកប

ដោយនវានុវត្តន៍នោះទេ។ ទោះបីជាការប៉ាន់ប្រមាណអំពីចំនួនអ្នកមានសញ្ញាបត្របណ្ឌិតនៅមានការសង្ស័យខ្លះៗក៏ដោយ[26] គេប៉ាន់ប្រមាណថា នៅបង់ក្លាដែស អ្នកមានសញ្ញាបត្រអាចមានចំនួនប្រហែលពី ៥.០០០ ទៅ ៦.០០០នាក់ ក្នុងអំឡុងឆ្នាំ២០០០ ក្នុងចំណោមប្រជាជនសរុបប្រហែលចំនួន១៤០លាននាក់។ រូបភាពដែលគួរឲ្យទុកចិត្ត បានលេចឡើងនៅពេលយើងបង្រួមមកកាន់សាកលវិទ្យាល័យកសិកម្មតែមួយមុខ។ ការសិក្សាមួយរកឃើញថា នៅក្នុងចំណោមមហាវិទ្យាល័យ និងសាកលវិទ្យាល័យឈានមុខគេចំនួន១៧ នៅទូទាំងប្រទេស (រួមទាំងសាកលវិទ្យាល័យជាតិកសិកម្មក្នុងករណីខាងលើ) ភាគរយនៃអ្នកស្រាវជ្រាវដែលមានសញ្ញាបត្របណ្ឌិតមានចំនួន៥៥% (Beintema and Kabir 2006)។ តួរលេខនេះ មានចំនួនច្រើនជាង២ដង នៃតួរលេខជាមធ្យមនៃអ្នកស្រាវជ្រាវនៅវិទ្យាស្ថានស្រាវជ្រាវ គាំទ្រដោយរដ្ឋាភិបាល ដែលនៅតែមានចំនួនច្រើនគួរឲ្យកត់សម្គាល់រហូតដល់២៥%។ ក្នុងឆ្នាំ១៩៨១ ចំនួនអ្នកស្រាវជ្រាវពេញម៉ោងនៅក្នុងមហាវិទ្យាល័យទាំង១៧នេះ មានអ្នកមានសញ្ញាបត្របណ្ឌិតតែចំនួន៤១នាក់តែប៉ុណ្ណោះ ប៉ុន្តែនៅក្នុងឆ្នាំ២០០២ ចំនួននេះបានកើនឡើងដល់ទៅជិត ៣ដង រហូតដល់ ១១៩ (Beintema and Kabir 2006)។

តើអ្វីទៅដែលនាំឲ្យមានចំនួនបណ្ឌិតច្រើន? នៅពីក្រោយតួរលេខ ដែលជាចំនួនខ្ពស់ជាងគេនៅអាស៊ីខាងត្បូងនេះ គឺមានមូលហេតុពីរ៖ មរតកប្រវត្តិសាស្ត្រ និងចំនួនគម្រោងដ៏ច្រើនរបស់ម្ចាស់ជំនួយ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយក្នុងការឧបត្ថម្ភគាំទ្រការអប់រំថ្នាក់បណ្ឌិត។ ជាលក្ខណៈប្រវត្តិសាស្ត្រ ដោយសារតែទីក្រុងនៃអាណានិគមនិយមអង់គ្លេសមានទីតាំងស្ថិតជាប់ទីក្រុងកុលកាតា (Kolkata) រហូតដល់ឆ្នាំ១៩១១ កិច្ចប្រឹងប្រែងរបស់អង់គ្លេសក្នុងការធ្វើឲ្យឥណ្ឌាមាន "អារ្យធម៌" តាមរយៈសាលារៀន ការរៀនសូត្រ និងសាកលវិទ្យាល័យបែបបស្ចឹមប្រទេស បានធ្វើឲ្យជ្រុងខាងកើតនៃតំបន់នេះ ក្លាយជាមជ្ឈមណ្ឌលនៃសាកលវិទ្យាល័យទំនើបមុនគេនៃឧបទ្វីបនេះ។ ដោយចម្លងតាមគំរូចក្រភពអង់គ្លេស សាកលវិទ្យាល័យទាំងនេះ មិនមែនផ្តោតតែលើការបង្រៀនតែមួយមុខទេ។ ជាឧទាហរណ៍ សាកលវិទ្យាល័យដាក្កា (Dhaka) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩២១ ដែលមានសាកលវិទ្យាធិការជាជនជាតិអង់គ្លេស ដែលធ្លាប់បានធ្វើការនៅសាកលវិទ្យាល័យឡុងដ៍ (London) បានធ្វើការកត់សម្គាល់ក្នុងពិធីបញ្ចប់ការសិក្សាដំបូងគេនៅសាកលវិទ្យាល័យ ដាក្កា នេះថា៖

> មនុស្សម្នាក់ អាចធ្វើជាគ្រូបង្រៀនមុខវិជ្ជាថ្នាក់បឋមសិក្សាដ៏ប្រសើរ ដោយមិនមានអំណាចអាចបន្ថែមលើចំណេះដឹង។ ប៉ុន្តែក្នុងការបង្រៀនកម្រិតឧត្តមសិក្សា ខ្ញុំអះអាងថា គ្មាននរណាម្នាក់បង្រៀនបានល្អទេ ប្រសិនបើគាត់គ្មានលទ្ធភាពប្តូកបញ្ចូលការស្រមើស្រមៃ ជាមួយនឹងអំណាចរិះគន់ ដែលនាំទៅកាន់ការបង្កើតផលិតផល (ចំណេះដឹង) ថ្មី ហើយដោយមូលហេតុនេះ ប្រសិនបើមិនមានមូលហេតុណាផ្សេងទៀតទេ ដើម្បីឲ្យសាកលវិទ្យាល័យមួយ ក្លាយជាសាកលវិទ្យាល័យពិតប្រាកដ គឺគ្រូរបស់ខ្លួន ត្រូវតែជាអ្នកដែលមានសមត្ថភាពអាចបង្កើតពុទ្ធិដ៏ឧត្តុង្គឧត្តមនេះ (Hartog 1923)។

ជាមួយគំនិត ដែលគេមើលឃើញពីភាពបន្តរបស់វានៅក្នុងសៀវភៅ *កសាងសង្គមពុទ្ធិ* (Constructing Knowledge Society) បែបនេះ មានន័យថា ការសិក្សាកម្រិតបណ្ឌិតមានប្រវត្តិនៃការគាំទ្រ និងលើកទឹកចិត្តជាយូរយារណាស់មកហើយនៅទីនោះ។ ប្រពៃណីនេះ បានបន្តឥតដាច់ក្នុងស្ថាប័នទាំងនេះដូចជា សាកលវិទ្យាល័យ ដាក្កា ចាប់តាំងពីសម័យអាណានិគមនិយមអង់គ្លេសមកម្ល៉េះ។

អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៅទៀតនោះ គឺកត្តាទី២៖ គម្រោងម្ចាស់ជំនួយធំៗជាច្រើននៅប្រទេសបង់ក្លាដែស ចាប់តាំងពីឆ្នាំ១៩៨០មក បាននាំឲ្យមានកំណើនការគាំទ្រដល់អ្នកបន្តការសិក្សាយកសញ្ញាបត្រថ្នាក់បណ្ឌិតនៅក្រៅប្រទេស។ ការគាំទ្រជាចម្បង គឺតាមរយៈជំនួយសហរដ្ឋអាមេរិក និងធនាគារពិភពលោក ដែលនាំឲ្យមានកំណើនអ្នកមានសញ្ញាបត្របណ្ឌិតជាច្រើន។ ដោយលើកយកឧទាហរណ៍ក្នុងវិស័យ

[26] នៅក្នុងបរិបទដែលសញ្ញាបត្រអាចក្លែងបន្លំបាន ទិញបាន ឬអាចបញ្ចប់បានដោយមិនមានការប្រឹងប្រែង។

កសិកម្មដដែល គម្រោងគ្រប់គ្រងការស្រាវជ្រាវវិស័យកសិកម្មរបស់ធនាគារពិភពលោក ចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០១ អនុញ្ញាតឲ្យអ្នកស្រាវជ្រាវចំនួន ១០៦នាក់ បន្តការសិក្សា និងទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត (Beintema and Kabir 2006, 6)។ បញ្ហាដែលធនាគារពិភពលោក និងគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សា "ទទួលស្គាល់" នៅពេលនោះ គឺមិនមែនអ្នកដែលមិនចេះធ្វើការស្រាវជ្រាវនោះទេ ប៉ុន្តែ មកពីកង្វះសម្ភារ និងឧបករណ៍៖ នៅពេលដែលអ្នកដែលទើបតែបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតទាំងនេះ ត្រឡប់មកកាន់ប្រទេសបង់ក្លាដែសវិញ ពួកគេមិនមានលទ្ធភាពបន្តការស្រាវជ្រាវរបស់ពួកគេនោះទេ ពីព្រោះតែបរិស្ថានគាំទ្រការស្រាវជ្រាវមិនល្អ[27]។

## ❖ គោលនយោបាយនាំចេញ និង "ចក្ខុវិស័យយុទ្ធសាស្ត្រ"៖ គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា នៅកម្ពុជា

១៨ខែបន្ទាប់ពីការអនុវត្តគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សានៅប្រទេសបង់ក្លាដែស ធនាគារពិភពលោកចាប់ផ្តើមរៀបចំតាក់តែងគម្រោងកម្ចីវិនិយោគដំបូងបង្អស់របស់ខ្លួនមកកាន់ប្រទេសកម្ពុជា ដែលផ្តោតជាពិសេសលើអនុវិស័យឧត្តមសិក្សា។ បុគ្គលិកធនាគារពិភពលោក ដែលបានចូលរួមសរសេរផ្នែកសំខាន់ៗជាច្រើនក្នុងសៀវភៅ កសាងសង្គមពុទ្ធិ (Constructing Knowledge Society 2002) និងក៏ជាអ្នកបានជួយរៀបចំគម្រោងនៅប្រទេសបង់ក្លាដែសផងដែរ បានសម្រេចថា គំរូមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់ ក៏មានភាពសាកសមសម្រាប់ប្រទេសកម្ពុជាផងដែរ។ លោកស្រី រួមដោយថ្នាក់ដឹកនាំមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់នៅការិយាល័យធនាគារពិភពលោកប្រចាំប្រទេសបង់ក្លាដែស គឺជាអ្នកឲ្យយោបយល់ក្នុងការរៀបចំចំណុចលម្អិតផ្នែកទី២នៃគម្រោងនៅប្រទេសកម្ពុជា និងក្រោយមកក្លាយជាអ្នកតាមដានត្រួតពិនិត្យការអនុវត្ត ទាំងគម្រោងមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់នៅប្រទេសបង់ក្លាដែស និងទាំងគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍នៅប្រទេសកម្ពុជា ក្នុងពេលតែមួយ។ គឺក្នុងន័យនេះហើយដែលវាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ដែលថាចក្ខុវិស័យគោលនយោបាយនៅកម្ពុជាគឺជាការចម្លងចេញពីគំរូនៅបង់ក្លាដែស បើទោះបីជាឈ្មោះត្រូវបានប្តូរពី **មូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់** មកជា **ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍** ក៏ដោយ។

ដូចជាករណីនៅបង់ក្លាដែសដែរ **ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍** បើកចំហសម្រាប់សាកលវិទ្យាល័យទាំងសាធារណៈ និងឯកជន ហើយបានដាក់ចេញនូវថវិកាចំណាយនៅក្រោមទម្រង់ពីរគឺ៖ "គាំទ្រការរៀន និងការបង្រៀន" (ប្រកទី១) និង "ដំណោះស្រាយបញ្ហាក្នុងស្រុក" (ប្រកទី២)។

---

[27] គួរកត់សម្គាល់ថា យើងមិនបានអះអាងថា គម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សានៅប្រទេសបង់ក្លាដែស ទទួលបាន "ជោគជ័យ" នោះទេ។ ទស្សនកិច្ចទៅប្រទេសបង់ក្លាដែស ដែលធ្វើឡើងដោយអ្នកនិពន្ធទី២ និងដែលទទួលការគាំទ្រដោយធនាគារពិភពលោក បានលើកឡើងពីវិបាកដែលគួរឲ្យបារម្ភជាច្រើន ទោះបីជាបញ្ហាទាំងនេះ មិនបានរំលេចនៅក្នុងកំណត់ហេតុផ្លូវការនៅក្នុងការិយាល័យធនាគារពិភពលោកក៏ដោយ (សូមមើល World Bank 2014)។ យើងគ្រាន់តែមានបំណងរំលេចពីរបៀបដែលធនាគារពិភពលោកយល់ពីបរិបទ គម្រោងដែលបានរៀបចំឡើងដែលហាក់ដូចជា "មានន័យជាង" បើប្រៀបធៀបជាមួយករណីប្រទេសកម្ពុជា។ ការស្រាវជ្រាវនាពេលអនាគត គួរផ្តោតលើគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សានៅប្រទេសបង់ក្លាដែស។ អ្នកពិនិត្យឲ្យយោបល់ឯករាជ្យម្នាក់មកលើអត្ថបទនេះបានចោទសួរថា វាប្រហែល "គ្រាន់តែជាសំណាង" ទេឬ ក្នុងករណីប្រទេសបង់ក្លាដែស ដែលថាគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សាហាក់មានន័យជាង។ វាគឺជាសំណួរដែលចាំបាច់ ប៉ុន្តែជាសំណួរមួយដែលយើងមិនអាចឆ្លើយបាន ប្រសិនបើយើងមិនមានការយល់ដឹងឲ្យបានស៊ីជម្រៅពីករណីប្រទេសបង់ក្លាដែស និងអំពីគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សានោះទេ។ នៅទីនេះ យើងព្យាយាមបញ្ចៀសការចម្លងប្រភេទនៃការគិតបែបនេះ ដូចដែលធ្លាប់បានធ្វើដោយធនាគារពិភពលោកធ្វើអំណះអំណាងអំពីបរិបទដោយផ្អែកលើបទពិសោធន៍នៃកន្លែងដទៃ ទោះបីជាយើងមានអារម្មណ៍ថា វាចាំបាច់ក្នុងការផ្តល់ជាគម្រោងត្រួសៗដែលបង្ហាញពីភាពខុសគ្នាជាមួយប្រទេសកម្ពុជាក៏ដោយ។ នៅពេលក្រោយមកទៀត សហការីជនជាតិបង់ក្លាដែសរបស់យើងម្នាក់បានផ្ញើអត្ថបទរបស់គាត់មកឲ្យពួកយើង។ អត្ថបទនេះក៏មានការរិះគន់ស្រដៀងគ្នា ដូចដែលយើងបានរិះគន់នៅទីនេះដែរ បើទោះបីជាវាពិនិត្យទៅលើករណីផ្សេងមួយទៀត ហើយមិនមែនជាករណីអប់រំក៏ដោយ (Mohammad Mizanur Rahman & Fahimul Quadir, 2018, The civil service's "fast food approach" to development policy-making in Bangladesh: critique and agenda for reform, Asian Pacific Journal of Public Administration, Vol 40(3), 159-174)។ ការណ៍នេះវាបានធ្វើឲ្យការសង្ស័យរបស់យើងកាន់តែច្បាស់ឡើងពីបទអន្តរាគមន៍ទាំងអស់របស់ធនាគារពិភពលោកថាមានលក្ខណៈស្រដៀងគ្នាទាំងអស់ ។

ចិរវេលានៃការអនុវត្តមានរយៈពេលយ៉ាងច្រើនបំផុត ២ឆ្នាំ សម្រាប់គម្រោងធំ និង១៨ខែ សម្រាប់គម្រោងតូច។ ការរៀបចំជុំបូងមានផែនការប្រកាសជ្រើសរើសគម្រោងស្រាវជ្រាវចំនួន៥០ នៅក្នុងជុំទី១ និង១០០ នៅក្នុងជុំទី២ (World Bank 2010) ដែលនេះឆ្លុះបញ្ចាំងនូវសន្ទុះនៃការកើនឡើងនៃកម្មវិធីនៅបង់ក្លាដែស។ គ្រឹះស្ថានឧត្តមសិក្សាអាចដាក់សំណើសុំហិរញ្ញប្បទានផ្ទាល់ទៅលើច្រកណាមួយក៏បាន និងប្រភេទណាមួយក៏បានក្នុងចំណោមប្រភេទទាំង ២៖ ប្រភេទ **ក** ថវិកា ៥០.០០០ ដុល្លារសហរដ្ឋអាមេរិក និងប្រភេទ **ខ** ថវិការហូតដល់ ២០០.០០០ ដុល្លារសហរដ្ឋអាមេរិក។

ក្នុងកម្រិតលម្អិតបែបនេះ គេឃើញមានកម្រិតខុសគ្នានៃចំនួនថវិកាពីគម្រោងអន្តរាគមន៍នៅបង់ក្លាដែស៖ ចំនួនថវិកាដែលខ្ពស់បំផុតមានចំនួន ៤ដង លើសពីករណីដែលមាននៅបង់ក្លាដែស។ ហិរញ្ញប្បទានទាំងនេះ ត្រូវបានបែងចែកទៅជា ៧០% សម្រាប់ប្រភេទ ក និង៣០% សម្រាប់ប្រភេទ ខ ហើយមានការប្រកាសជ្រើសរើសសំណើស្រាវជ្រាវ ២ ឬ ៣ដង ក្នុងអំឡុងរយៈពេល៥ឆ្នាំនៃការអនុវត្តគម្រោងនេះ (World Bank 2010, 7)។ ទោះបីជាយ៉ាងនេះក៏ដោយ ដូចក្នុងករណីប្រទេសបង់ក្លាដែសដែរ ចិរវេលានៃការអនុវត្តគម្រោងនេះមានរយៈពេលខ្លី៖ ក្នុងនោះយ៉ាងយូរបំផុតមានរយៈពេល២ឆ្នាំ សម្រាប់គម្រោងធំ ប្រភេទ ខ និង១៨ខែ សម្រាប់គម្រោងតូច ប្រភេទ ក។ ទោះបីនៅកម្ពុជា មិនទាន់មានគណៈកម្មការសាកលវិទ្យាល័យថ្នាក់ជាតិដូចនៅបង់ក្លាដែសក៏ដោយ ការរៀបចំរបស់ធនាគារពិភពលោក បានស្នើសុំឲ្យមានការបង្កើតគណៈកម្មាធិការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវនៅក្នុងនាយកដ្ឋានឧត្តមសិក្សារបស់ក្រសួងអប់រំឲ្យបានឆាប់បំផុត ដើម្បីគ្រប់គ្រងការអនុវត្តគម្រោង។ សមាជិកគណៈកម្មាធិការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវនេះ ត្រូវតែជាបុគ្គលិកកំពុងធ្វើការនៅក្នុងនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ប៉ុន្តែលក្ខខណ្ឌ ត្រូវបានធ្វើឡើងដើម្បីមានការបើកចំហក្នុងការជ្រើសរើសតតិយជនជាទីប្រឹក្សាក្នុងរយៈពេលកំណត់មួយរយៈពេលខ្លី មកជួយ/បំពេញការងារតាមតម្រូវការចាំបាច់។ នៅកម្រិតគ្រឹះស្ថានឧត្តមសិក្សា ដំណើរការនេះ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការហិរញ្ញប្បទានស្រាវជ្រាវប្រចាំសាកលវិទ្យាល័យដែលទើបបង្កើតថ្មី ដឹកនាំដោយសាកលវិទ្យាធិការ ឬប្រធានដេប៉ាតឺម៉ង់។ ចក្ខុវិស័យ គឺសុំឲ្យគណៈកម្មាធិការហិរញ្ញប្បទានស្រាវជ្រាវប្រចាំសាកលវិទ្យាល័យប្រកាសឲ្យមានការប្រកួតប្រជែងផ្ទៃក្នុង ដើម្បីជ្រើសរើសសំណើស្រាវជ្រាវណាដែលល្អ រួចបញ្ជូនមកគណៈកម្មាធិការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវនៅក្នុងនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ។ ប្រសិនបើត្រូវបានជ្រើសរើសក្នុងដំណាក់ដំបូងនេះ គណៈកម្មាធិការហិរញ្ញប្បទានស្រាវជ្រាវសាកលវិទ្យាល័យ នឹងជួយក្រុមអ្នកស្រាវជ្រាវឲ្យសរសេរគម្រោងស្រាវជ្រាវលម្អិត រួមទាំងការសរសេរឲ្យច្បាស់លាស់អំពីការចូលរួមចំណែករបស់សាកលវិទ្យាល័យក្នុងគម្រោងស្រាវជ្រាវនេះផងដែរ។ ថវិកាដែលសាកលវិទ្យាល័យត្រូវរួមចំណែក គឺយ៉ាងតិចបំផុតចំនួន៥%នៃចំនួនថវិកាស្នើសុំសរុប ប៉ុន្តែថវិកានេះ អាចត្រូវបានបង់ជាការរួមចំណែក មិនមែនជាសាច់ប្រាក់ (លុយ) (ដូចជា ការប្រើប្រាស់ទឹក ភ្លើង យានយន្ត និងថ្លៃប្រេងឥន្ធនៈជាដើម)។ លក្ខខណ្ឌទាំង៣នេះ រួមមានសំណើគម្រោងស្រាវជ្រាវ ការបង្កើតឲ្យមានគណៈកម្មាធិការហិរញ្ញប្បទានស្រាវជ្រាវប្រចាំសាកលវិទ្យាល័យ និងការចូលរួមចំណែកចំនួន៥% គឺជាតម្រូវការជាផ្លូវការសម្រាប់សាកលវិទ្យាល័យក្នុងការដាក់ពាក្យស្នើសុំ និងទទួលបានហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។

អ្នកដែលទទួលបានហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ (ហៅថា អនុគម្រោង) ការងារត្រូវចាប់ផ្តើមធ្វើភ្លាមៗ ដោយហេតុថា ចិរវេលាក្នុងការអនុវត្តមានរយៈពេលខ្លីពេកពី ១៨ ទៅ ២៤ខែ (ក្រោយមក ក្រុមអនុគម្រោងអាចស្នើសុំពន្យាពេលបានរយៈពេល៦ខែ ប្រសិនបើចាំបាច់)។ សាកលវិទ្យាល័យ នឹងទទួលបានទឹកប្រាក់ដំបូង៥% នៃចំនួនថវិកាស្នើសុំសរុប បន្ទាប់ពីបើកគណនីនៅធនាគារពាណិជ្ជកម្មរួចហើយ។ នេះគឺសម្រាប់ការចាប់ផ្តើមសកម្មភាព និងរដ្ឋទេយ្យ។ ថវិកាផ្សេងទៀត នឹងបើកជាបន្តបន្ទាប់ អាស្រ័យលើការបញ្ចប់

គម្រោងផែនការថវិកាលម្អិត និងមានការអនុម័តយល់ព្រម ពីគណៈកម្មាធិការគ្រប់គ្រងហិរញ្ញប្បទានស្រាវជ្រាវនៅក្នុងនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ហើយអ្វីដែលសំខាន់បំផុត គឺផែនការលទ្ធកម្ម។ ទោះបីជាថវិកា ត្រូវបានបញ្ជូនមកតាមក្រសួងអប់រំក៏ដោយ សៀវភៅណែនាំការអនុវត្តគម្រោងបានសង្កត់ធ្ងន់ថា លទ្ធកម្មត្រូវតែធ្វើឲ្យស្របតាមគោលការណ៍លទ្ធកម្មរបស់ធនាគារពិភពលោក (MoEYS-DHE 2011, 14)។

គោលការណ៍ក្រសួងដែលដើរតាមធនាគារពិភពលោកនេះ បានដាក់ចេញរបៀបរបបផ្សេងៗគ្នា យ៉ាងលម្អិតអំពីសេចក្តីត្រូវការដើម្បីបញ្ជាទិញទំនិញ ការសាងសង់ និងជួលទីប្រឹក្សាជាដើម។ល។ គ្រប់សំណើលទ្ធកម្មរបស់អនុគម្រោងទាំងអស់ត្រូវតែផ្ញើទៅកាន់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ដើម្បីត្រួតពិនិត្យ និងអនុម័តដោយយោងតាមទម្រង់ស្តង់ដារជាក់លាក់មួយ ប៉ុន្តែមុនពេលដែលថវិកាត្រូវបានបើកទៅឲ្យអនុគម្រោង នាយកដ្ឋានឧត្តមសិក្សាជាដំបូងត្រូវតែទទួលបាន **លិខិតមិនជំទាស់** (NOL – Non-Objection Letter) ពីធនាគារពិភពលោកសិន។ ក្នុងការធ្វើការងារនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវមានកាតព្វកិច្ច "តែងតាំងមនុស្សដែលមានគុណវុឌ្ឍិសមស្របយ៉ាងតិច២នាក់ ឲ្យធ្វើជាជនបង្គោលលើការងារលទ្ធកម្មនេះ និងត្រូវចូលរួមការបណ្តុះបណ្តាលពីទីប្រឹក្សាបរទេសដែលធ្វើការឲ្យគម្រោងនេះ" (MoEYS-DHE 2011)។

លើផ្នែកការគាំទ្របច្ចេកទេស (ការសិក្សាស្រាវជ្រាវជាន់ខ្ពស់) ចក្ខុវិស័យធនាគារពិភពលោក គឺថា នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ គឺជាអ្នកដែលដឹកនាំផ្ទាល់។ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ នឹងត្រូវ "តាមដានការអនុវត្តអនុគម្រោងជាប្រចាំ និងផ្តល់យោបល់ណែនាំលើសកម្មភាពអនុគម្រោង" (World Bank 2010)។ កត្តាលម្អិតមួយចំនួនទៀត នឹងរៀបរាប់នៅទីនេះ។ ហេតុអ្វីបានជាបែបនេះ? ប្រាកដណាស់នេះពីព្រោះតែដំណើរការពិនិត្យកែប្រែសំណើស្រាវជ្រាវត្រូវបានចាត់ទុកថា ជាធាតុចូលដ៏សំខាន់ និងចាំបាច់នៃការសិក្សាស្រាវជ្រាវជាន់ខ្ពស់ (ផ្នែកបច្ចេកទេស) តែមួយគត់របស់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ។ នៅពេលដែលក្រុមការងារនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ដែលត្រូវបានចាត់តាំងឲ្យពិនិត្យ និងអនុម័តលើសំណើគម្រោងស្រាវជ្រាវធ្វើការជ្រើសរើសសំណើ ដែលល្អបំផុតរួចហើយ ប្រធានក្រុមស្រាវជ្រាវនៅតាមសាកលវិទ្យាល័យត្រូវបានរំពឹងថា នឹងចាប់ផ្តើមស្វ័យគ្រប់គ្រងការអនុវត្តអនុគម្រោងស្រាវជ្រាវរបស់ខ្លួនដោយផ្ទាល់។ នៅប្រទេសបង់ក្លាដែស ការអនុវត្ត គឺផ្តោតតែលើការទទួលបានធនធានសម្ភារ នេះមានន័យថា ភ្នាក់ងារគ្រប់គ្រងហិរញ្ញប្បទានថ្នាក់ជាតិ - គណៈកម្មការសាកលវិទ្យាល័យបង់ក្លាដែស - មានតួនាទីតិចតួចណាស់ លើសពីការបើកថវិកាចាំបាច់ទៅឲ្យអនុគម្រោង និងការតាមដាន "របាយការណ៍វឌ្ឍនភាព" ប្រចាំត្រីមាស។ គំនិតគឺថា នៅប្រទេសកម្ពុជាក៏មានទម្រង់ដូចគ្នាដែរ អនុគម្រោងក៏នឹងស្វ័យដំណើរការនៅពេលដែលនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ជ្រើសរើសសំណើគម្រោងស្រាវជ្រាវដែលល្អបានហើយ។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១០ ការប្រកាសជ្រើសរើសជុំទី១ នៃហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ត្រូវបានធ្វើឡើង និងបិទបញ្ចប់ដោយនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំតាមផែនការខាងលើនេះ ហើយការងារជាក់ស្តែងត្រូវចាប់ផ្តើមដោយគ្រឹះស្ថានឧត្តមសិក្សានៅខែមករា ឆ្នាំ២០១១។ នេះគឺជាលើកទី១ ដែលថវិកាស្រាវជ្រាវពីរដ្ឋាភិបាលត្រូវបានផ្តល់ទៅឲ្យសាកលវិទ្យាល័យនៅកម្ពុជា។ ធនាគារពិភពលោកលើកឡើងថា នេះគឺជាសករាជថ្មីដែលគួរឲ្យមានមោទនភាពសម្រាប់ឧត្តមសិក្សានៅកម្ពុជា ជាជំហានទី១សម្រាប់កម្ពុជាក្នុងដំណើរឈានចូលទៅក្នុងសេដ្ឋកិច្ចពុទ្ធិសាកលថ្មី។

### ❖ គោលនយោបាយដែលបរាជ័យ៖ បណ្ឌិតលទ្ធកម្ម បរិបទ និងការបន្ទោស

បញ្ហារបស់គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍កើតមានយ៉ាងច្បាស់តាំងពីចាប់ផ្តើមដំបូងមកម្លេះ។ បញ្ហារដ្ឋបាលការងារតូចៗជាច្រើនបានកើតឡើង ដូចដែលកើតមាននៅក្នុងគម្រោងថ្មីៗផ្សេងៗទៀតដែរ។ ប៉ុន្តែ ទាំងនេះ

មិនមែនជាអ្វី ដែលជាការផ្តោតការយកចិត្តទុកដាក់របស់យើងនៅទីនេះទេ។ ផ្ទុយទៅវិញ យើងនឹងវិភាគប្រកបដោយការរិះគន់ទៅលើបញ្ហាដែលកើតចេញពីឫសគល់ដែលជ្រៅជាងនេះ គឺភាពមិនស៊ីគ្នារវាងចក្ខុវិស័យគោលនយោបាយរបស់ធនាគារពិភពលោក ការសន្មតរបស់ធនាគារពិភពលោកអំពីបរិបទ និងបរិបទនៅកម្ពុជាជាក់ស្តែង។ ដើម្បីឲ្យខ្លី និងចំគោលដៅ យើងកម្រិតការវិភាគរបស់យើងលើបញ្ហា *បណ្ឌិត* និង *លទ្ធកម្ម* នេះពីព្រោះតែបញ្ហាទាំងពីរនេះបំភ្លឺទឡ្ហីករណ៍ទូលំទូលាយរបស់យើងអំពីអន្តរទំនាក់ទំនងរវាង "បរិបទ"[28] បរិបទ[29] និងការបន្ទោស។ ប្រសិនបើមានទំព័របន្ថែម យើងអាចរៀបរាប់បញ្ហាចម្បង៣ ទៅ ៤ទៀត ដើម្បីគាំទ្រគម្រោងការបញ្ញត្តិកម្មទូទៅដែលយើងពិពណ៌នាខាងលើ ប៉ុន្តែយើងត្រូវតែទុកបញ្ហាទាំងនេះ សម្រាប់ការងារនាពេលអនាគត។

### ក. បរាជ័យទី១ ៖ កង្វះបណ្ឌិត

២ខែបន្ទាប់ពីការប្រកាសជ្រើសរើសសំណើស្រាវជ្រាវដំបូងដែលបានធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១០ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ បានជួបប្រទះបញ្ហាធំ១ គឺចំណាប់អារម្មណ៍ជាទូទៅនៅតាមគ្រឹះស្ថានឧត្តមសិក្សាមានកម្រិតទាប និងមានសំណើស្រាវជ្រាវតិចតួចប៉ុណ្ណោះ ដែលបានផ្ញើមកនាយកដ្ឋានឧត្តមសិក្សា។ តាមពិតទៅ នាយកដ្ឋានឧត្តមសិក្សាបានទទួលសំណើស្រាវជ្រាវតែបួន-ដប់ប៉ុណ្ណោះនៅចុងខែតុលា ឆ្នាំ២០១០ ហើយគុណភាពសំណើ ត្រូវបានចាត់ទុកថា មានកម្រិតទាប ដោយគម្រោងភាគច្រើន គឺគ្រាន់តែជាយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីបម្រែបម្រួលអាកាសធាតុ ឬជាការបង្កើតស្រះចិញ្ចឹមត្រីថ្មី (វារីវប្បកម្ម) នៅក្នុងភូមិជនបទក្រីក្រចំនួន១០០ ដើម្បីបង្កើនបរិមាណកាឡូរីទទួលបន្ថែម។ សំណើសុំ មិនមែនជាគម្រោងស្រាវជ្រាវទេ ប៉ុន្តែគ្រាន់តែជាគម្រោងអនុវត្តបែបអភិវឌ្ឍន៍ដែលមានលក្ខណៈ "ក្លាស៊ិក"។ វាហាក់ដូចជាគ្រឹះស្ថានឧត្តមសិក្សាយល់ច្រលំពីគោលបំណងនៃកម្មវិធីនេះ។ ជាដំបូង វាហាក់ដូចជាមានជំហរថា ដោយសារតែលទ្ធផលនៃការប្រាប់ឲ្យធ្វើអ្វីៗដោយភ្នាក់ងារអភិវឌ្ឍបរទេសជាច្រើនឆ្នាំ ទើបអ្នកស្រាវជ្រាវហាក់ដូចជាមិនហ៊ាន "គិតដោយខ្លួនឯង" ទេ។ ដោយមានការតាមដានពិគ្រោះយោបល់បន្តនៅតាមសាកលវិទ្យាល័យ បញ្ហាដែលត្រូវទទួលស្គាល់គឺថា មានសភាពធ្ងន់ធ្ងរជាងនេះទៅទៀត គឺមានគ្រឹះស្ថានឧត្តមសិក្សាតិចតួចណាស់ ដែលមានការយល់ដឹងអំពីការស្រាវជ្រាវ មិនចាំបាច់និយាយដល់ការបង្កើតគម្រោងស្រាវជ្រាវច្រើនឆ្នាំដែលមានចំនួនទឹកប្រាក់ច្រើន (ចំនួន ៥០.០០០ ដុល្លារសហរដ្ឋអាមេរិក គឺជាចំនួនដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់ប្រទេសក្រីក្រ ដូចកម្ពុជា)។

ហេតុនេះ ក្រសួងអប់រំ ប្រញាប់ប្រញាល់បើកវគ្គសិក្ខាសាលាដើម្បីពន្យល់អំពីអ្វីជាការស្រាវជ្រាវ និងអំពីរបៀបសរសេរសំណើគម្រោងស្រាវជ្រាវ និងតាមរយៈដំណើរការនេះ បង្កើតជាសំណើស្រាវជ្រាវ "ដែលអាចធ្វើទៅរួច"។ ដើម្បីធ្វើដូច្នេះបាន នាយកដ្ឋានឧត្តមសិក្សា តាមការស្នើសុំពីធនាគារពិភពលោក បានអញ្ជើញអ្នកស្រាវជ្រាវជាន់ខ្ពស់ ពីសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក ដែលធ្លាប់មានភាពជោគជ័យក្នុងការសរសេរសំណើគម្រោងស្រាវជ្រាវ។ ជាអកុសល ទីប្រឹក្សាអាមេរិកទាំងនេះ មិនធ្លាប់មកកម្ពុជាសោះ ហើយក៏មិនមានការស្វែងយល់ពាក់ព័ន្ធនឹងការបារម្ភរបស់អ្នកចូលរួមនៅក្នុងសិក្ខាសាលាទាំងនេះទាល់តែសោះ៖ ពួកគេផ្តោតលើការសរសេរសំណើគម្រោងស្រាវជ្រាវ ដើម្បីទទួលបានហិរញ្ញប្បទានរាប់លានដុល្លារពីស្ថាប័នដែលមានទីតាំងនៅសហរដ្ឋអាមេរិក ដូចជាមូលនិធិវិទ្យាសាស្ត្រជាតិ (National Science Foundation) និងមូលនិធិបៀល & មេលីនដា (Bill & Melinda Foundation)។ អ្នកចូលរួមកាន់តែមានអារម្មណ៍ច្របូកច្របល់ ដោយសារពួកគាត់និយាយពីអ្វីដែលចម្លែក ហើយលើសពីនេះ សិក្ខាសាលាទាំងនេះ សុទ្ធបានធ្វើជាភាសាអង់គ្លេស។

---

[28] "បរិបទ" ដូចដែលធនាគារពិភពលោកយល់ និងកំណត់។

[29] បរិបទ គឺជាតថភាព ជាអ្វីដែលកើតមានឡើងក្នុងប្រទេសកម្ពុជា។

បន្ទាប់មក សិក្ខាសាលាសាមញ្ញជាងនេះ ត្រូវបានរៀបចំឡើងដោយប្រធានទីប្រឹក្សាបច្ចេកទេស ប្រចាំនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ជាជនជាតិអូស្ត្រាលីដែលធ្លាប់ធ្វើការនៅសាកលវិទ្យាល័យនៅប្រទេសអូស្ត្រាលី។ សិក្ខាសាលានេះផ្តោតលើការពន្យល់បញ្ហាជាមូលដ្ឋាន ដូចជា ការបំពេញទម្រង់ស្នើសុំហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ជាភាសាអង់គ្លេស។ នោះ គឺអ្វីដែលគ្រឹះស្ថានឧត្តមសិក្សាត្រូវសរសេរក្នុងបែបបទសំណើសុំដែលជាទម្រង់ស្តង់ដារ ជាឧទាហរណ៍ "សង្ខេបពីវិធីសាស្ត្រស្រាវជ្រាវ លទ្ធផលសកម្មភាព លទ្ធផលនៃការស្រាវជ្រាវដែលគម្រោងនឹងធ្វើបាន (យ៉ាងច្រើនបំផុត ៣៥០ពាក្យ)"។ បច្ចេកសព្ទ "លទ្ធផលសកម្មភាព" និង "លទ្ធផលនៃការស្រាវជ្រាវ" ដូចដែលយើងធ្លាប់បានអង្កេត គឺខ្ចីពីក្របខណ្ឌចង្វាក់ជាសាកលរបស់ធនាគារពិភពលោក ដែលប៉ុនប៉ងបង្កើតឡើងសម្រាប់ភាពងាយស្រួលក្នុងការតាមដាន និងធ្វើរបាយការណ៍មកឲ្យបុគ្គលិកការិយាល័យធនាគារពិភពលោកនៅកម្ពុជា នៅក្រោយពេលអនុវត្តគម្រោងចប់។

ទោះបីជាមានការប្រឹងប្រែងយ៉ាងខ្លាំងក្លាបែបនេះក៏ដោយ ក៏នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ទទួលបានសំណើស្រាវជ្រាវដំបូងមិនដល់ ៦០គម្រោងផង។ លើសពីនេះទៀត ទោះជានៅក្នុងអំឡុងពេលនោះ កម្ពុជា មានសាកលវិទ្យាល័យចំនួន៩៧ ក៏ដោយ សំណើស្រាវជ្រាវទាំងនេះ គឺចេញតែពីសាកលវិទ្យាល័យចំនួន២២ប៉ុណ្ណោះ ដែលក្នុងនោះមានសាកលវិទ្យាល័យសាធារណៈចំនួន១២ និងសាកលវិទ្យាល័យឯកជនចំនួន១០។ សាកលវិទ្យាល័យសាធារណៈ ផ្ញើសំណើគម្រោងស្រាវជ្រាវបានចំនួន៤៧ ដែលភាគច្រើនបំផុតចេញតែមកពីមហាវិទ្យាល័យ៣-៤ នៃសាកលវិទ្យាល័យឈានមុខគេនៅកម្ពុជា ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យជាតិគ្រប់គ្រង។ សាកលវិទ្យាល័យទាំងនេះមានទីតាំងនៅទីក្រុងភ្នំពេញ។ ដើម្បីឲ្យស្របនឹងអាទិភាពនៃគោលនយោបាយវិមជ្ឈការ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ បានបង្កើតឲ្យមានប្រព័ន្ធកូតាដែលតម្រូវឲ្យផ្តល់គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍យ៉ាងតិចបំផុតចំនួន២៥% ដល់គ្រឹះស្ថានឧត្តមសិក្សាដែលមានទីតាំងនៅក្រៅក្រុងភ្នំពេញ។ នៅក្នុងន័យនេះ សំណើស្រាវជ្រាវ ផ្ញើដោយគ្រឹះស្ថានឧត្តមសិក្សាទាំងនេះ ដែលមានទីតាំងនៅតាមខេត្ត គឺត្រូវទទួលទាំងអស់ដោយមិនគិតពីគុណភាពនៃសំណើស្រាវជ្រាវឡើយ។ ជាយថាហេតុ សំណើគម្រោងស្រាវជ្រាវចំនួន៣១ ត្រូវបានជ្រើសរើសនៅជុំទី១។ តួរលេខនេះ នៅក្រោមការគ្រោងទុកឆ្ងាយណាស់លើចំនួន៥០ ដែលបានដាក់ក្នុងផែនការដំបូងរបស់ធនាគារពិភពលោក។ អ្នកអានដែលចាប់អារម្មណ៍ចង់ដឹងស៊ីជម្រៅ អាចស្វែងរកបញ្ជីឈ្មោះគម្រោងទាំងនេះបានដោយងាយតាមរយៈការបោះពុម្ពរបស់ក្រសួងអប់រំ ក្រោមចំណងជើងថា ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍៖ របាយការណ៍អំពីអ្វីដែលបានធ្វើកន្លងមកក្នុងខែមិថុនា ឆ្នាំ២០១៥ (*Development and Innovation Grants, Stocktaking Report 2015* តាមរយៈវេបសាយរបស់ក្រសួងអប់រំ[30] )។

អ្វីដែលគួរឲ្យអន់ចិត្តជាងនេះទៅទៀតនោះគឺថា ទោះបីជាមានការបន្តរៀបចំសិក្ខាសាលាដូចបានរៀបរាប់ខាងលើ និងការផ្សព្វផ្សាយស្វែងរកសំណើស្រាវជ្រាវតាមរយៈសារព័ត៌មាន នៅក្នុងឆ្នាំទី២នៃការអនុវត្តគម្រោង ចំនួនសំណើស្រាវជ្រាវដំបូងដែលបានដាក់មកក្រសួងអប់រំបានធ្លាក់ចុះមកនៅត្រឹមចំនួន ៣០ និងផ្ញើមកពីសាកលវិទ្យាល័យចំនួនតែ១៩ ប៉ុណ្ណោះ។ អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៅទៀត គឺគុណភាពនៃសំណើស្រាវជ្រាវក្នុងជុំទី២ នេះមានកម្រិតទាបមែនទែន ដែលចុងក្រោយបំផុត មានតែគម្រោងសំណើស្រាវជ្រាវចំនួន១៤ ដែលផ្ញើមកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន១៣ (១០ មានទីតាំងនៅទីក្រុងភ្នំពេញ និង៣មានទីតាំងនៅតាមខេត្ត) បានទទួលហិរញ្ញប្បទាន។ តួរលេខនេះ រឹតតែនៅក្រោមការគ្រោងទុក

[30] របាយការណ៍ទាំងស្រុងអាចទាញយកបានតាមរយៈ៖ https://www.academia.edu/27353153/Development_and_Innovation_Grants_Stocktaking_Report_Cambodia_2015។

ឆ្ងាយថែមទៀតពីចំនួន១០០ ដែលបានដាក់នៅក្នុងផែនការដំបូងរបស់ធនាគារពិភពលោកក្នុងឆ្នាំទី២។ ធនាគារពិភពលោកមានការរំពឹងទុកពីវឌ្ឍនភាព និងការកើនឡើងនៃចំនួនគម្រោងសំណើស្រាវជ្រាវ ប៉ុន្តែតថភាពជាក់ស្តែង គឺផ្ទុយពីនេះ។

ម្នាក់ៗអាចស្រមៃថា ទោះបីជាត្រូវបានបង្ខំឲ្យសម្រេចផ្តល់ហិរញ្ញប្បទានដល់គម្រោងសំណើស្រាវជ្រាវក្នុងកម្រិតក្រោមស្តង់ដារក៏ដោយ ក៏នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ គួរតែត្រូវបានចាត់វិធានការបន្ថែមក្នុងការដាក់ដំណើរការអនុវត្តគម្រោងនៅលើមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវ ដែលមានភាពរឹងមាំជាងនេះ។ ហេតុអ្វីបានជាក្រសួងអប់រំបរាជ័យក្នុងការធ្វើសកម្មភាពបែបនេះ គឺជាចំណុចដែលត្រូវពិនិត្យមើលពីការមិនអាចតភ្ជាប់គ្នាជាទូទៅរវាងចក្ខុវិស័យគោលនយោបាយរបស់ធនាគារពិភពលោក និងបរិបទនៅកម្ពុជា។ មើលឃើញដោយសាមញ្ញបំផុត គឺមានអ្នកដែលមានសញ្ញាបត្របណ្ឌិតតិចតួចណាស់នៅកម្ពុជា មិនថានៅសាកលវិទ្យាល័យ ឬក៏នៅក្នុងក្រសួងអប់រំខ្លួនឯង។ នៅក្នុង(អគ្គ)នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ អ្នកមានសញ្ញាបត្របណ្ឌិតមានតែម្នាក់គត់។ គាត់ គឺជាប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ប៉ុន្តែត្រូវបានធនាគារពិភពលោក វិនិច្ឆ័យភ្លាមថា មិនមានសមត្ថភាពក្នុងការគ្រប់គ្រងចាត់ចែងការងារនេះទេ (ព្រោះតែការស្រាវជ្រាវរបស់គាត់មានលក្ខណៈទ្រឹស្តីពេក) ហេតុនេះមិនត្រូវបានអញ្ជើញឲ្យដើរតួនាទីណាមួយទេ ក្នុងដំណើរការអនុវត្តន៍គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា[31]។ មួយឆ្នាំក្រោយមក អ្នកមានសញ្ញាបត្រវ័យក្មេងម្នាក់មកពីសាកលវិទ្យាល័យឈានមុខគេមួយនៅកម្ពុជា ត្រូវបានស្នើសុំឲ្យមកគ្រប់គ្រង និងចាត់ចែងដឹកនាំផ្នែកទី១ និងផ្នែកទី២ នៃគម្រោង រហូតដល់មានអ្នកចូលមកធ្វើការពេញម៉ោងសម្រាប់គ្រប់គ្រង និងចាត់ចែងដឹកនាំគម្រោងហិរញ្ញប្បទានការស្រាវជ្រាវ និងនវានុវត្តន៍ អ្នកដែលគេរំពឹងថានឹងមកកាន់តួនាទីនេះ គឺជាអ្នកដែលមានសញ្ញាបត្របណ្ឌិត និងមានចំណេះដឹងអំពីការស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យ។ ក្រោយមកនៅក្នុងឆ្នាំ២០១៣ អ្នកនិពន្ធទី២ ត្រូវបានហៅឲ្យមកកាន់ការងារនេះ គឺរយៈពេល ៣ឆ្នាំក្រោយ គម្រោងបានចាប់ផ្តើមជាផ្លូវការ។

នៅឯសាកលវិទ្យាល័យវិញ ស្ថានភាព គឺគ្រាន់បើជាងនេះតែបន្តិចប៉ុណ្ណោះ។ សាកលវិទ្យាល័យមួយចំនួន ពុំមានអ្នកមានសញ្ញាបត្របណ្ឌិតសូម្បីតែម្នាក់ នៅក្នុងមហាវិទ្យាល័យរបស់ខ្លួនតែម្តង។ អ្នកទាំងឡាយណាដែលមានសញ្ញាបត្របណ្ឌិតត្រូវបានដំឡើងឋានៈជាព្រឹទ្ធបុរស ឬជាសាកលវិទ្យាធិការរង។ ការសម្លឹងមើលគ្រឹះស្ថានឧត្តមសិក្សាដែលល្បីជាងគេ នឹងបង្ហាញឲ្យឃើញពីស្ថានភាពនេះ។ នៅពេលដែលគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សាកំពុងត្រូវបានរៀបចំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលទទួលបានគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ចំនួន៦ មានបណ្ឌិតចំនួនតែ ១១នាក់ប៉ុណ្ណោះ ក្នុងចំណោមបុគ្គលិកបង្រៀនជិត៣០០នាក់ (Development Research Forum in Cambodia 2010) គឺនៅក្រោម៤% បន្តិច។ លើសពីនេះទៅទៀត ក្នុងចំណោមបណ្ឌិតទាំងនេះ ក៏មានជនជាតិបរទេស២ ឬ ៣នាក់ផងដែរ ពួកគាត់មួយចំនួនបានបោះបង់ចោលការងារ នៅស្រុកកំណើតរួចព្យាយាមមកជួយដល់ការអភិវឌ្ឍនៅកម្ពុជា។ ក្រោយមក នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ បានធ្វើការប៉ាន់ស្មានក្រៅផ្លូវការមួយថា ជិត ៥០%នៃសំណើស្រាវជ្រាវក្នុងគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ គឺសរសេរដោយជនជាតិបរទេសដែលធ្វើការនៅក្នុង ឬមានទំនាក់ទំនងជាមួយនឹងសាកលវិទ្យាល័យទាំងនោះ (យ៉ាងហោចណាស់ក្នុងនោះ មានសំណើ

[31] នៅក្រោយមក ក្នុងឆ្នាំ២០១៩ តួនាទីរបស់គាត់ត្រូវបានជំនួសដោយបណ្ឌិតវ័យក្មេងម្នាក់មកពីសាកលវិទ្យាល័យល្បីល្បាញនៅអាស៊ីបូព៌ាដែលមានជំនាញ និងបទពិសោធន៍ខាងអប់រំ ជាពិសេសធ្លាប់បង្រៀននៅមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យឈានមុខគេមួយនៅកម្ពុជា និងធ្លាប់ជាទីប្រឹក្សាជាន់ខ្ពស់ផ្នែកអប់រំក្នុងគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍។ វាគួរឲ្យកត់សម្គាល់ផងដែរថា នៅពេលអនុវត្តគម្រោងលើកទី២ "គម្រោងកែលម្អការអប់រំឧត្តមសិក្សា២០១៨-២០២៤" ដែលមានទឹកប្រាក់៩២,៥ លានដុល្លាសហរដ្ឋអាមេរិច (៩០ លានជាកម្ចីពីធនាគាពិភពលោក និង២,៥ ជាថវិកាបដិភាគរបស់រដ្ឋាភិបាលកម្ពុជា) ដោយសារតែបទពិសោធន៍ការងារក្នុងវិស័យអប់រំ ជាពិសេសនៅកម្រិតសាកលវិទ្យាល័យ និងជាមួយដៃគូអភិវឌ្ឍន៍ បណ្ឌិតវ័យក្មេងម្នាក់នេះត្រូវបានហៅឲ្យចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងនេះ។

ស្រាវជ្រាវចំនួន៣ ដែលត្រូវបានផ្ញើទៅក្រៅប្រទេស និងសរសេរទាំងស្រុងដោយជនជាតិបរទេសដែលជាមិត្តភក្តិ ឬសហការីបរទេសរួចផ្ញើត្រឡប់មកវិញ និងដាក់ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ)។

ផលប៉ះពាល់នៃកង្វះខាតបណ្ឌិត ដើម្បីអនុវត្តគម្រោងឲ្យបានជោគជ័យមិនអាចត្រូវបានមើលរំលងនោះទេ។ ដោយគ្មានការបណ្តុះបណ្តាលការស្រាវជ្រាវជាន់ខ្ពស់សម្រាប់ថ្នាក់បណ្ឌិត សំណើស្រាវជ្រាវដំបូងនៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ គឺមានគុណភាពទាបមែនទែន។ លើសពីនេះ ដោយគ្មានបណ្ឌិតនៅក្នុងនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ដើម្បីពិនិត្យតាមដាន គ្រប់គ្រង និងក្រោយមកគាំទ្រសាកលវិទ្យាល័យ សំណើស្រាវជ្រាវដែលមានគុណភាពទាបទាំងនោះ នៅតែត្រូវបានជ្រើសរើស និងទទួលបានហិរញ្ញប្បទាន។ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងធនាគារពិភពលោក បានគាំទ្រឲ្យមានការបណ្តុះបណ្តាលដោយប្រើប្រាស់ទីប្រឹក្សាបរទេស (ដូចជាអ្នកនិពន្ធទី១) តែការណ៍នេះមិនបានជួយអ្វីធំដុំនោះទេ នេះមិនមែនមកពីពួកគេមិនស៊ាំនឹងស្ថានភាពនៅកម្ពុជា ឬដោយសារតែការបង្រៀនធ្វើឡើងជាភាសាអង់គ្លេសនោះទេ គឺព្រោះតែវាមិនអាចទៅរួចក្នុងការបង្រៀន "ពីរបៀបស្រាវជ្រាវ" ក្នុងវគ្គខ្លីៗរយៈពេល ២ ឬ ៣ សប្តាហ៍នោះទេ។ ដើម្បីទទួលបានសញ្ញាបត្របណ្ឌិតយ៉ាងហោចណាស់ក៏ត្រូវការពេលសិក្សាពេញម៉ោងយ៉ាងតិច ៣ ទៅ ៤ឆ្នាំ ហើយដើម្បីគ្រប់គ្រងគម្រោង ដែលមានទឹកប្រាក់ពី៥០.០០០ ទៅ ២០០.០០០ ដុល្លារសហរដ្ឋអាមេរិក ដាច់ខាតត្រូវមានជំនាញស្រាវជ្រាវ និងគ្រប់គ្រងច្បាស់លាស់ណាស់។

កង្វះការយល់ដឹងអំពីការស្រាវជ្រាវ នៅក្នុងចំណោមបុគ្គលិកសាកលវិទ្យាល័យនេះ គឺរឹតតែឃើញច្បាស់ក្រឡែតទៅទៀតនៅក្នុងផែនការអនុវត្តថវិកាដែលពួកគេបានស្នើនៅក្នុងសំណើស្រាវជ្រាវសម្រាប់គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍៖ ថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា កម្រៃបែងចែកថវិកាសម្រាប់ទីប្រឹក្សា ដើម្បីជួយពួកគេឲ្យមានការយល់ដឹងពី "ការស្រាវជ្រាវ" ណាស់។ *ពួកគេមិនដឹងពីអ្វីដែលពួកគេមិនដឹង*នោះទេ។ ការពិត ដោយគ្មានអ្នកដែលមានសញ្ញាបត្របណ្ឌិត និងមានចក្ខុវិស័យឆ្ពោះទៅមុខមកដឹកនាំអនុគម្រោងទាំងនេះទេ ចក្ខុវិស័យគោលនយោបាយ ដែលនាំចូលទាំងស្រុងពីបង់ក្លាដែសនេះនឹងមិនដំណើរការទេ។ អ្នកស្រាវជ្រាវកម្ពុជាមិនប្រាកដអំពីអ្វីដែលពួកគេកំពុង "ស្រាវជ្រាវ" នោះទេ ហើយមានតិចតួចណាស់ ដែលយល់ដឹងពីឧបករណ៍ពិសោធន៍ដែលពួកគេត្រូវការ (ឧទាហរណ៍ អ្វីដែលពួកគេមិនមាន) ឬសៀវភៅ/ធនធានអ្វីដែលមាននៅក្នុងស្រុក ឬក្រៅប្រទេសដែលអាចជួយពួកគេបាន។ ជួនកាល ពួកគេមិនទាំងដឹងផងថា សំណួរស្រាវជ្រាវអ្វីដែលពួកគេកំពុងស្រាវជ្រាវនោះ សូមកុំនិយាយដល់ភាពចាំបាច់ក្នុងកម្រិតសាកលលោក ឬការស្រាវជ្រាវដែលរំពឹងថានឹងរួមចំណែកដល់ "នវានុវត្តន៍"។

ផ្ទុយទៅវិញ អនុគម្រោងភាគច្រើន បានស្នើគម្រោងចំណាយថវិការបស់ខ្លួនទៅលើ ១) ទស្សនកិច្ចសិក្សាក្រៅប្រទេសដើម្បីរៀនសូត្រពីគម្រោង ឬកម្មវិធីប្រហាក់ប្រហែលគ្នាជាមួយគម្រោងរបស់ពួកគេនៅប្រទេសជិតខាង ឬ ២) ទិញឧបករណ៍ដែលអនុញ្ញាតឲ្យពួកគេបង្កើតគម្រោងអភិវឌ្ឍន៍ដែលមានលក្ខណៈ "នវានុវត្តន៍" ណាមួយក្នុងសហគមន៍ (ឧទាហរណ៍ ទិញសម្ភារបង្កើតអាងចិញ្ចឹមត្រីនៅភូមិជនបទ (វារីវប្បកម្ម) ទិញឧបករណ៍ដំឡើងរោងសម្រាប់ស្តុកទុក ឬចម្រាញ់ដំឡូងមី)។ ក្នុងន័យម្យ៉ាងទៀត គេមិនឃើញមានការស្រាវជ្រាវពិតប្រាកដណាមួយទេ កុំថាឡើយនិយាយដល់ "នវានុវត្តន៍"។ ជាអកុសល អ្នកជំនាញលទ្ធកម្ម និងហិរញ្ញវត្ថុខ្លះនៅ ធនាគារពិភពលោក ប្រញាប់ប្រញាល់វាយតម្លៃសំណើប្រើប្រាស់ថវិកាបែបនេះថា ជាគម្រោងការពុករលួយដែលមានជំនាញ (ពួកគេគ្រាន់តែព្យាយាមប្រើប្រាស់ថវិកាដើម្បីធ្វើដំណើរទៅក្រៅប្រទេស) ប៉ុន្តែអ្នកដឹកនាំគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ជាច្រើនគិតយ៉ាងត្រឹមត្រូវថា នេះគឺអ្វីដែលហៅថាជា "ការស្រាវជ្រាវ"។ លើសពីបុព្វហេតុទោលដទៃទៀតទាំងអស់ បរាជ័យនៃគ្រប់ទិដ្ឋភាពទាំងអស់របស់គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ មានឫសគល់ចេញពីកង្វះបណ្ឌិតនៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។

ប៉ុន្តែអ្វីទៅនាំឲ្យមានកង្វះបណ្ឌិតនៅក្នុងសាកលវិទ្យាល័យនៅកម្ពុជា? តើហេតុអ្វី បានជាធនាគារពិភពលោកមិនយល់ពីបរិបទនេះយ៉ាងដូច្នេះ? អ្នកអានភាគច្រើនប្រហែលជាដាក់ការសង្ស័យរួចហើយ ទៅលើការសម្លាប់បញ្ញវន្តខ្លួនឯងនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) គឺជាកត្តាចម្បងបំផុតដែលមិនអាចប្រកែកបាន។ ដើម្បីឲ្យប្រាកដ មានកត្តាជាច្រើនទៀត ដែលប្រទេសដែលមានប្រាក់ចំណូលទាប និងធ្លាប់ស្ថិតក្រោមអាណានិគមនិយមកំពុងប្រឈម ដូចជា កង្វះឧត្តមភាពខាងភាសា ភាពតឹងរ៉ឹងនៃលក្ខខណ្ឌចូលសាកលវិទ្យាល័យនៅបរទេស កង្វះថវិកា និងពេលវេលា កាលានុវត្តភាពនៅក្នុងស្រុកមានតិចតួច ប៉ុន្តែទាំងនេះ វាមិនសំខាន់ដូចជា ប្រវត្តិសាស្ត្រកម្ពុជានោះទេ។ តាំងពីដំបូងមកម្ល៉េះ អាជ្ញាធរអាណានិគមនិយមបារាំង មិនបានវិនិយោគលើវិស័យអប់រំនៅកម្ពុជាឲ្យបានហ្មត់ចត់នោះទេ (រួមទាំងឧត្តមសិក្សាផងដែរ)។ ក្រោយទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ សាកលវិទ្យាល័យទំនើប ៣ ឬ៤ បានកើតឡើង ហើយដែលល្បីជាងគេបំផុតនោះគឺសាកលវិទ្យាល័យភូមិន្ទខ្មែរ ក្នុងឆ្នាំ១៩៦០ (បច្ចុប្បន្ន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)។ អត្រាចុះឈ្មោះចូលរៀននៅឧត្តមសិក្សាបានកើនឡើង ហើយកូនសិស្សបានព្យាយាមស្វែងរកសញ្ញាបត្រជាន់ខ្ពស់ទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ប៉ុន្តែនៅពេលដែលខ្មែរក្រហមវាយចូលដល់ទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ គ្រប់សាលារៀន និងសាកលវិទ្យាល័យទាំងអស់ត្រូវបានបិទទ្វារ ឬត្រូវបានបំផ្លាញទាំងស្រុង។ ប្រជាជនទាំងអស់ត្រូវបានជម្លៀសឲ្យទៅកាន់ទីជនបទ និងត្រូវឲ្យទៅ "រៀនសូត្រឡើងវិញ"[32]។ អ្នកដែលបានទទួលការអប់រំពីមុនគឺជាសត្រូវរបស់ *អង្គការ* និងជាគោលដៅចម្បងដែលត្រូវកម្ចាត់ចោល។ អ្នករៀនបានកាន់តែខ្ពស់ កាន់តែត្រូវបានគេសង្ស័យខ្លាំងឡើង។ ការស្រាវជ្រាវមួយបានបង្ហាញថា ៧៥% នៃគ្រូបង្រៀន ៩៦% នៃនិស្សិតសាកលវិទ្យាល័យ និង ៦៧% នៃកូនសិស្សបឋមសិក្សា និងមធ្យមសិក្សាត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម (Ayres 2000)។ សាស្ត្រាចារ្យសាកលវិទ្យាល័យ និងអ្នកមានសញ្ញាបត្រខ្ពស់ ឬមានបទពិសោធន៍ពីបរទេសបានស្លាប់យ៉ាងច្រើនក្នុងរបបនេះ។

ទោះបីជាគ្រប់គ្រងប្រទេសតិចជាង៤ឆ្នាំក៏ដោយ របបគ្រប់គ្រងមួយនេះ គឺជា "យុគនៃការប្រែប្រួលសង្គមមួយដែលមិនអាចយល់បាន ដោយគ្រប់ទិដ្ឋភាពនៃជីវភាពសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌ខ្មែរទាំងអស់ ដែលបានអភិវឌ្ឍជាច្រើនសតវត្សរ៍មកហើយ ត្រូវបានលុបបំបាត់ចោលទាំងស្រុង" (Ayres 2000, 59)។ ប្រពៃណីសិក្សាជាន់ខ្ពស់ បានរងគ្រោះខ្លាំងជាងគេបំផុត ក្រោមរូបភាពនៃ "ការលុបបំបាត់ចោលទាំងស្រុងនេះ"។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ សូមកុំនិយាយដល់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិត ប្រទេសកម្ពុជាពេលនោះស្ទើរតែគ្មានអ្នកមានសញ្ញាបត្រជាន់ខ្ពស់ ដែលនៅរស់រានមានជីវិត ទទួលបណ្តុះបណ្តាលនិស្សិតនៅកម្រិតសាកលវិទ្យាល័យ ឲ្យដំណើរការបានផង។ នៅពេលដែលប្រព័ន្ធអប់រំ ត្រូវបានបើកទ្វារវិញភ្លាមៗ ការផ្តោតជាចម្បង គឺការបង្រៀន មិនមែនពីព្រោះតែការរំពឹងទុក ថានឹងបណ្តុះបណ្តាលមនុស្សឲ្យចេះរស់នៅក្នុងជីវភាពសង្គមដែលមានដំណើរការជាធម្មតាប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែមិនមានអ្នកស្រាវជ្រាវណាដែលនៅរស់រានមានជីវិត សម្រាប់បន្តវប្បធម៌ស្រាវជ្រាវនោះទេ។ ការសិក្សាក្រៅប្រទេស (ភាគច្រើនទៅសហភាពសូវៀតក្នុងអំឡុងឆ្នាំ១៩៨០) បានបំពេញចន្លោះប្រហោងនៃកង្វះការបណ្តុះបណ្តាលជាន់ខ្ពស់បានមួយកម្រិត ប៉ុន្តែនេះមិនមែនជាការស្រាវជ្រាវជាន់ខ្ពស់នោះទេ ហើយភាគតិចណាស់ដែលមានឱកាសបន្តការសិក្សាថ្នាក់បណ្ឌិត មុនពេលត្រូវហៅឲ្យត្រឡប់មកកម្ពុជាវិញដើម្បីកាន់តំណែងសំខាន់ៗ ក្នុងសាកលវិទ្យាល័យដែលទើបតែឈរជើងរួចក្រោយរបបខ្មែរក្រហម។ មរតកខ្មែរក្រហមនេះនៅតែឃើញមានស្ទើរគ្រប់ទីកន្លែងរហូតដល់សព្វថ្ងៃនេះ៖ ស្ទើរតែគ្រប់គ្នាដែលមានអាយុលើ ៤០ឆ្នាំ មិនមានកម្រិតសញ្ញាបត្រជាន់ខ្ពស់ទេ បើទោះបីជាគាត់កាន់តួនាទីខ្ពស់ក៏ដោយ។ ព្រោះតែកង្វះសមត្ថភាពនេះ មានសាកលវិទ្យាល័យ

[32] ជាធម្មតា អ្នកដែលត្រូវបានពួកខ្មែរក្រហមយកទៅរៀនសូត្រឡើងវិញ មិនដែលត្រឡប់មកវិញនោះទេ។ តាមពិត ពួកគេត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលតែម្តង។

តិចតួចណាស់ ដែលមានកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ហើយការផ្តោតជាចម្បងនៃសកម្មភាពសាកលវិទ្យាល័យ គឺទៅលើតែការរៀន និងបង្រៀនប៉ុណ្ណោះ។ នេះរួមទាំងប្រាក់ខែផងដែរ ដែលត្រូវគិតតាមម៉ោងបង្រៀន ពីព្រោះតែមិនមានគំរូសម្រាប់គាំទ្រការស្រាវជ្រាវណាមួយពីមុនមកទេ។ ដើម្បីដោះស្រាយបញ្ហានេះ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ បានហៅអ្នកនិពន្ធទី២ នៃអត្ថបទនេះ - យុវជនអាយុ ៣៥ឆ្នាំ ដែលទើបតែបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតថ្មីៗពីអឺរ៉ុបខាងជើង និងធ្លាប់ធ្វើជាទីប្រឹក្សាបច្ចេកទេស នៃគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សាស្រាប់ - មកដឹកនាំគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ ពីព្រោះតែនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ មិនមាន "សមត្ថភាព" គ្រប់គ្រាន់សម្រាប់គ្រប់គ្រងគម្រោងនេះទេ (សូមអានរបាយការណ៍បុគ្គលិកដែលមានសមត្ថភាព)។

ប៉ុន្តែម្តងទៀត តើហេតុអ្វីបានជាធនាគារពិភពលោកមិនយល់ពីបរិបទនេះយ៉ាងដូច្នេះ? ក្នុងអំឡុងពេល២ឆ្នាំ ធ្វើការនៅក្នុងការិយាល័យធនាគារពិភពលោកនៅទីក្រុងភ្នំពេញ យើងឈានដល់ការយល់ដឹងថា យុទ្ធវិធី *ប្រភេទសព្វបរិបទទូទៅ* ក្នុងការយល់ពីបរិបទ គឺជាប្រភពចម្បងបំផុតនៃបញ្ហា។ ក្នុងដំណាក់កាលរៀបចំគម្រោង ក្រុមការងាររបស់ធនាគារពិភពលោក មិនបានយកចិត្តទុកដាក់ទាល់តែសោះ អំពីរូបភាពជាក់លាក់នៃប្រទេសកម្ពុជា។ អ្នកនិពន្ធទី១ នៃអត្ថបទនេះ បានខំប្រឹងរុករកអស់ចិត្តដើម្បីរកឲ្យឃើញភស្តុតាងដែលថា ក្រុមការងាររបស់ធនាគារពិភពលោក (ក្រុមដែលបានបញ្ចប់ការងារនេះ ៣ឆ្នាំ មុនពេលអ្នកនិពន្ធទី១ ចាប់ផ្តើមការងារនេះ) ការពិតទៅ បានធ្វើការសិក្សាឲ្យបានស៊ីជម្រៅជាងនេះ - អ្វីមួយដែលបានចាប់ផ្តើមពីប្រភេទឧត្តមគតិ ប៉ុន្តែត្រូវបានបន្ថែមដោយការស្រាវជ្រាវដែលមានលក្ខណៈអាចបកស្រាយបានដោយផ្អែកលើភស្តុតាងជាក់ស្តែងក្នុងស្រុក។ ប៉ុន្តែ ការរុករកនេះ មិនបានរកឃើញអ្វីទាល់តែសោះ។ មិនមានសហការី/សហការិនីណាម្នាក់មកពីធនាគារពិភពលោក ដែលមានវត្តមាននៅក្នុងអំឡុងពេលនៃការបង្កើតគម្រោងនេះ (ឧទាហរណ៍ ដំណាក់កាលរៀបចំគម្រោង) អាចរកនឹកឃើញថា មានការស្រាវជ្រាវបែបនេះសោះ។ ផ្ទុយទៅវិញ ជាមួយចក្ខុវិស័យដ៏រឹងមាំដែលចម្លងចេញពីមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់នៅប្រទេសបង់ក្លាដែស ក្នុងសតិរបស់ក្រុមការងារធនាគារពិភពលោក នៅពេលនោះបានដាក់ឲ្យប្រើប្រាស់គំរូសាកល រួមមានប្រភេទសព្វទូទៅសម្រាប់ប្រទេសកម្ពុជាផងដែរ។ នេះអនុញ្ញាតឲ្យធនាគារពិភពលោក បង្កើតទស្សនវិស័យ ដែលជាតម្រូវការរបស់ខ្លួនអំពី "បរិបទ" បើនិយាយឲ្យត្រឹមត្រូវ គឺទស្សនវិស័យសើៗ និងជាទម្លាប់របស់ខ្លួនអំពី "បរិបទ" ក្នុងឯកសារផ្លូវការរបស់ខ្លួន គឺការបង្ហាញជាទូទៅអំពីសូចនាករម៉ាក្រូសេដ្ឋកិច្ច វិសមភាពយេនឌ័រ និងវិសមភាពសង្គម បន្ទាប់មកទៅលើអត្រាចុះឈ្មោះចូលរៀន និងការប្រមើលពីអត្រាចុះឈ្មោះចូលរៀនសម្រាប់ឆ្នាំបន្ទាប់។

ក្នុងកថាខណ្ឌតែ២គត់ បានលើកឡើងពី "បរិបទប្រវត្តិសាស្រ្តនៃអនុវិស័យឧត្តមសិក្សា" ដែលសរសេរនៅក្នុងឯកសារគន្លឹះក្នុងការបង្កើតគម្រោងផ្លូវការ (ឯកសារគន្លឹះក្នុងការបង្កើតគម្រោងផ្លូវការផ្នែក I.A.4. ដែលកាត់យកទៅដាក់ក្នុងយន្តការដំណើរការផ្នែក១.២.) មិនមានការលើកឡើងណាមួយ ដូចដែលយើងបានដកស្រង់សម្តីខាងលើ អំពីមរតកនៃរបបខ្មែរក្រហម ឬក៏ភាពទាក់ទងនៃរបបនេះទៅនឹងការស្លាប់របស់អ្នកដែលមានសញ្ញាបត្របណ្ឌិត និងវិបាករបស់វាមកលើសាកលវិទ្យាល័យ ដែលមានតែការរៀន និងការបង្រៀនតែមួយមុខគត់ ហើយខ្វះសមត្ថភាពស្រាវជ្រាវ។ ជាការពិត ការនិយាយដល់របបខ្មែរក្រហម ដែលចេញពីធនាគារពិភពលោក គឺមានតែនៅក្នុងផ្នែក "បរិបទប្រទេស" ទូទៅដែលនិយាយដោយខ្លី និងមិនគួរឲ្យពេញចិត្ត ថា៖

> ក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីការតស៊ូប្រយុទ្ធអស់រយៈពេល ៥ ឆ្នាំ កងកម្លាំងកុម្មុយនីស្តខ្មែរក្រហម បានវាយកាន់កាប់ទីក្រុងភ្នំពេញ និងបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង និងទីប្រជុំជន។ ខែធ្នូ ឆ្នាំ១៩៧៨ ការឈ្លានពានរបស់វៀតណាមបានបណ្តេញខ្មែរក្រហមចេញទៅជាយដែនខ្មែរ-ថៃ (World Bank 2010, x)។

ការប្រើប្រាស់អនុមានញែកចេញពី *ប្រភេទសព្វបរិបទទូទៅ* នៅក្នុងធនាគារពិភពលោក អំពី "បរិបទ" ត្រូវបានបង្កើតយ៉ាងប្រញាប់ប្រញាល់ ដូចជាក្រដាសដ៏ស្តើងមួយសន្លឹក គ្មានអ្វីទាស់តែសោះ ក្រៅពីចំនួន និងលេខ។

នៅទីនេះ យើងអាចទាញការយល់ឃើញរបស់ធនាគារពិភពលោកដ៏ទូលំទូលាយបាន នោះគឺ ភាពពុកផុយដែលកើតចេញពីរបៀបនៃ "ការគិត" របស់ធនាគារពិភពលោក។ *ប្រភេទសព្វបរិបទទូទៅ* របស់ធនាគារពិភពលោក ទៅលើ "សាកលវិទ្យាល័យ" នៅពេលដែលអនុវត្តនៅកម្ពុជា បានជំនួសតថភាពជាក់ស្តែង ជាមួយនឹងឧត្តគតិរបស់ធនាគារពិភពលោកទៅលើសកលវិទ្យាល័យ ដែលពួកគេគិតថា "សាកលវិទ្យាល័យ" នៅកម្ពុជា ក៏ដូចសាកលវិទ្យាល័យនានានៅទូទាំងពិភពលោក ត្រូវតែពោរពេញទៅដោយអ្នកដែលមានសញ្ញាបត្របណ្ឌិត និងផ្តោតសំខាន់លើការបង្រៀន ការស្រាវជ្រាវ និងការអភិវឌ្ឍជាតិ។ ពិតណាស់ តថភាពជាក់ស្តែងនៅហ្នឹងកន្លែងរបស់ប្រទេសកម្ពុជា ត្រូវបានជំនួសដោយឧត្តមគតិរបស់ធនាគារពិភពលោកអំពីគ្រឹះស្ថានឧត្តមសិក្សាបែបនេះ។ នេះ គឺជាការបង្ហាញយ៉ាងច្បាស់អំពីអ្នកអង្កេត "ដែលដាក់ជំនួសប្រភេទឧត្តមគតិរបស់ខ្លួនដោយមិនដឹងខ្យល់អ្វីទាំងអស់ទៅលើសតិរបស់ប្រធានវិស័យដែលពួកគេកំពុងអង្កេត" (Schütz [1932] 1967, 205)។ អ្វីដែលភ្ញាក់ផ្អើលបំផុតនោះគឺ មិនមែនធនាគារពិភពលោក បកស្រាយអំពីអថេរបរិបទគន្លឹះខុសទេ តែធនាគារពិភពលោកបានបំភ្លេចបរិបទចោលតែម្តង។ ការអនុវត្តយុទ្ធវិធី *ប្រភេទសព្វបរិបទទូទៅ* ឲ្យមានប្រសិទ្ធភាព មានន័យថា ធនាគារពិភពលោក ដំណើរការក្នុងប្រព័ន្ធទំនាក់ទំនងមួយដែលបិទជិត ដោយគ្មានលទ្ធភាពណាដែលបរិបទ (ផ្ទុយពី "បរិបទ" ឧទាហរណ៍ រូបភាពដ៏ស្តើងបំផុតដូចក្រដាសមួយសន្លឹក អំពីបរិបទដែលត្រូវបានបង្កើតឡើងដោយប្រភេទសព្វបរិបទទូទៅ និងបោះពុម្ពក្នុងឯកសារធនាគារពិភពលោក) អាចមានឥទ្ធិពលលើ "ការគិត" របស់ខ្លួននោះទេ ហើយក៏ដូចដែលធនាគារពិភពលោក មិនដែលរកឃើញកំហុសរបស់ខ្លួនផងដែរ។ នោះ គឺអ្វីដែលគេស្គាល់ជាទូទៅ និងដ៏ទូលំទូលាយ និងមានឥទ្ធិពលកប់យ៉ាងជ្រៅ ដូចជាមរតកឥទ្ធិពលខ្មែរក្រហម អាចត្រូវបានបំភ្លេចចោល បានបង្ហាញឲ្យឃើញពីភាពងងឹតខ្វាក់ថ្លង់ របស់ធនាគារពិភពលោក។

### ខ. បរាជ័យទី២ ៖ លទ្ធកម្ម និងបុគ្គលិក

នៅពេលដែលសាកលវិទ្យាល័យ ដែលទទួលបានគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ បន្តជំនះយ៉ាងស្ងៀមស្ងាត់ ដើម្បីស្វែងយល់ពីរបៀបអនុវត្ត និងគ្រប់គ្រងការស្រាវជ្រាវ បញ្ហាភ្លាមៗ និងធ្ងន់ធ្ងរបំផុត ដែលពួកគេជួបប្រទះនៅនឹងមុខ គឺការធ្វើលទ្ធកម្ម។ បញ្ហានេះ គឺពាក់ព័ន្ធនឹងបុគ្គលិក ដែលនឹងត្រូវអនុវត្តគម្រោងស្រាវជ្រាវ និងចាត់ចែងបញ្ហារដ្ឋបាល និងហិរញ្ញវត្ថុនៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។ សម្រាប់អ្នកដែលមិនសូវស្គាល់ពាក្យរបស់ម្ចាស់ជំនួយ ការធ្វើលទ្ធកម្មសំដៅលើការបញ្ជាទិញទំនិញ ការបណ្តុះបណ្តាល ការងារ និងសេវាផ្សេងៗទៀតដែលចាំបាច់ក្នុងការអនុវត្តគម្រោងស្រាវជ្រាវ។ ដើម្បីការពារកុំឲ្យមានអំពើពុករលួយ និងការបំពានការប្រើប្រាស់ថវិកា ជាញឹកញាប់ ម្ចាស់ជំនួយតែងតែដាក់ចេញនូវច្បាប់ជាច្រើន ទាក់ទងនឹងសកម្មភាពលទ្ធកម្មនេះ ដូចជាការប្រកាសផ្សព្វផ្សាយ និងបែបបទដេញថ្លៃ យន្តការជ្រើសរើសប្រកបដោយតម្លាភាព វិក័យប័ត្រ និងរបាយការណ៍ ក៏ដូចជាមុខទំនិញណាដែលថវិកាអាចប្រើប្រាស់បាន។ ដោយផ្អែកលើស្ថានភាពប្រទេសនីមួយៗ ធនាគារពិភពលោក ដាក់កម្រិតនៃភាពតឹងរ៉ឹងមកលើការធ្វើលទ្ធកម្មផ្សេងៗគ្នា។ ដោយសារតែការយល់ឃើញពីបញ្ហាពុករលួយខ្លាំង និងការបរាជ័យទាំងស្រុងនៃគម្រោងមួយក្នុងឆ្នាំ២០០៦ ដែលនៅពេលនោះធនាគារពិភពលោកបានបង្កកកម្ចីចំនួន៣ ដើម្បីបង្ហាញពីជំហរប្រឆាំងនឹងការប្រើប្រាស់ថវិកាមិនត្រឹមត្រូវនៅក្នុងប្រទេសកម្ពុជា (Ear 2013, 45-47) គោលការណ៍របស់ធនាគារពិភពលោក អំពីការធ្វើលទ្ធកម្មនៅប្រទេសកម្ពុជា គឺស្ថិតក្នុងចំណោមកម្រិតដែលមានភាពតឹងរ៉ឹងជាងគេបំផុតនៅក្នុងពិភពលោក។ នេះក៏មានន័យថា គោលការណ៍លទ្ធកម្មរបស់ធនាគារពិភពលោក មានលក្ខណៈស្មុគស្មាញជាងគេបំផុតផងដែរ។ នៅក្នុងគម្រោងលើកកម្ពស់

គុណភាព និងសមត្ថភាពឧត្តមសិក្សា វាមានន័យ ជាការតម្រូវឲ្យនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ពិនិត្យមើលរាល់ការចំណាយទាំងអស់ជាមួយធនាគារពិភពលោក និងត្រូវទទួលបានលិខិតមិនជំទាស់ (NOL) ពីធនាគារពិភពលោក មុនពេលដែលថវិកាជាក់ស្តែងត្រូវបានបើកឲ្យទៅអនុគម្រោង នៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។ សំខាន់ជាងនេះទៀត គឺបែបបទលទ្ធកម្មតឹងរ៉ឹងនេះ ត្រូវបានដាក់ឲ្យអនុវត្តមុនការតាក់តែងអនុគម្រោងនៃគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សាទៅទៀត។

ការធ្វើលទ្ធកម្មនៅប្រទេសបង់ក្លាដែស សម្រាប់មូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់ត្រូវបានគេរាយការណ៍ថា មានបញ្ហាតិចតួច។ ហេតុអ្វី? មូលហេតុមួយគឺថា កម្រិតភាសាអង់គ្លេសមានកម្រិតខ្ពស់ក្នុងចំណោមអ្នកធ្វើការនៅសាកលវិទ្យាល័យនៅទីនោះ (គ្រប់ការធ្វើលទ្ធកម្មរបស់ធនាគារពិភពលោកនៅជុំវិញពិភពលោក ត្រូវធ្វើឡើងជាភាសាអង់គ្លេស នៅពេលមានករណីជម្លោះកើតឡើង) ឯមូលហេតុមួយទៀត គឺថាការធ្វើលទ្ធកម្មរបស់ធនាគារពិភពលោកនៅទីនោះ មិនសូវមានភាពតឹងរ៉ឹងដូចនៅកម្ពុជាទេ។ ប៉ុន្តែបញ្ហាសំខាន់ជាងគេគឺថវិកាមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់ អាចត្រូវបានចំណាយលើការជួល និងបើកប្រាក់ខែឲ្យបុគ្គលិកពេញម៉ោង ដែលធ្វើការនៅក្នុងសាកលវិទ្យាល័យ អ្នកទាំងនេះធ្វើការងារតែទៅលើហិរញ្ញវត្ថុ និងលទ្ធកម្មតែប៉ុណ្ណោះ។ ជាមួយការផ្តោតតែទៅលើការទទួលបានធនធាន បុគ្គលិកកិច្ចសន្យាពេញម៉ោងទាំងនេះតម្រូវឲ្យបង្កើត និងដោះស្រាយកញ្ចប់លទ្ធកម្មធំៗ ១ ឬ ២ (ឧទាហរណ៍ សម្ភារមន្ទីរពិសោធន៍ កុំព្យូទ័រ...) ហើយបន្ទាប់មកការងាររបស់ពួកគេនឹងត្រូវបានបញ្ចប់។ ក្នុងន័យម្យ៉ាងវិញទៀត នៅប្រទេសបង់ក្លាដែស ផ្នែកខ្លះនៃថវិការបស់មូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់ អាចប្រើប្រាស់សម្រាប់ជាប្រាក់បន្ថែមលើប្រាក់ខែបុគ្គលិកសម្រាប់ការងារបន្ថែមនេះ។

ផ្ទុយទៅវិញ អ្នកទទួលបានគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍នៅកម្ពុជា ត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់ថវិកាទាំងនេះ ក្នុងការជួលបុគ្គលិកឲ្យមកចាត់ចែងការងាររដ្ឋបាលនៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍នេះទេ។ នេះមានន័យថា បុគ្គលិករដ្ឋបាលនៃសាកលវិទ្យាល័យនៅកម្ពុជា ត្រូវតែរៀន និងអនុវត្តបែបបទលទ្ធកម្មដ៏ស្មុគស្មាញ និងប្រើភាសាអង់គ្លេសជាគោលតាមធនាគារពិភពលោក បន្ថែមពីលើកាតព្វកិច្ចការងារប្រចាំថ្ងៃរបស់ពួកគេដែលមានស្រាប់។ គួរកត់សម្គាល់ដែរថា គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍មានទំហំ៣ទៅ ៤ ដងច្រើនជាងមូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់នៅបង់ក្លាដែស ហើយវាប្រើប្រាស់យន្តការគណនេយ្យបរទេសទាំងស្រុង និងទាក់ទងនឹងការប្រើប្រាស់លុយដែលអ្នកធ្វើការងារ រដ្ឋបាលប្រចាំសាកលវិទ្យាល័យ មិនធ្លាប់បានអនុវត្តពីមុនមក នេះមានន័យថា វាជាការបន្ថែមការងារជាទម្ងន់ដោយគ្មានបន្ថែមប្រាក់កម្រៃ។

តើអ្វីទៅជាប្រភពនៃការរៀបចំដ៏ចម្រូងចម្រាសបែបនេះ? ចាប់តាំងពីឆ្នាំ១៩៨០ មក ម្ចាស់ជំនួយនៅកម្ពុជាបើកប្រាក់ (ហៅថា ប្រាក់លើកទឹកចិត្ត) សម្រាប់ដៃគូជនជាតិខ្មែរដែលចាត់ចែង និងអនុវត្តគម្រោងរបស់ពួកគេ។ តក្កវិជ្ជានៅទីនេះគឺសាមញ្ញបំផុត៖ ពុំមាននរណាម្នាក់សុខចិត្ត ធ្វើការកសាងសាលារៀន ទៅចូលរួមវគ្គបណ្តុះបណ្តាល ឬទទួលការងារបន្ថែមសម្រាប់យុទ្ធនាការ លើកកម្ពស់ការយល់ដឹងដោយស្ម័គ្រចិត្តនោះទេ នៅពេលដែលគ្រាន់តែការស្វែងរកប្រាក់ឲ្យបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតរបស់គាត់ គឺជាការតស៊ូស្លាប់រស់ទៅហើយ។ ប្រាក់ឧបត្ថម្ភរបស់ម្ចាស់ជំនួយ គឺត្រូវបានផ្តល់ឲ្យទៅបុគ្គលិករដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដូចគ្នា។ ប៉ុន្តែនៅពេលដែលសេដ្ឋកិច្ចទីក្រុងភ្នំពេញ មានការរីកចម្រើននៅឆ្នាំ១៩៩០ ហើយម្ចាស់ជំនួយកាន់តែច្រើនឡើង បានហូរចូលមកកាន់កម្ពុជា វានាំឲ្យមានអតិផរណានៃសេវាកម្មទាំងនេះដែលតម្រូវឲ្យម្ចាស់ជំនួយបង់ថវិកាកាន់តែច្រើនឡើងៗ ក្នុងមួយឆ្នាំៗ ដើម្បីទប់ទល់នឹងការឡើងប្រាក់ខែនៅក្រុងភ្នំពេញ និងការប្រកួតប្រជែងក្នុងចំណោមម្ចាស់ជំនួយដូចគ្នា ដើម្បី "ទទួលបានមនុស្សល្អបំផុត" មកចាត់ចែង និងអនុវត្តគម្រោងរបស់ពួកគេ។ ការណ៍នេះ នាំឲ្យមានកំណើនចំណាយ សម្រាប់

គម្រោងនីមួយៗ។ វាក៏បានបង្កើតជាការបារម្ភផងដែរ ទាក់ទងនឹងរឿងដែលថា ប្រាក់ឧបត្ថម្ភនេះអាចបណ្តាលឲ្យមានអំពើពុករលួយកាន់តែច្រើនឡើង ព្រោះគម្រោងត្រូវបានជ្រើសរើសដោយរដ្ឋាភិបាលកម្ពុជា ដោយមិនបានពិចារណាលើតម្រូវការក្នុងស្រុក ប៉ុន្តែផ្អែកលើថា តើមានចំណែកប្រាក់ឧបត្ថម្ភប៉ុន្មានក្នុងកញ្ចប់ថវិកាគម្រោងទាំងមូល។ នៅកម្ពុជា ក៏ដូចជានៅក្នុងកម្រិតពិភពលោកទាំងមូល  ថវិការបស់ម្ចាស់ជំនួយទាំងនេះគឺជាសាំងដែលនាំឲ្យកង់នៃប្រព័ន្ធបរិបាល[33] វិលទៅមុខជានិច្ច និងជាប្រភពនៃការធ្វើឲ្យបែកខ្ញែកអាទិភាពគោលនយោបាយ។

សេដ្ឋកិច្ចវិទូប្រចាំធនាគារពិភពលោក យល់ពីបញ្ហានេះច្បាស់ណាស់ ប៉ុន្តែបែរជាធ្វើបញ្ញត្តិនីយកម្មទៅជារឿងមិនប្រក្រតីខាងផ្នែកសេដ្ឋកិច្ចទៅវិញ ដែលបង្កើតឡើងតាមរូបភាពប្រាក់ឧបត្ថម្ភដោយរដ្ឋាភិបាលបែបនេះ។ នោះគឺពួកគេគិតថា មានជំនួយប្រាក់ដុល្លារ ហូរចូលមកកាន់កម្ពុជាច្រើនពេក ដែលនាំទីផ្សារការងារដំណើរការមិនប្រក្រតី។ ឧទាហរណ៍ ការបើកប្រាក់ឧបត្ថម្ភឲ្យមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ៣០ដុល្លារ (ក្នុងមួយថ្ងៃ) ដើម្បីឲ្យមកចូលរួមសិក្ខាសាលា រៀបចំដោយម្ចាស់ជំនួយ ដែលមានន័យថា ក្នុងរយៈពេល១០ថ្ងៃសោះ គាត់អាចទទួលបានប្រាក់ ស្មើនឹងប្រាក់ខែមន្ត្រីរាជការរបស់គាត់គឺ ៣០០ ដុល្លារ។ ស្ថិតក្រោមប្រព័ន្ធបែបនេះ វាមិនមានភាពចាំបាច់ណាមួយសម្រាប់រដ្ឋាភិបាលក្នុងការដំឡើងប្រាក់បៀវត្សរ៍ ជូនមន្ត្រីរាជការនោះទេ ហើយក៏គ្មានទំនាក់ទំនងរវាង ប្រាក់៣០ ដុល្លារ ដើម្បីធ្វើការងារជាមួយគម្រោងរបស់ម្ចាស់ជំនួយ និង "អត្រាទីផ្សារ" នោះដែរ៖ ថ្លៃដែលដាក់ចេញនេះ គ្រាន់តែជាការឆ្លុះបញ្ចាំង អំពីថវិកាដែលម្ចាស់ជំនួយស្ម័គ្រចិត្តបង់ ដើម្បីណែនាំគម្រោងរបស់ពួកគេតែប៉ុណ្ណោះ។

ហេតុនេះ សេដ្ឋកិច្ចវិទូប្រចាំធនាគារពិភពលោក បានជម្រាបទៅរដ្ឋាភិបាលនៅអំឡុងដើមឆ្នាំ ២០១០ ថា ខ្លួននឹងបញ្ឈប់លែងឲ្យមានការប្រើប្រាស់ថវិការបស់ខ្លួន សម្រាប់ជាការបើកប្រាក់ឧបត្ថម្ភទៀតហើយ (សំដៅលើការបើកថវិកាឲ្យមន្ត្រីរាជការកម្ពុជា ដើម្បីចូលរួមអនុវត្តគម្រោងរបស់ម្ចាស់ជំនួយ) ហើយបានបញ្ចុះបញ្ចូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យចេញគោលការណ៍នេះ ដើម្បីអនុវត្តលើគ្រប់ការអនុវត្តគម្រោងរបស់ម្ចាស់ជំនួយផ្សេងទៀតទាំងអស់។ ក្រសួងសេដ្ឋកិច្ច បានទទួលយកសំណើនេះ ព្រោះខ្លួនពុំសូវបានទទួលប្រាក់ឧបត្ថម្ភបែបនេះទេ (ពីព្រោះក្រសួងសេដ្ឋកិច្ច មិនមែនជាអ្នកអនុវត្តគម្រោងទាំងនេះទេ) ហើយក៏គិតក្នុងន័យសេដ្ឋកិច្ច/ទីផ្សារស្រដៀងគ្នានេះដែរ។ ប៉ុន្តែ ការសម្រេចចិត្តនេះ បានធ្វើឲ្យមានការអន់ចិត្តពីសំណាក់ក្រសួងជាច្រើន ដែលពឹងផ្អែកលើ "ប្រាក់ឧបត្ថម្ភបែបនេះ" សម្រាប់ជីវភាពរស់នៅ នៅពេលដែលប្រាក់បៀវត្សរ៍មិនទាន់គ្រប់គ្រាន់។ សកម្មភាពជាលក្ខណៈឯកតោរបស់ធនាគារពិភពលោកនេះ ក៏បានធ្វើឲ្យម្ចាស់ជំនួយអន្តរជាតិផ្សេងទៀតអន់ចិត្តផងដែរ។ ជាការឆ្លើយតបទៅវិញ ក្រសួង និងម្ចាស់ជំនួយផ្សេងទៀត បានរិះរកវិធីប្រកបដោយការច្នៃប្រឌិត ដើម្បីបញ្ចៀសបម្រាមនេះ ដោយទទួលស្គាល់ថា វាគឺជារឿងមិនសមហេតុផល និងមិនអាចទៅរួច ដែលហៅមនុស្សឲ្យមកចូលរួមធ្វើការងារបន្ថែមក្នុងគម្រោងរបស់ម្ចាស់ជំនួយដោយមិនមានថវិកាបន្ថែម។ រហូតមកទល់ថ្ងៃនេះ ម្ចាស់ជំនួយជាច្រើនដូចជា យូនីសេហ្វ ភ្នាក់ងារសហប្រតិ-បត្តិការអន្តរជាតិជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី នៅតែបន្តបើកប្រាក់ "ប្រាក់ឧបត្ថម្ភ" នេះដដែល។ ទោះបីជាយ៉ាងនេះក៏ដោយ ធនាគារពិភពលោក ជាប់អន្ទាក់បម្រាមខ្លួនឯង៖ មិនមានប្រាក់ឧបត្ថម្ភ បើកឲ្យអ្នកធ្វើការក្នុងគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា ដែលបានរៀបចំឡើងក្នុងឆ្នាំតែមួយ ដែលបម្រាម "គ្មានប្រាក់ឧបត្ថម្ភ" ត្រូវបានប្រកាសឲ្យប្រើ[34]។ ក្នុងដំណាក់កាលដំបូង ទោះបីជាបុគ្គលិក

---

[33] ប្រព័ន្ធបរិបាល គឺជាការដឹកនាំដែលផ្តល់ឲ្យបក្ខពួកខ្លួនដូចជា មិត្តភក្តិ បងប្អូន ឬអ្នកគាំទ្រខ្លួននូវការងារ និងតួនាទីក្នុងជួររដ្ឋាភិបាល ដោយមិនគិតគូរពីសមត្ថភាពក្នុងការធ្វើការងារជាក់ស្តែង។

[34] មុនបម្រាមចូលជាធរមាន បុគ្គលិកដែលអនុវត្តគម្រោងលើកកម្ពស់គុណភាពនិងសមត្ថភាពឧត្តមសិក្សាបានទទួលប្រាក់ឧបត្ថម្ភក្នុងរយៈពេលខ្លីមួយ។ ដោយរៀនសូត្រពីបទពិសោធន៍ពីគម្រោងទី១ ក្នុងការអនុវត្តគម្រោងលើកទី២ "គម្រោងកែលម្អការអប់រំឧត្តមសិក្សា២០១៨-២០២៤" ធនាគារពិភពលោកបានបញ្ចុះ

ផ្នែកអប់រំរបស់ធនាគារពិភពលោក ទទួលស្គាល់ថា វាអាចជះឥទ្ធិពលមកលើគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា ពួកគេមានអំណាចតិចតួចណាស់ ក្នុងការតវ៉ាជាមួយក្រុមសេដ្ឋកិច្ចវិទូរបស់ធនាគារពិភពលោក។ ក្នុងដំណើរការជាក់ស្តែង វាមានន័យថា ធនាគារពិភពលោកនៅតែបចេសថា លទ្ធកម្មរបស់គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សាដែលគាំទ្រដោយធនាគារពិភពលោក ស្ថិតក្នុងចំណោមការធ្វើលទ្ធកម្មដែលតឹងរ៉ឹងបំផុតក្នុងពិភពលោក ត្រូវតែធ្វើឡើងដោយបុគ្គលិករបស់សាកលវិទ្យាល័យ ដែលមិនអាចទទួលបានប្រាក់កម្រៃបន្ថែម ចេញពីគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។ ពួកគេ គឺកំពុងសុំឲ្យមានការធ្វើការងារដោយទទេ (មិនមានប្រាក់ឧបត្ថម្ភ)។

ចុងក្រោយបំផុត គឺផលបូករវាងការធ្វើលទ្ធកម្មដ៏ស្មុគស្មាញ និងបញ្ហាប្រាក់ឧបត្ថម្ភបុគ្គលិកនេះហើយ ដែលជាមូលហេតុចម្បងទី២នៃការបរាជ័យរបស់គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍នៅកម្ពុជា គឺភាពបរាជ័យនៃបែបបទអនុវត្តគម្រោង។ បញ្ហានេះ បានគ្របដណ្តប់លើគម្រោងគ្រប់កម្រិតទាំងអស់។ ជាឧទាហរណ៍ យើងលើកមកបង្ហាញពីគម្រោងកសិកម្មក្នុងសាកលវិទ្យាល័យមួយ នៅជនបទដាច់ស្រយាល ដែលទទួលបានថវិកាចំនួន ១៦៦.០០០ ដុល្លារសហរដ្ឋអាមេរិក។ អ្នកដឹកនាំគម្រោង មានសញ្ញាបត្របណ្ឌិត ហើយគម្រោងនេះ គឺជាគម្រោងមួយដែលរៀបចំបានល្អជាងគេ ក្នុងកម្រិតការស្រាវជ្រាវជាន់ខ្ពស់ ដែលអនុញ្ញាតឲ្យយើងលើកយកតែរឿងបែបបទអនុវត្តគម្រោងផ្នែកលទ្ធកម្ម និងបុគ្គលិក មកធ្វើការពិភាក្សា។ អនុគម្រោងព្យាយាមស្រាវជ្រាវអំពីថាតើដំណាំឆ្លាស់គ្នាបែបណាដែលល្អសម្រាប់ស្តារដីដែលបាត់បង់ជីជាតិ ដោយសារតែការដាំដំណាំដំឡូងមីតែមួយមុខជារៀងរាល់ឆ្នាំដោយកសិករក្រីក្រ។ អ្នកស្រាវជ្រាវ ប៉ុនប៉ងប្រើប្រាស់ផ្ទៃដីដែលរៀបចំជាប្លុកៗ ដោយការគ្រប់គ្រងស្តង់ដារដោយចៃដន្យ និងដាំដំណាំដូចជា សណ្តែកសៀង សណ្តែកបាយ និងពោតនៅចន្លោះវដ្តគម្រោងដែលមានរយៈពេល ២ ឆ្នាំ បន្ទាប់មកធ្វើតេស្តមុន និងក្រោយអំពីសារធាតុជីសំខាន់ៗ (ប៉ូតាស្យូម នីត្រូសែន និងផូស្វ័រ)។

ទោះបីជាមានការរៀបចំគម្រោងបានល្អ អ្នកស្រាវជ្រាវមានសមត្ថភាព និងមានការប្តេជ្ញាចិត្តខ្ពស់បែបនេះក៏ដោយ ការធ្វើលទ្ធកម្មរបស់ធនាគារពិភពលោក បានសម្លាប់គម្រោងនេះទាំងស្រុង។ ជាក់ស្តែង អ្នកស្រាវជ្រាវ តម្រូវឲ្យមានអាចម៍គោច្រើន ដើម្បីធ្វើជាជីធម្មជាតិសម្រាប់ប្លុកពិសោធន៍។ ការទាមទារនេះ គឺនឹងត្រូវចំណាយលើសពី ១.០០០ដុល្លារសហរដ្ឋអាមេរិក (ប៉ុន្តែតិចជាង១% នៃចំណាយសរុបរបស់គម្រោង)។ គាត់ត្រូវប្រមូលបន្តិចម្តងៗពីកសិករជាច្រើន ដោយហេតុថានៅកម្ពុជា មិនមានកសិដ្ឋានពាណិជ្ជកម្មអាចម៍គោនោះទេ។ នៅពេលដែលគាត់ប្រមូលទិញ អ្នកភូមិមិនមានវិក័យប័ត្រចេញឲ្យនោះទេ ហើយមនុស្សស្ទើរតែទាំងអស់ មិនអាចអានសេចក្តីប្រកាសដេញថ្លៃផ្លូវការសម្រាប់ទិញអាចម៍គោនោះទេ។ ប៉ុន្តែ បែបបទលទ្ធកម្មរបស់ធនាគារពិភពលោកចែងថា មានតែការទិញណាដែលថោកជាង ៥០ដុល្លារសហរដ្ឋអាមេរិក ទើបមិនចាំបាច់ត្រូវការវិក័យប័ត្រ។ ប៉ុន្តែការទិញរបៀបនេះ អនុញ្ញាតបានសម្រាប់តែការទិញទំនិញមួយមុខតែប៉ុណ្ណោះ។ តាមរបៀបនេះ វាគ្មានផ្លូវណាមួយដែលអ្នកស្រាវជ្រាវ អាចទិញអាចម៍គោបានទេ ប៉ុន្តែ បើគ្មានអាចម៍គោ គាត់មិនក៏អាចចាប់ផ្តើមការស្រាវជ្រាវរបស់គាត់បានដែរ។

មានតែបុគ្គលិករដ្ឋបាលម្នាក់គត់ នៅសាកលវិទ្យាល័យជនបទតូចមួយនេះ។ គាត់មិនចេះភាសាអង់គ្លេសស្ទាត់ ហើយជំនាញគណនេយ្យរបស់គាត់ ក៏បានត្រឹមតែសម្រាប់បើកថវិកាដែលបានពីរដ្ឋាភិបាលឲ្យប្រធានដេប៉ាតឺម៉ង់ និងប្រមូលថ្លៃសិក្សា

បញ្ចូលក្រសួងសេដ្ឋកិច្ចឡើងវិញឲ្យប្រើប្រាស់ថវិកាបដិភាគរបស់រដ្ឋាភិបាលដើម្បីឧបត្ថម្ភបុគ្គលិកដែលចូលរួមអនុវត្តគម្រោងនេះ។ ទោះបីជាមកទល់ខែឧសភា ឆ្នាំ២០២០ អ្នកអនុវត្តគម្រោងទាំងអស់មិនទាន់ទទួលបានប្រាក់ឧបត្ថម្ភក៏ដោយ ក៏ការស្នើសុំនៅតែបន្ត និងហាក់មានការសន្យាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុថាប្រាក់ឧបត្ថម្ភនេះនៅតែគ្រោងបើកជូនបុគ្គលគម្រោងដដែល នៅពេលដែលឯកសារ និងក្រុមការងារត្រូវបានរៀបចំឲ្យបានត្រឹមត្រូវ ដើម្បីធានាឲ្យបានភាពជោគជ័យ និងពន្លឿនល្បឿនអនុវត្តន៍របស់គម្រោងដែលយឺតយ៉ាវនាពេលកន្លងមក។

ពីកូនសិស្សតែប៉ុណ្ណោះ។ ការណ៍នេះ បង្ខំឲ្យអ្នកស្រាវជ្រាវ និងជាអ្នកដឹកនាំគម្រោងខ្លួនឯង ធ្វើដំណើរជាច្រើនលើកច្រើនសារមកទីក្រុងភ្នំពេញ (រយៈពេល ៤ម៉ោងក្នុងមួយជើង ប្រសិនបើគាត់មានយានយន្តល្អ) ដើម្បីព្យាយាមស្វែងរកដំណោះស្រាយ និងដើម្បីបើកថវិកា។ ជាលទ្ធផល វដ្តនៃការដាំដុះ បានរំលងហួសក្នុងឆ្នាំទី១ មានន័យថា គម្រោងនេះត្រូវរងចាំមួយឆ្នាំពេញទៀត ដើម្បីចាប់ផ្តើមឡើងវិញ (ដោយសារតែរដូវភ្លៀង និងរដូវទឹកជំនន់)។ នៅបំណាច់ឆ្នាំទី១ នៃគម្រោងរយៈពេល២៤ខែ អ្នកស្រាវជ្រាវ ចំណាយបានត្រឹមតែ ២.៧០០០ ដុល្លារ (១៦% នៃថវិកាសរុប)។ ពុំមានបុគ្គលិកសាកលវិទ្យាល័យណាម្នាក់ ត្រូវបានផ្តល់ប្រាក់បន្ថែមសម្រាប់ធ្វើការងារនេះទេ។ ខណៈដែលនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងធនាគារពិភពលោក ចូលរួមក្នុងការពិភាក្សាអំពីរបៀបដែលអាចបញ្ជាទិញអាចម៍គោឲ្យស្របច្បាប់ ទាំងអ្នកស្រាវជ្រាវ និងអ្នករដ្ឋបាលប្រចាំសាកលវិទ្យាល័យ លែងមានចំណាប់បន្តទៀត ហើយក៏បានសម្រេចចិត្តបោះបង់ចោលការទិញអាចម៍គោ រួចដាំដោយគ្មានអាចម៍គោនៅរដូវបន្ទាប់។ នៅពេលដែលយើងទៅជួបដល់ទីកន្លែងនៅឯសាកលវិទ្យាល័យ ក្នុងរយៈពេល ៣ម៉ោង ការពិភាក្សាផ្តោតតែទៅលើការធ្វើការងារលទ្ធកម្ម និងអាចម៍គោ មិនមែនបញ្ហាបច្ចេកទេសទេ (បញ្ហាទាក់ទងនឹងការស្រាវជ្រាវជាន់ខ្ពស់)។ ចុងក្រោយនៅពេលដែលយើងទៅមើលផ្ទាល់ដល់ទីកន្លែងពិសោធន៍ មានតែដំណាំពីរទៅបីដើម ដែលហាក់ដូចមានជំងឺបានដុះឡើងពីដីខ្សាច់ ដែលហិលរបស់ទន្លេមេគង្គក្រោម។ នេះមិនមែន "នវានុវត្តន៍" ប៉ុន្តែជាការបរាជ័យ។

ជាទូទៅ ការណ៍ដែលគ្មានប្រាក់ឧបត្ថម្ភ ហើយប្រឈមនឹងភាពស្មុគស្មាញនៃដំណើរការលទ្ធកម្មរបស់ធនាគារពិភពលោក មានន័យថា នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំត្រូវចំណាយពេលធ្វើដំណើរជាច្រើនសារ ដើម្បីបណ្តុះបណ្តាលបុគ្គលិកក្នុងស្ថាប័ន ដែលទទួលបានគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។ នៅក្នុងឆ្នាំដំបូងនៃការអនុវត្តគម្រោង សូម្បីតែបុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំខ្លួនឯង ក៏មិនទាន់យល់ច្បាស់ពីបែបបទរបស់ធនាគារពិភពលោកដែរ៖ ស្ទើរតែគ្រប់សំណើទាំងអស់ត្រូវបានបដិសេធតាមរយៈការមិនចេញលិខិតមិនជំទាស់ (NoL) របស់ធនាគារពិភពលោក។ ក្នុងពេលជាមួយគ្នានេះដែរ បុគ្គលិកធនាគារពិភពលោក ដែលទទួលខុសត្រូវលើសំណើទាំងនេះ គឺជាអ្នកជំនាញខាងលទ្ធកម្ម និងហិរញ្ញវត្ថុ ដែលមិនមានការយល់ដឹងពីការងារស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យទាល់តែសោះ។ ឧទាហរណ៍ នៅពេលពួកគេឃើញសំណើទិញអាចម៍គោចំនួន ១.០០០ដុល្លារ ហើយគ្មានវិក័យប័ត្រ ពួកគេសន្មតភ្លាមៗថា ជាផែនការពុករលួយ។ ជាយថាហេតុ ជាង៧០% នៃបុគ្គលិកដែលចាត់តាំងដោយសាកលវិទ្យាល័យ ឲ្យទទួលខុសត្រូវលើការងារលទ្ធកម្មនៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ បានលាលែងពីការងារនេះ ក្នុងនាមជាការប្រឆាំងដោយស្ងៀមស្ងាត់ និងដោយការភ័យខ្លាចថា ពួកគេនឹងត្រូវប្រឈមនឹងការទទួលខុសត្រូវផ្លូវច្បាប់ លើរឿងរ៉ាវនៃការចាត់ចែងថវិកាមិនត្រឹមត្រូវ។ អ្នកមកជំនួសពួកគេនឹងត្រូវបានបង្ហាត់បង្រៀនឡើងវិញ ដោយបុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ដែលហួសពីកម្លាំងដែលនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំមាន ហើយការងារបន្ថែមទាំងនេះគឺមិនមានការឧបត្ថម្ភអ្វីទាំងអស់ ហើយត្រូវចាំថា បុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ មានកាតព្វកិច្ចជាច្រើនទៀតដែលត្រូវធ្វើ។

ទោះជាវាបង្ហាញច្បាស់ថា គម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ កំពុងស្ថិតនៅលើមាគ៌ាបរាជ័យក៏ដោយ ធនាគារពិភពលោក បានធ្វើការរិះគន់ខ្លាំងៗ មកលើនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំថា មិនបានធ្វើការឲ្យសកម្មក្នុងការគាំទ្រគ្រឹះស្ថានឧត្តមសិក្សា។ អ្នកនៅក្នុងធនាគារពិភពលោក ហាក់មិនមានលទ្ធភាពទទួលស្គាល់ការពិត ដែលថា ពួកគេ គឺជាអ្នកបង្កើតបញ្ហា ហើយនេះបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពី *អព្ភោហារិកភាពបរិបទ* ដែលបានដកធនាគារពិភពលោក ចេញពីបញ្ជីលទ្ធភាពនៃការបញ្ចូលអថេរមួយ ទៅក្នុងភាពបរាជ័យនៃគម្រោង។ ជាលទ្ធផល "កំហុស" របស់

បុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងអ្នកស្រាវជ្រាវ ត្រូវបានកំណត់ថា ជាប្រភពនៃភាពបរាជ័យ[35] ទៅវិញ។

## ❖ សន្និដ្ឋាន៖ ចេញពីភាពបរាជ័យ មកកាន់ការស្តីបន្ទោស រួចត្រឡប់ទៅកាន់ភាពមិនចេះខុស និងជំនឿ

> ភាពស្របច្បាប់របស់ធនាគារពិភពលោក ផ្អែកលើអាជ្ញានៃទស្សនៈរបស់ខ្លួន ដូចទីក្រុងវ៉ាទីកង់ (Vatican) ដែរ ហើយក្នុងហេតុផលស្រដៀងគ្នានេះ ធនាគារពិភពលោក មិនអាចទទួលស្គាល់កំហុសរបស់ខ្លួននោះទេ (Wade 1996, 34-35)។

អត្ថបទនេះ បានរៀបរាប់ និងវិភាគប្រកបដោយការរិះគន់ទៅលើការតាក់តែងគម្រោងរបស់ធនាគារពិភពលោក ដែលមានលក្ខណៈថ្មីស្រឡាងមួយ និងគំរូជំនួយសម្រាប់ការអប់រំឧត្តមសិក្សា ដូចដែលបានអនុវត្តនៅកម្ពុជាក្នុងចន្លោះឆ្នាំ២០១០-២០១៥/១៦។ តាមរយៈការផ្តល់ហិរញ្ញប្បទានស្រាវជ្រាវដោយផ្ទាល់ ទៅឲ្យសាកលវិទ្យាល័យនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ធនាគារពិភពលោក ប៉ុនប៉ងរៀបចំប្រទេសទាំងនេះ សម្រាប់ចក្ខុវិស័យរបស់ខ្លួនស្តីពី "សេដ្ឋកិច្ចពុទ្ធិសាកល" ថ្មី។ ចេញពីចក្ខុវិស័យគោលនយោបាយដំបូង ដែលមានចែងក្នុងសៀវភៅ *កសាងសង្គមពុទ្ធិ* (Constructing Knowledge Society 2002) របស់ខ្លួន ធនាគារពិភពលោក បានដាក់ចក្ខុវិស័យនេះឲ្យដំណើរការនៅប្រទេសបង់ក្លាដែសក្នុងឆ្នាំ២០០៨ តាមរយៈ "គម្រោងពង្រឹងគុណភាពឧត្តមសិក្សា" ដែលមានផ្នែក "មូលនិធិនវានុវត្តន៍សិក្សាជាន់ខ្ពស់" បន្ទាប់មកនាំយកគំរូនេះ មកប្រទេសកម្ពុជាក្នុងឆ្នាំ២០១០ តាមរយៈ "គម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា" ដែលមានផ្នែក "ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍"។ ទោះបីជាមានចក្ខុវិស័យសាកលប្រកបដោយមហិច្ឆតា ហើយធនាគារពិភពលោក បានកៀរគរធនធានរាប់លានដុល្លារ ដើម្បីចង់សម្រេចឲ្យបានចក្ខុវិស័យនេះក៏ដោយ ការមើលចេញពីខាងក្នុងបង្ហាញឲ្យឃើញថា ការប្រឹងប្រែងរបស់ធនាគារពិភពលោកបរាជ័យក្នុងការបង្កើតឲ្យមានផលិតផលស្រាវជ្រាវ កុំថាឡើយនិយាយដល់ "នវានុវត្តន៍"។

បន្ថែមពីលើការពិពណ៌នាពីភាពលម្អិតនៃបទពិសោធន៍ច្បាស់លាស់ ដែលជាប់ពាក់ពន្ធ័នឹងរឿងរ៉ាវទាំងនេះ យើងបានរកឃើញបញ្ហាមួយ ដែលគ្របដណ្តប់លើសពីគំរូជំនួយថ្មី និងគម្រោងរបស់ធនាគារពិភពលោកជាក់លាក់ណាមួយ នោះគឺថា តើធនាគារពិភពលោក ធ្វើបញ្ញត្តិនីយកម្មបរិបទដោយរបៀបណា? ការគិតរបៀបនេះហើយ ជាអ្វីដែលនាំឲ្យមានលទ្ធផលថា "តាមពិត វិបាក គឺគ្មានអ្វីក្រៅពីភាពបរាជ័យ"។ ដើម្បីបំពេញបន្ថែមស្នាដៃសិក្សាជាន់ខ្ពស់ប្រកបដោយការរិះគន់អំពីធនាគារពិភពលោក យើងព្យាយាមប៉ុនប៉ងបង្កើតទទ្បីករណ៍ប្លែកពីគេមួយ៖ ដោយផ្អែកលើរបៀបដែលធនាគារពិភពលោក "គិត" អំពីបរិបទ វាជំរុញឲ្យមានការមើលរំលងសូម្បីអថេរបរិបទដែលសំខាន់បំផុត ប៉ុន្តែដោយសារតែធនាគារពិភពលោក មិនអាចមើលឃើញពីការចូលរួមរបស់ខ្លួនក្នុងបរិស្ថាននៃការបង្កើតគោលនយោបាយ ដាយថាហេតុ ធនាគារពិភពលោកត្រូវតែទម្លាក់កំហុសនៃភាពបរាជ័យទៅលើប្រទេសទទួលកម្ចីវិញ។ ជាលទ្ធផល នោះគឺ ធនាគារពិភពលោក កើតចេញពីរបៀបដែលខ្លួនគិត និងអត្តរូបភាពអំពីខ្លួនឯង ពីព្រោះធនាគារពិភពលោក មិនបានទទួលស្គាល់កំហុសរបស់ខ្លួនឯងឡើយ។ បើយើងមើលវានៅក្នុងកម្រិតមួយផ្សេងទៀត មន្ត្រីនៅក្នុងការិយាល័យធនាគារពិភពលោកតាមប្រទេសដែលសរសេរគម្រោងកម្ចីទៅតាមតម្រូវការ "បរិបទ" គឺមិនដែលបើកភ្នែកមើលបរិបទនោះទេ ហេតុនេះដាយថាហេតុ ធនាគារពិភពលោកនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ក៏គិតបែបនេះដែរ ដោយហេតុថា ស្នាក់ការកណ្តាលមួយនេះ មិនបានដឹងអ្វីច្រើនទេអំពីបរិបទ។ ជាការសន្និដ្ឋាន ពេលនេះយើងនឹងសង្ខេប ហើយនឹងលម្អិតអំពីទទ្បីករណ៍ដ៏ទូលំទូលាយនេះឲ្យបានច្បាស់លាស់។ ដូចដែលបានរៀបរាប់ខ្លះៗ នៅក្នុងសេចក្តី

---

[35] យើងសង្កេតឃើញថា បែបបទស្រដៀងគ្នានេះ ត្រូវបានកំណត់ក្នុងការស្រាវជ្រាវថ្មីៗ របស់ស្ថាប័ន ដូចជា អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ និងម៉ាកឃីនសី (McKinsey) ដែលការងាររបស់ពួកគេលើវិស័យអប់រំកាន់តែមានលក្ខណៈ ដូចគ្នាទៅនឹងការងាររបស់ធនាគារពិភពលោក (Auld and Morris 2016)។

ផ្តើម យើងសង្កត់ធ្ងន់ថា មិនគ្រាន់តែជាមនោគមវិជ្ជាជ្រុលនិយមនោះទេ តែយើងរកឃើញថា **ត្រៃពិធ** នៃ ១) **ការបន្ទោស** ២) **ភាពមិនចេះខុស** និង ៣) **ជំនឿ** ទៅវិញទេ ដែលជាឧបសគ្គចម្បង រារាំងមិនឲ្យអ្នកដែលនៅខាងក្នុងធនាគារពិភពលោក ផ្លាស់ប្តូររបៀបដែលស្ថាប័នអភិវឌ្ឍន៍ ដ៏មានអំណាចបំផុតនៅលើពិភពលោក "គិត"។

ទោះបីជាយ៉ាងនេះក៏ដោយ មុនពេលរៀបរាប់បែបនេះ យើងមានអារម្មណ៍ថា ត្រូវឈប់មួយភ្លែតសិន ដើម្បីឆ្លើយតបទៅនឹងការជំទាស់ទាំងឡាយណាដែលអាចកើតមាន ចំពោះការរិះគន់របស់ពួកយើង។ នៅទីនេះ អ្នកដែលមានការអាណិតអាសូរ និងឈរនៅខាងគោលនយោបាយរបស់ធនាគារពិភពលោកនឹងជំទាស់ថា គ្រប់គម្រោងទាំងអស់ ជាពិសេសសម្រាប់ការពិសោធគំរូជំនួយថ្មី តែងតែជួបប្រទះឧបសគ្គ ជួបប្រទះបញ្ហាដែលមិនបានព្រៀងទុក និងទៅមុខដោយរដាក់រដុប ប៉ុន្តែ ការរៀនសូត្រ ដែលកើតមាននៅក្នុងដំណើរការអនុវត្តគម្រោងនេះ គឺជាផ្នែកមួយនៃវឌ្ឍនភាព[36]។ "គេចាំបាច់ត្រូវ

[36] ជាការកត់សម្គាល់ ក្នុងការអនុវត្តគម្រោងលើកទី២ "គម្រោងកែលម្អការអប់រំឧត្តមសិក្សា២០១៨-២០២៤" គេហាក់មើលឃើញថា ធនាគារពិភពលោកមានការផ្លាស់ប្តូរឥរិយាបថមួយចំនួនទាក់ទងនឹងបញ្ហាដែលធ្លាប់បានជួបប្រទះក្នុងពេលអនុវត្តគម្រោងលើកទី១។ ជាពិសេស ការដកទីប្រឹក្សា និងបុគ្គលិកបរទេស ស្ទើរតែទាំងស្រុងក្នុងការអនុវត្តគម្រោងលើកទី២ នេះ ទោះបីជាពួកគេបានចូលរួមដំបូងក្នុងការបង្កើតគម្រោងក៏ដោយ។ ប៉ុន្តែ វាហាក់ដូចជាលឿនពេកក្នុងការសន្និដ្ឋានបែបនេះ បើសម្លឹងទៅមើលភាពយឺតយ៉ាវនៃការចំណាយថវិកាវិញ ចាប់តាំងពីគម្រោងដាក់ឲ្យអនុវត្តជាផ្លូវការក្នុងខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ចុងឆ្នាំ២០១៩ ការអនុវត្តគម្រោងចំណាយបានត្រឹមតែ៧,៩% នៃគម្រោងផែនការតែប៉ុណ្ណោះ។ ការណ៍នេះ នាំឲ្យធនាគារពិភពលោកចាត់ថ្នាក់ការវាយតម្លៃការអនុវត្តគម្រោងថា ស្ថិតនៅកម្រិតទី៣ មិនពេញចិត្តល្មម (កម្រិតចាប់ពីមិនពេញចិត្តខ្លាំង មិនពេញចិត្ត មិនពេញចិត្តល្មម ពេញចិត្តល្មម ពេញចិត្ត និងពេញចិត្តខ្លាំង) ទាំងវឌ្ឍនភាពសម្រេចបានគោលដៅអភិវឌ្ឍន៍គម្រោង និងវឌ្ឍនភាពនៃការអនុវត្តគម្រោងជាទូទៅ គិតមកទល់ត្រឹមថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ យកចេញពី http://documents.worldbank.org/curated/en/920931581115641265/Disclosable-Version-of-the-ISR-Cambodia-Higher-Education-Improvement-Project-P162971-Sequence-No-04 នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។ ប្រសិនមានការយល់ឃើញថា ធនាគារពិភពលោក បានរៀនសូត្រខ្លះពីគម្រោងលើកទី១មែន តើអ្វីជាមូលហេតុនៅពីក្រោយការយឺតយ៉ាវទាំងនេះ? គេអាចសម្លឹងឃើញថា ចេញពីចក្ខុវិស័យរបស់ធនាគារពិភពលោក និងអ្នកនៅក្រៅសង្វៀនអនុវត្តគម្រោង កង្វះភាពជាអ្នកដឹកនាំ ចក្ខុវិស័យ និងភាពវៃឆ្លាតរបស់ស្ថាប័នស្រុកក្នុងការគាំទ្រការអនុវត្តគម្រោង អាចរួមចំណែកធ្វើឲ្យមានភាពយឺតយ៉ាវនេះ ហេតុនេះបានប៉ះពាល់ដល់ការចំណាយថវិកាបានតិចតួច មិនតាមផែនការដែលបានគ្រោងទុក។ ដើរតាមការមើលឃើញបែបនេះ បរាជ័យលើកនេះ មិនត្រឹមតែជាកំហុសរបស់ធនាគាពិភពលោកនោះទេ តែក៏ជាកំហុសនៃថ្នាក់ដឹកនាំក្នុងស្រុកផងដែរ ហើយជាពិសេសប្រហែលជានៅតាមគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដែលជាអ្នកអនុវត្តគម្រោងដោយផ្ទាល់។ ប្រសិនបើនេះពិតជាកំហុសមែននោះ កំហុសនេះ ពិតជាងាយស្រួលក្នុងការដោះស្រាយ ប្រសិនបើថ្នាក់ដឹកនាំសម្រួចធន្ទៈ និងថាមពលក្នុងការកៀរគរធនធានបន្ថែមតែបន្តិច សម្រាប់ពន្លឿនល្បឿនក្នុងការអនុវត្តគម្រោងមួយនេះ។ ប៉ុន្តែយោងតាមបទពិសោធន៍ផ្ទាល់ខ្លួន អ្នកនិពន្ធទី២ ជឿថា បញ្ហាយឺតយ៉ាវនេះ មានភាពស្មុគស្មាញខ្លាំងជាងនេះឆ្ងាយណាស់។ លើសពីនេះទៀត អនុញ្ញាតឲ្យអ្នកនិពន្ធទី២ ពិនិត្យមើលឲ្យស៊ីជម្រៅហួសពីបញ្ហាយន្តការ និងមធ្យោបាយក្នុងការអនុវត្តគម្រោងទៅកាន់វិចារណកិច្ចនៃគម្រោងអភិវឌ្ឍន៍នេះវិញម្តង។ បើទោះជាការអនុវត្តគម្រោងមួយនេះ បានទទួលជោគជ័យ គោលបំណងចុងក្រោយនៃការស្រាវជ្រាវឧត្តមសិក្សា និងការអប់រំឧត្តមសិក្សាជាទូទៅ ដែលដាក់ចេញដោយធនាគារពិភពលោក និងដែលគ្មាននរណាចោទសួរ និងសម្រេចបានដោយស្ងៀមស្ងាត់។ នេះ ពីព្រោះតែយើងរវល់តែពិភាក្សាអំពីយន្តការ និងមធ្យោបាយ ប៉ុន្តែមិនដែលបានចោទសួរអំពីគុណផល តើអ្វីជាគោលបំណងចុងក្រោយនៃការអនុវត្តគម្រោង ការស្រាវជ្រាវ និងការអប់រំឧត្តមសិក្សាដើម្បីអ្វី? និងដើម្បីអ្នកណា? (Un, Leang, Boomsma, Lars & Sok, Say (2018). Higher Education Reform in Cambodia since 1990s: How or What?, Think, October 2018, the Head Foundation Digest; Un, Leang & Boomsma, Lars (2019). 'Higher Education' and 'Development': The World Bank in Cambodia. HESB, Issue 5, February 2019, the Head Foundation)។ នេះពីព្រោះតែក្នុងដំណើរការកសាងគម្រោងលើកទី២ ធនាគារពិភពលោក បានបង្កើតរួចជាស្រេចនូវព្រំដែនដ៏ចង្អៀតមួយសម្រាប់ឲ្យថ្នាក់ដឹកនាំឧត្តមសិក្សា ទាំងក្នុងកម្រិតនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងកម្រិតស្ថាប័នឲ្យធ្វើដំណើរ។ គេអាចមើលឃើញថា ក្នុងការតាក់តែង និងអនុវត្តគម្រោងលើកទី២នេះ វាមានការតវ៉ា និងចូលរួមច្រើនពីសំណាក់អ្នកអនុវត្តក្នុងស្រុក ប៉ុន្តែគេក៏មិនគួរបំភ្លេចពីគុណភាពនៃការចូលនេះឡើយ។ នេះវាទាក់ទងនឹងនយោបាយ និងសមត្ថភាពក្នុងស្រុក ទាំងកម្រិតក្រសួង និងកម្រិតគ្រឹះស្ថានដែលផ្តោតលើទម្រង់ជាជាងគុណភាពនៃការចូលរួម និងភាពជាអ្នកដឹកនាំដែលមានចក្ខុវិស័យ និងភាពវៃឆ្លាត ក្នុងការធានាឲ្យបាននូវគុណភាពនៃការចូលរួម ដើម្បីកែប្រែព្រំដែនដ៏ចង្អៀតមួយដែលដាក់ចេញដោយធនាគារពិភពលោក (បញ្ហានេះ នឹងមានពិភាក្សានៅក្នុងអត្ថបទដែលត្រៀមនឹងបោះពុម្ពនាពេលខាងមុខ Un, Leang & Sok, Say "(Higher) Education Policy and Project Intervention in Cambodia: Its Development Discourse"។ ពាក្យ ភាពជាអ្នកដឹកនាំ ចក្ខុវិស័យ និងភាពវៃឆ្លាតដែលអ្នកនិពន្ធទី២ ប្រើប្រាស់ក្នុងពេលនេះ គឺមានន័យខុសពីបុគ្គលិកធនាគារពិភពលោក ដែលកំពុងប្រើប្រាស់ដែលអ្នកនិពន្ធទី២ បានឮ ជាច្រើនលើកច្រើនសា នៅក្នុងពេលបើក ឬបិទសិក្ខាសាលា ឬក្នុងអង្គប្រជុំនានា។ សម្រាប់បុគ្គលិកធនាគារពិភពលោក ភាពជាអ្នកដឹកនាំ ចក្ខុវិស័យ និងភាពវៃឆ្លាត សំដៅលើគុណភាពប្រាជ្ញារបស់ថ្នាក់ដឹកនាំ និងបុគ្គលិកតាមអង្គភាពអនុវត្តន៍ក្នុងការស្វែងរកយុទ្ធសាស្ត្រអនុវត្តគម្រោងឲ្យបានជោគជ័យ។ សម្រាប់អ្នកនិពន្ធទី២ និយមន័យបែបនេះមានលក្ខណៈចង្អៀតណាស់ ដែលមិនមានចន្លោះប្រហោងណាមួយសម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកតាមអង្គភាពអនុវត្តន៍ប្រើប្រាស់

តែចាប់ផ្ដើមពីកន្លែងណាមួយ តើត្រូវទេ?” នោះ គឺជាការឆ្លើយតបទូទៅ។ ការពិត យើងបានឮបែបនេះជាច្រើនលើកច្រើនសារនៅទីក្រុងភ្នំពេញ។ យើងអាចយល់ស្របថា ការគាំទ្រពីសំណាក់អន្តរជាតិនៅតែអាចទៅរួច ហើយការងារបែបនេះត្រូវតែ “ចាប់ផ្ដើមពីកន្លែងណាមួយ” ដោយជៀសមិនផុត។ ប៉ុន្តែ យោបល់ដែលយើងផ្ដល់ឲ្យជាយុទ្ធសាស្ត្រដ៏សាមញ្ញ សម្រាប់រយៈពេលវែងឆ្ងាយ និងលើសពីអ្វីៗទាំងអស់ គឺយុទ្ធសាស្ត្រដែលពឹងផ្អែកលើតថភាពនៃបរិបទ។ ឧទាហរណ៍ ហេតុអ្វីមិនព្រមចំណាយថវិកា ៤,៥៨ លានដុល្លារសហរដ្ឋអាមេរិក ផ្ដល់ទៅឲ្យអ្នកស្រាវជ្រាវកម្ពុជាវ័យក្មេងប្រកបដោយសក្ដានុពលនៅសាកលវិទ្យាល័យឈានមុខគេ ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ទៅបន្តការសិក្សាថ្នាក់បណ្ឌិត? ហេតុអ្វីមិនចំណាយថវិកាអនុវត្តគម្រោងស្រាវជ្រាវថ្នាក់ក្រោយបណ្ឌិត ដែលផ្ដល់ថវិកាឲ្យអ្នកមានសញ្ញាបត្របណ្ឌិតប្រកបដោយសក្ដានុពល និងមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការស្រាវជ្រាវ ដើម្បីជួយបង្កើតឡើងវិញនូវចលនាបញ្ញវន្ត និងអ្នកអាជីពកំពូលដែលជាស្នូលនៃឧត្តមសិក្សា? ហេតុអ្វីបានជាមិនចំណាយថវិកាដាក់លាក់មួយផ្នែកណានោះនៃគម្រោងក្នុងការបង្កើតវេទិកាថ្នាក់ជាតិ សម្រាប់អ្នកស្រាវជ្រាវកម្ពុជាឈានមុខគេដើម្បីគិតពីអាទិភាពផ្ទាល់ខ្លួនរបស់ពួកគេអំពីកំណែទម្រង់ឧត្តមសិក្សា ជាជាងចំណាយថវិកាក្នុងការជួលទីប្រឹក្សារបស់ធនាគារពិភពលោក ពីចម្ងាយដ៏ឆ្ងាយមកបង្កើតអាទិភាពបែបនេះសម្រាប់កម្ពុជា និងសម្រាប់អ្នកស្រាវជ្រាវកម្ពុជា? ជាជាងភ្ជាប់កម្ពុជាទៅនឹង “សេដ្ឋកិច្ចពុទ្ធិសាកល” ហេតុអ្វីបានជាមិនចំណាយថវិកាឲ្យមានការគិតគូរពេញលេញអំពីវិបាកនៃការបំផ្លាញទាំងស្រុងរបស់ខ្មែរក្រហម សង្គ្រាមស៊ីវិលមួយទសវត្សរ៍បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ និងឲ្យច្បាស់ថែមទៀតទៅលើផលប៉ះពាល់ដែលថវិកាជំនួយបរទេសរាប់ពាន់លានដុល្លារសហរដ្ឋអាមេរិក មានមកលើគោលនយោបាយ អាទិភាព និងចក្ខុវិស័យរបស់ប្រទេសមួយនេះ?[37]

លើសពីនេះ ប្រសិនបើមានការតាំងចិត្តដ៏ស្មោះត្រង់ពិតប្រាកដមែននោះ ហេតុអ្វីមិនដកគោលការណ៍ដំណើរការលទ្ធកម្ម និងហិរញ្ញវត្ថុរបស់ធនាគារពិភពលោក ពីគម្រោងស្រាវជ្រាវរបស់សាកលវិទ្យាល័យ។ ការស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យមិនមែនធ្វើដំណើរពីចំណុច **ក** ទៅចំណុច **ខ** ដោយត្រង់ដូចដែលគណនេយ្យករបានរំពឹងគិតទុកជាមុននោះទេ។ “នវានុវត្តន៍” មិនមែនលេចឡើងដូចការអភិវឌ្ឍ ដែលមានផែនការរួចស្រេចនោះទេ។ វាជាការណ៍ដ៏គួរឲ្យហួសចិត្ត ដែលធនាគារពិភពលោក ធ្លាប់តែមិនចូលចិត្តការធ្វើផែនការ ប៉ុន្តែតាមរយៈនីតិវិធីលទ្ធកម្ម និងហិរញ្ញវត្ថុ ចង់ធានាថា គំរូថ្មីដែលប៉ុនប៉ងនាំមកនូវនវានុវត្តន៍លេចឡើងដូចបានគ្រោងទុក។ ការរៀបដាក់ឲ្យ “ការអភិវឌ្ឍ និង នវានុវត្តន៍” នៅជាមួយគ្នា គឺជារឿងចម្លែកបំផុត។ អនុសាសន៍សម្រាប់ការកែលម្អរបស់យើង គឺផ្ដោតទៅលើការចាប់យកយុទ្ធវិធីអនុមានរួម ដែលអនុញ្ញាតឲ្យអ្នកគិតកម្ពុជា អាចឆ្លើយនឹងសំណួរអ្វីជាតម្រូវការរបស់ពួកគេ ហើយថាតើអនាគតគួរតែបែបណា។

យើងត្រូវតែទទួលស្គាល់ផងដែរថា មិនមែនគ្រប់អនុគម្រោងនៃគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍សុទ្ធតែបរាជ័យទាំងអស់នោះទេ។ ការពិត មានការស្រាវជ្រាវខ្លះដែលទទួលបាន “ជោគជ័យ” បានកើតឡើងផងដែរ។ ជាតឹកតាង នៅចុងបញ្ចប់នៃការអនុវត្តគម្រោងក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ អនុគម្រោងចំនួន៩ ត្រូវបានផ្ដល់ជូននូវពានរង្វាន់ជាផ្លូវការ។ នៅផ្ទៃក្នុងធនាគារពិភពលោក គម្រោងទាំងនេះ

ប្រាជ្ញាក្នុងការបង្កើត និងចោទសួរអំពីវិចារណកិច្ចអភិវឌ្ឍន៍របស់គម្រោង និងតក្កវិជ្ជានៅពីក្រោយការតាក់តែងគម្រោង ថាតាមពិត គម្រោងត្រូវបានតាក់តែងដោយខុសក្បួននោះទេ។ លើសពីនេះទៀត ថ្មីៗនេះ ធនាគារពិភពលោកបានដើរតាមគន្លងចាស់ គឺនៅពេលការអនុវត្តគម្រោងមានសភាពយឺតយ៉ាវ ធនាគារពិភពលោកបានចាប់ផ្ដើមជួលទីប្រឹក្សាបរទេសបន្ថែមមកជួយជំរុញល្បឿនអនុវត្តន៍គម្រោងដើម្បីសម្រេចឲ្យបានវិចារណកិច្ចអភិវឌ្ឍន៍របស់ខ្លួនដែលបានដាក់ចេញ ខណៈដែលគេនៅតែមិនទាន់ឃើញមានការចោទសួរឡើងវិញពីសំណាក់ភ្នាក់ងារអនុវត្តន៍ក្នុងស្រុកនៅឡើយទៅលើកិច្ចការទាំងអស់នេះរបស់ធនាគារពិភពលោក។

[37] គេឃើញមានការឆ្លើយតបខ្លះៗ ចំពោះសំណួរបែបនេះនៅក្នុងគម្រោងទី២ ប៉ុន្តែប្រហែលជាមិនមានលក្ខណៈជាប្រព័ន្ធច្បាស់លាស់នៅឡើយ។ ជាពិសេស សំណួរស្នូលខាងលើ ការស្រាវជ្រាវ និងការអប់រំឧត្តមសិក្សាដើម្បីអ្វី និងដើម្បីអ្នកណានៅតែអវត្តមានដដែល។

ត្រូវបានគេបង្ហាញ និងលើកយកមកនិយាយនៅក្នុងវេទិកាជាច្រើន ដើម្បីធ្វើឲ្យគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍មើលទៅឃើញថា "ជោគជ័យ" មែនទែន។ ប៉ុន្តែ គម្រោងផ្តល់ពានរង្វាន់នេះ តាមពិត គឺត្រូវបានរៀបចំដោយអ្នកនិពន្ធទាំងពីនាក់នេះទេ ហើយវាគ្រាន់តែជាផែនការលើកទឹកចិត្តដល់អនុគម្រោងណាដែលបានបញ្ចប់ទាន់ពេលវេលាតែប៉ុណ្ណោះ[38]។ វាផ្អែកតែទៅលើលក្ខខណ្ឌដូចជា ១) បញ្ចប់ទាន់ពេល និង ២) ចំណាយថវិកាដែលបានគ្រោងទុកអស់។ ចំនួននៃពានរង្វាន់ ត្រូវបានកំណត់ជាមុន ហេតុនេះវា ហាក់ឃើញថា មានភាពជោគជ័យក្នុងចំណោមអនុគម្រោងចំនួន ៤៥ ចំណុចដែលធនាគារពិភពលោក នៅតែរក្សាភាពស្ងប់ស្ងាត់។ លើសពីនេះ អនុគម្រោង ដែលជោគជ័យមែនទែន តាមលក្ខណៈស្រាវជ្រាវជាន់ខ្ពស់ (យើងគិតថា មានត្រឹមតែ៣ ប៉ុណ្ណោះ) ដើម្បីគាំទ្រករណីទូទៅរបស់យើង៖ អនុគម្រោងទាំង៣ នេះចាប់ផ្តើមជាមួយអ្នក ដែលបានទទួលការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និង/ឬមានអ្នកជំនាញលទ្ធកម្មពេញម៉ោងសម្រាប់អនុគម្រោង ដែលបង់ប្រាក់ខែដោយសាកលវិទ្យាល័យរបស់ពួកគេ។

ត្រឡប់មកកាន់ទឡ្ហីករណ៍ដ៏ទូលំទូលាយរបស់យើងវិញម្តង នៅពេលអ្នកសិក្សាជាន់ខ្ពស់ជាច្រើននៅតែបារម្ភថា ផ្ទត់គំនិតបរិបទ នៅតែតាមលងធនាគារពិភពលោកជានិច្ច យើងចង្អុលបង្ហាញថា គឺមានតែតាមរយៈការពិនិត្យមើលយុទ្ធវិធីរបស់ធនាគារពិភពលោក អំពីបរិបទនៅក្នុងកម្រិតដ៏ជ្រៅទេ ទើបយើងអាចមើលឃើញពីឫសគល់នៃភាពបរាជ័យនៃគោលនយោបាយ។ រហូតមកទល់ពេលនេះ ការយល់ដឹងពីវេយ្យាករណ៍គ្រឹះ និងស៊ីជម្រៅនៃរបៀបដែលធនាគារពិភពលោក "គិត" បែបនេះ មិនមែនជាចំណុចដៅដ៏ចម្បងនៃការរិះគន់ប្រកបដោយការសិក្សាជាន់ខ្ពស់ក្នុងការស្រាវជ្រាវអប់រំនោះទេ[39]។ ដើម្បីបង្កើតការស្រាវជ្រាវប្រកបដោយការរិះគន់ តាមការគិតបែបនេះជាថ្មីឡើងវិញ យើងកំពុងអះអាងថា យុទ្ធវិធី *ប្រភេទសព្វបរិបទទូទៅ* គឺជាប្រភពនៃភាពបរាជ័យគោលនយោបាយ ខណៈពេលដែល *អព្វោហារិកភាពបរិបទ* បានប្រែក្លាយភាពបរាជ័យ ឲ្យទៅជាការបន្ទោស។ *ប្រភេទសព្វបរិបទទូទៅ* បង្កើតបរិបទទូទៅដោយការធ្វើអនុមានញែកចេញពីជាតុរូមនៃសូចនាករបែបឧត្តមគតិ ដែលមិនដែល ផ្ចិតយករូបភាពអ្វីទាំងអស់ ក្រៅតែពីការយល់ឃើញទុកជាមុនរបស់អ្នកអង្កេត។ ហេតុនេះ វានាំឲ្យមានការមើលរំលង សូម្បីតែកត្តាបរិបទដ៏ធំ និងសំខាន់បំផុត ហើយនិងសូម្បីតែអ្វីមួយដែលច្បាស់ក្រឡែត ដូចជាផលប៉ះពាល់ពីរបបខ្មែរក្រហម មកលើការអប់រំឧត្តមសិក្សានៅកម្ពុជា។ ប្រសិនបើសោកនាដកម្មបែបនេះ អាចឆ្លងផុតប្រព័ន្ធនៃការគិត (របស់ធនាគារពិភពលោក) វាមិនពិបាកទេដែលថា អ្វីៗផ្សេងទៀត ក៏រំលងផុតពីប្រព័ន្ធនៃការគិតបែបនេះដែរ។ ដូចយើងបានលើកឡើងតាំងពីដំបូងក្នុងសេចក្តីផ្តើមរួចហើយថា អ្នកស្រាវជ្រាវសង្គមសាស្ត្របានរិះគន់យុទ្ធវិធីឧត្តមគតិនេះថា ពោរពេញដោយកំហុស និងគ្រោះថ្នាក់បំផុត ដូចអ្វីដែល លោក អែលហ្វ្រែដ ស្មុត បានព្រមានយើងថា វាធ្វើឲ្យយើងខ្វាក់ភ្នែកមើលមិនឃើញកំហុសដែលវាបានបង្កើតឡើង។

ក្នុងផ្នែកមួយដ៏ធំ *អព្វោហារិកភាពបរិបទ* គឺចេញមកពីហេតុដែលថា *ប្រភេទសព្វបរិបទទូទៅ* មិនដែលបញ្ចូលពីរបៀបដែលធនាគារពិភពលោកខ្លួនឯងជះឥទ្ធិពលលើបរិបទនោះទេ។ ឧទាហរណ៍ខាងលើ ដែលយើងពិនិត្យមើល រួមមានភាពតឹងរ៉ឹងបំផុតនៃក្រឹត្យក្រមលទ្ធកម្មរបស់ធនាគារពិភពលោក និង

[38] គម្រោងផ្តល់ពានរង្វាន់នេះ មិនមាននៅក្នុងការតាក់តែងគម្រោងដើមដែលរៀបចំដោយធនាគារពិភពលោកនោះទេ។

[39] សម្រាប់ការរិះគន់បន្ទាប់បន្សំសូមមើល Klees and Edwards (2014), Verger, Edwards, and Altinyekan (2014), Heyneman (2003) និង Jones (2007)។ នៅក្រៅវិស័យអប់រំ សូមមើលផងដែរ Broad (2006) និង Wade (1996)។ ដោយខ្លាចគ្រោះថ្នាក់នៃការធ្វើទូទៅនីយកម្មហួសហេតុ ការរិះគន់ទាំងនេះច្រើនតែផ្តោតតែទៅលើមនោគមវិជ្ជា និងរបៀប/មធ្យោបាយសម្ភារៈ ដែលមានឥទ្ធិពលលើការរក្សារបបនៃការគិត។ នៅក្នុងន័យម្យ៉ាងវិញទៀត គឺគ្រាន់តែលម្អិតមនោគមវិជ្ជា និងអំពីទិដ្ឋភាពតថនិយម/សម្ភារនិយម។ ការពិតបញ្ហានេះ វានៅតែមានសារសំខាន់។ ផ្ទុយទៅវិញ កិច្ចការរបស់យើង គឺផ្តោតលើរចនាសម្ព័ន្ធនៃគំនិតដ៏ជ្រៅ (ប្រហែលនរណាម្នាក់អាចនិយាយថាជា វប្បធម៌) និងដោយឡែកដែលយុទ្ធវិធីបែបនេះបានបង្កើត៖ យុទ្ធវិធីអនុមានញែក ការសន្មតនៃនិយាមវិទ្យាសាស្ត្រដាច់ខាត និងពីមូលបដិញ្ញាភាវវិទ្យានៃវត្ថុវិស័យរូបធាតុ ដូចដែលនឹងបានរៀបរាប់ខាងក្រោម។ សម្រាប់ការពិភាក្សាបន្តទៀត អ្នកអានអាចមើល Rappleye and Komatsu (2017)។

របៀបដែលនិយាមរបស់ធនាគារពិភពលោក បានដាក់ចេញ ធ្វើជាលក្ខខណ្ឌចាំបាច់ ដែលតម្រូវឲ្យអ្នកស្រាវជ្រាវកម្ពុជា ធ្វើការដោយមិនបានប្រាក់កម្រៃ។ នីតិវិធី និងនិយាមទាំងនេះ គឺជាវត្ថុវិស័យ "ដែលផ្តល់ឲ្យ" តាមការមើលឃើញរបស់ធនាគារពិភពលោកទៅលើពិភពលោក។ ធនាគារពិភពលោក មិនដែលមានការគិតគូរយ៉ាងម៉ត់ចត់ទេថា បុព្វហេតុនៃយន្តការបែបនេះ នឹងធ្វើឲ្យការរៀបចំគម្រោងមួយចំនួន មិនអាចទៅរួច។ អាស្រ័យហេតុនេះ អ្វីៗទាំងអស់ *លើកលែងតែ* ធនាគារពិភពលោក សុទ្ធតែក្លាយទៅជាអថេរក្នុងការស្វែងយល់ពីបរាជ័យ ឧទាហរណ៍ អ្វីៗទាំងអស់ គឺជាកំហុសខាងកម្ពុជា។ ខណៈដែលគំនិតបែបនេះ គឺជាចំណុចចាប់ផ្តើម វានាំទៅដល់ការស្តីបន្ទោសដោយជៀសមិនផុត។ ឧទាហរណ៍ កង្វះអ្នកមានសញ្ញាបត្របណ្ឌិត បានក្លាយទៅជាបរាជ័យរបស់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ក្នុងការផ្តល់ការគាំទ្របច្ចេកទេស ឬសិក្ខាសាលាអំពីវិធីសាស្ត្រស្រាវជ្រាវឲ្យបានគ្រប់គ្រាន់ *ដែលនេះមិនមែនជាបញ្ហា ដែលបង្កើតឡើងដោយរបៀបរៀបចំគម្រោងដំបូងនោះទេ។* បរាជ័យក្នុងការដោះស្រាយបញ្ហាលទ្ធកម្ម បានក្លាយជាបរាជ័យនៃឆន្ទៈក្នុងចំណោមអ្នកដឹកនាំសាកលវិទ្យាល័យ និងនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំក្នុងការបំពេញការងារបណ្តុះបណ្តាល និងគាំទ្រកិច្ចការលទ្ធកម្មនេះ[40]។ បរាជ័យនៅក្នុងការធ្វើលទ្ធកម្ម *មិនត្រូវបានគិតថា* ជាលទ្ធផលនៃភាពចម្រូងចម្រាសរវាងសេដ្ឋកិច្ចវិទូធនាគារពិភពលោក និងអ្នកជំនាញខាងអភិវឌ្ឍន៍ធនធានមនុស្សនោះទេ ដែលជាបញ្ហាខាងធនាគារពិភពលោកសុទ្ធសាធ។

នៅពេលអ្នកនិពន្ធទី២ ដែលជាអ្នកដឹកនាំគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ បានតវ៉ាថា រាល់ការបណ្តុះបណ្តាល និងការងារលទ្ធកម្មទាំងអស់ បានស្រូបយកអស់ពេលវេលាជាច្រើន ពីបុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ (ទោះយ៉ាងណាក៏ដោយ ពួកគេត្រូវតែធ្វើការងារស្នូលរបស់ពួកគេ)[41] ធនាគារពិភពលោក បានចោទម្តងហើយម្តងទៀតថា បុគ្គលិកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ ធ្វេសប្រហែស "មិនយកចិត្តទុកដាក់នឹងភារកិច្ចរបស់ខ្លួន"[42] ហើយបានដាក់ទណ្ឌកម្មដោយផ្ទាល់តាមរយៈការដក "ប្រាក់លើកទឹកចិត្ត" តិចតួចដែលនៅសល់មកពីការតាក់តែងគម្រោងដំបូង ដូចជា ការធ្វើដំណើរក្រៅប្រទេសសម្រាប់ "ការកសាងសមត្ថភាព" គម្រោងវិបស្សនានៅមាត់សមុទ្រ ដើម្បីដកស្រង់បទពិសោធន៍ជាដើម។ល។ ពួកអ្នកសង្ស័យនិយម អាចចោទជាសំណួរថា តើយើងមានចិត្តសប្បុរសមកលើកម្ពុជាពេក ឬយ៉ាងណាមកលើកម្ពុជា ប៉ុន្តែក្នុងរយៈពេល២ឆ្នាំ ដែលអ្នកនិពន្ធទី១ បានធ្វើការជាមួយនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងសាកលវិទ្យាល័យ វាច្បាស់ណាស់ថា នៅខាងកម្ពុជាភាគច្រើនបំផុត បានព្យាយាមធ្វើអ្វី ដែលពួកគេអាចធ្វើបានអស់ពីសមត្ថភាព និងលទ្ធភាពហើយ[43]។ នៅពីក្រោយទ្វារដែលបិទជិត អ្នកនៅក្នុងការិយាល័យធនាគារពិភពលោក ជាញឹកញាប់ លាបពណ៌ពួកគេថា ជាអ្នកដែល "គ្មានសមត្ថភាព" "គ្មានឆន្ទៈ" និងម្តងម្កាលថា "ពុករលួយ"។ នេះមិនមែនមាន

[40] បញ្ហាដែលគេនៅតែឃើញមាននៅក្នុងការអនុវត្តគម្រោងលើកទី២។ ការណ៍ដែលមិនអាចធ្វើលទ្ធកម្មបានលើការជួសជុស ការសាងសង់ និងការបញ្ជាទិញសម្ភារពិសោធន៍ តាមផែនការសកម្មភាពប្រចាំឆ្នាំបាន គឺបណ្តាលមកពីកង្វះឆន្ទៈ និងការតាំងចិត្តរៀនសូត្រអនុវត្តរបស់បុគ្គលិកគម្រោងនៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ និងគ្រឹះស្ថានឧត្តមសិក្សា។

[41] បញ្ហានេះនៅតែកើតមាននៅក្នុងការអនុវត្តគម្រោងលើកទី២ តែលើកនេះ វាកើតមានផងដែរនៅកម្រិតគ្រឹះស្ថានឧត្តមសិក្សា ដោយហេតុថា ពួកគេជាអ្នកអនុវត្តន៍ផ្ទាល់ ហើយស្ថិតនៅក្រោមការសម្របសម្រួលរបស់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ។ ប៉ុន្តែ ក៏មានការលើកទឹកចិត្តឲ្យធ្វើការបូកបញ្ចូលការងារគម្រោងជាមួយការងារស្នូលរបស់ស្ថាប័នទាំងមូលផងដែរ។ វាស្ថិតនៅក្នុងដំណាក់កាលដំបូង ដែលយើងមិនអាចវាយតម្លៃទៅលើសមត្ថភាព និងទម្ងន់ការងារដែលបានមកពីការបូកបញ្ចូលគ្នានេះ ថាតើវាមានគុណភាពបែបណា និងថាតើវាហួសពីលទ្ធភាពរបស់ពួកគាត់ក្នុងការអនុវត្តដែរ ឬទេ?

[42] សំឡេងបែបនេះ នៅតែបន្តឮរហូតដល់ពេលបច្ចុប្បន្ននេះ ក្នុងបេសកកម្មតាមដានវាយតម្លៃដំណើរការអនុវត្តគម្រោងលើកទី២។

[43] ការអង្កេតដែលនៅតែត្រឹមត្រូវរហូតមកទល់ពេលនេះ ក្នុងការអនុវត្តគម្រោងលើកទី២។ ម្នាក់ៗ បានប្រឹងប្រែងធ្វើកិច្ចការនេះអស់ពីសមត្ថភាព និងលទ្ធភាពរបស់ពួកគេ អ្នកខ្លះបានធ្វើការហួសម៉ោងការងារកំណត់ជាផ្លូវការទៀតផង។

ន័យថា យើងបដិសេធថា គ្មានអំពើពុករលួយនៅកម្ពុជានោះទេ (Brehm 2018) ប៉ុន្តែអ្វីដែលយើងចង់សង្កត់ធ្ងន់នៅទីនេះ គឺថាជាញឹកញាប់ ការលាបពណ៌ទាំងនេះ ត្រូវបានប្រើដើម្បីដកការពន្យល់ពីបញ្ហាដែលចាក់ឫសយ៉ាងជ្រៅក្នុងការរៀបចំរចនាសម្ព័ន្ធ ដែលក្នុងករណីនេះ គឺ**ការរៀបចំគម្រោងខុសក្បួន**។

អ្វីដែលជាការបារម្ភជាងនេះទៅទៀត គឺថា ប្រសិនបើយើងដកឃ្លាបន្តិច អ្វីទាំងអស់នេះមានន័យថា វានឹងមិនមានចន្លោះប្រហោងណាមួយ សម្រាប់កំណែទម្រង់ជាសារវន្តអំពី "ការគិត" របស់ធនាគារពិភពលោកនោះទេ។ ដូចដែលយើងបានឃើញ ធនាគារពិភពលោក ហាក់មិនផ្តោតការយកចិត្តទុកដាក់ (ឬបំភ្លេចចោល) ស្នាដៃសិក្សាជាន់ខ្ពស់ដ៏សម្បូរបែប ដើម្បីយល់ពីបរិបទ (អប់រំ) ទោះជាក្នុងករណីជាក់លាក់នៅកម្ពុជា ក៏ដូចជាករណីទូទៅអំពីវិធីសាស្ត្រស្រាវជ្រាវរបស់សង្គមសាស្ត្រ ដូចដែលបានពិភាក្សាកន្លងមក។ ស្របជាមួយគ្នានេះ ធនាគារពិភពលោក ដំណើរការជាវប្បធម៌ស្ថាប័ន ដែលពិបាកក្នុងការទទួលស្គាល់កំហុសអតីតកាលរបស់ខ្លួន និងភាពបរាជ័យនៅតាមប្រទេសដែលខ្លួនបានធ្វើការ ពីព្រោះបញ្ហាទាំងអស់នេះត្រូវបានបំប្លែងទៅជាការបន្ទោស ដែលយើងអាចមើលឃើញយ៉ាងច្បាស់រួចមកហើយ។ ហេតុនេះ ការសន្និដ្ឋានរបស់យើង ដែលកើតចេញពីខាងក្នុង គឺថាបច្ចុប្បន្ននេះ ស្ថាប័ននេះហាក់ដូចជាមិនមានសមត្ថភាពរៀនសូត្រទាល់តែសោះ។ នេះគឺជាកោសល្យវិច័យមួយ ដែលមិនមាននរណាម្នាក់រំពឹងទុកសម្រាប់ "ធនាគារពុទ្ធិសាកល" ដែលព្យាយាមដឹកនាំពិភពលោក ក្នុងវិស័យសិក្សាជាន់ខ្ពស់ ការស្រាវជ្រាវ និងនវានុវត្តន៍។

ប៉ុន្តែ ប្រសិនបើ ធនាគារពិភពលោក បរាជ័យទាំងក្នុងការប្រើប្រាស់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ទៅលើបរិបទ ភាពជាក់លាក់របស់បរិបទ ឬការឆ្លុះបញ្ចាំងពីគោលនយោបាយដែលបរាជ័យក្នុងអតីតកាល ហេតុនេះយើងត្រូវតែចោទសួរថា *អ្វី* ទៅដែលជំរុញចក្ខុវិស័យគោលនយោបាយធនាគារពិភពលោក និងការរៀបចំតាក់តែងគម្រោង? នៅទីនេះ យើងសុំឲ្យអ្នកអានផ្តោតទៅលើថា តើបញ្ញត្តិជំនឿ និងភាពមិនចេះខុស អាចជាបញ្ញត្តិដែលមានប្រយោជន៍ ក្នុងការវិភាគនៅថ្ងៃមុខ ដើម្បីឲ្យយល់បានកាន់តែស៊ីជម្រៅពីចរិកបែបពាក់កណ្តាលសាសនា ដែលមានជាប់រហូតមកនៅក្នុងស្ថាប័នមួយនេះ (Rappleye 2018; Rist 1997)។ បទពិសោធន៍របស់យើង បង្ហាញប្រាប់យើងថា អ្វីដែលជំរុញចក្ខុវិស័យរបស់ធនាគារពិភពលោក និងការរៀបចំតាក់តែងគម្រោង ការពិតគឺ *ជំនឿ*៖ ជំនឿនៅក្នុងធនាគារពិភពលោកអំពីភាពមិនចេះខុសរបស់ខ្លួន ដែលត្រូវបានជំរុញដោយជំនឿធំជាងនេះនៅក្នុងតក្កវិជ្ជាទូទៅអំពី "ការអភិវឌ្ឍ"។ ជំនឿ បានបង្ហាញពីការជឿជាក់ដ៏មុតមាំ ជំនឿដែលជាប់នឹងសាសនាជ្រុលនិយម (សម្រាប់យើង ការពិតជំនឿចេញពីគម្ពីរសាសនានេះឯង) ដែលមានអំណាចខ្លាំងមែនទែន និងដែលជំនឿបែបនេះជឿថា ខ្លួនមានសមត្ថភាពក្នុងការបង្កើតតថភាព។

នៅខាងក្នុងធនាគារពិភពលោក ជាពិសេស ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងនៅការិយាល័យតាមប្រទេសដែលធនាគារពិភពលោកដំណើរការ យើងជួបបុគ្គលិកជាច្រើន ដែលច្រានចោលការជាប់ពាក់ព័ន្ធទៅនឹងនវសេរីនិយមជ្រុល (Neo-liberal Foundamentalism) និងជំនឿកម្លាយប្រភេទថ្មីៗ ដែលចេញពីនវសេរីនិយមជ្រុលនិយម។ ទោះតិច ឬច្រើន ភាគច្រើននៃអ្នកទាំងនេះអាចមើលឆ្លុះពីចរិតមនោគមវិជ្ជារបស់ធនាគារពិភពលោកដែលខ្លួនកំពុងបម្រើ។ មូលហេតុដែលពួកគេនៅបន្តធ្វើការនៅធនាគារពិភពលោក ពីព្រោះពួកគេជឿថា "ការអភិវឌ្ឍ" គឺជាអ្វីដែលមិនត្រូវចោទសួរ។ ទោះបីជាមានឧបសគ្គ រដាក់រដុប និងទៅមុខទៅក្រោយ ជួនកាលពួកគេអះអាងដោយទឹកចិត្តថា ត្រូវតែជំនះឲ្យបាន។ នេះគឺជារឿងត្រឹមត្រូវ ដែលត្រូវបន្តទៅមុខទៀត ក្នុងការឆ្លើយតបទៅនឹងការបន្តបារម្ភរបស់ពួកយើងអំពីគម្រោងដែលបរាជ័យ[44]។

[44] ការសន្និដ្ឋាន ដែលនៅតែមានសុពលភាព មិនគ្រាន់តែសំដៅលើបុគ្គលិកធនាគារពិភពលោកប៉ុណ្ណោះទេ តែសម្រាប់មន្ត្រីកម្ពុជាខ្លះផងដែរ ដែលធ្វើការមិនចេះហត់នឿយ និងយ៉ាងសកម្មជាមួយធនាគារពិភពលោក ក្នុងការតម្រង់ទិសគ្រឹះស្ថានឧត្តមសិក្សា និងអ្នកស្រាវជ្រាវកម្ពុជា។

ប៉ុន្តែបុគ្គលិកទាំងនេះ តែងតែដាក់គោលនយោបាយ "អភិវឌ្ឍន៍" ថាជានិយាមវិទ្យាសាស្រ្តដាច់ខាត និងមូលបដិញ្ញាតក្កវិជ្ជាឯក[45] (Monological Premises) ដោយមិនមានការភ្ញាក់រឭក។ នោះ គឺថា វេយ្យាករណ៍ជាមូលដ្ឋាននៃការគិតតែមួយគត់ គឺវាត្រូវតែមានចម្លើយដែលត្រឹមត្រូវ*មួយ* ("គំរូអនុវត្តន៍ល្អ") ដែលអាចអនុវត្តបាននៅទូទាំងពិភពលោក និងនៅគ្រប់ពេល (ត្រឹមត្រូវគ្រប់កាល និងលំហ)។ ការគិតបែបនេះហើយ គឺជាអ្វីដែលធ្វើឲ្យយុទ្ធវិធីអនុមានញែករបស់ធនាគារពិភពលោក អាចដំណើរការទៅបាន។ យុទ្ធនាការស្វះស្វែងរកឲ្យឃើញជាមុន បន្ទាប់មកអនុវត្ត "ច្បាប់" រំលងប្រវត្តិសាស្រ្តនេះ គឺជាការជំរុញទឹកចិត្ត និងជាគោលដៅគន្លឹះដែលយើងតែងតែជួបប្រទះជាញឹកញាប់នៅក្នុងការគិត និងដំណើរការរបស់ធនាគារពិភពលោក។ មកដល់កន្លែងនេះ យើងកំពុងផ្តល់ជម្រើសសម្រាប់ការពន្យល់បែបសេដ្ឋកិច្ចនយោបាយ ដើម្បីស្វែងយល់ពីការត្រួតត្រានៃអំណាចសេដ្ឋកិច្ច និងសេដ្ឋកិច្ចវិទូក្នុងផ្នែកអភិវឌ្ឍន៍ធនធានមនុស្សរបស់ធនាគារពិភពលោក៖ គឺមុខវិជ្ជាសង្គមសាស្រ្តដែលអាចក្លាយជាអំណះអំណាងដែលកៀកបំផុតថាជានិយាមវិទ្យាសាស្រ្តដាច់ខាត (ដោយលក្ខណៈនៃច្បាប់ផ្គត់ផ្គង់ និងតម្រូវការ)។ ហេតុដូចនេះ ជាជាងឲ្យនយោបាយនវសេរីនិយមដើរតួសំខាន់ សេដ្ឋកិច្ចវិទូល្បីៗនៅក្នុងធនាគារពិភពលោក បានដើរតួនាទីចម្បងក្នុងការរំលេចឲ្យឃើញពីវប្បធម៌នៃនិយាមវិទ្យាសាស្រ្តដាច់ខាតនេះ។

អ្វីដែលជំនួសការបើកចំហ ទៅជាការជំរុញពីខាងក្រៅ និងការរៀនសូត្ររបស់ធនាគារពិភពលោក គឺជាជំនឿអត្ថិភាពនៃភាព*ល្អ* ការណ៍ដែលខ្លួនមានគុណភាពមួយដែលមានលក្ខណៈដូចទៅនឹងទេវនៅក្នុងភាពស្មោះត្រង់ ភាពមិនចេះខុស និងចរិតដាច់ខាតរបស់ខ្លួន។ ជាជាងឧត្តមភាពរបស់ លោក វេប័រ ដែលបានមកពីការប្រែប្រួលទៅរកសកម្មភាពសង្គមជាចម្បង *(Verstehen)* ធនាគារពិភពលោក សម្លឹង "ទៅលើ"។ ជាជាងការចរចារជាមួយភាពស្មុគស្មាញដែលកើតចេញពីតថភាពដែលកំពុងមានចលនាជានិច្ច និងការព្យាយាមកសាងគំនិតធនាគារពិភពលោក បែរភ្នែករបស់ខ្លួនចេញពីប្រវត្តិសាស្រ្ត និងតម្រង់ត្រង់ឆ្ពោះទៅរក "អនាគត"។ ប៉ុន្តែ នៅពេលដែលសច្ចភាព "នៅលើ" ហើយមិនមែន "នៅទីនោះ" ការវិនិយោគយ៉ាងសន្ធឹកសន្ធាប់របស់ធនាគារពិភពលោក ក្នុងការបង្កើតទិន្នន័យសាកល គឺមិនមានន័យអ្វីទាំងអស់ នេះគឺដោយសារតែប្រភេទសព្វនិយាមវិទ្យាសាស្រ្តដាច់ខាតនេះ បានដាក់ទិន្នន័យទាំងនេះចូលរួចជាស្រេច។

ក្នុងកម្រិតដែលការធ្វើកោសល្យវិច័យរបស់យើងបានរកឃើញពីលោកទស្សនៈសាសនា ដែលមិនអាចព្យាបាលបាន ការសន្និដ្ឋានចុងក្រោយរបស់យើង អាចរឹតតែទុទ្ទិដ្ឋិនិយមថែមទៀត។ ដើម្បីរក្សាការមើលឃើញបែបសាសនានេះ បរិបទដែលក្នុងន័យនេះ សំដៅលើតថភាពនៃបទពិសោធន៍ មិនគ្រាន់តែត្រូវបំភ្លេចចោលនោះទេ ប៉ុន្តែត្រូវតែមានការសរសេរឡើងវិញឲ្យបានសកម្ម ដើម្បីឲ្យស្របទៅតាមចក្ខុវិស័យនេះ។ នេះជាអ្វីដែលយើងចង់មានន័យថា **បង្កើតតថភាព**។ វារឹតតែគួរឲ្យបារម្ភ ដែលរកឃើញថា ធនាគារពិភពលោកនៅតែ "មិនអាចទទួលកំហុស" (Wade 1996, 34) នៅពេលដែលខ្លួនព្យាយាមលើកកម្ពស់រូបភាពខ្លួនឯងថាជា ធនាគារពុទ្ធិ និងសេដ្ឋកិច្ចពុទ្ធិសាកល និងសូម្បីក្រោយគោលនយោបាយការរៀបចំរចនាសម្ព័ន្ធឡើងវិញនៅក្នុងឆ្នាំ១៩៨០ ដែលបានបរាជ័យម្តងរួចមកហើយ (សូមមើល Weaver 2008)។

នៅចុងបញ្ចប់ អ្វីដែលយើងកំពុងអះអាងធ្វើទឡ្ហីករណ៍ថាជាបញ្ហា គឺការស្វែងរកឫសគល់នៃមូលហេតុ ដោយចោទសួរថា បញ្ហាទាំងនោះកើតចេញពីណាមកតាំងពីដំបូងមក ជាជាងការទទួលស្គាល់បាតុភូតនេះថាជាបញ្ហា។ ចក្ខុវិកលនេះហើយ គឺជាមូលហេតុនៃការអភិវឌ្ឍដែលបរាជ័យ ដូចជាគម្រោងហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍ ហើយដែលអាចត្រូវបានជំនះដោយការចាក់ "*ការអភិវឌ្ឍ*" បន្ថែមទៀត[46]

[45] វាក្យាង្គដែលត្រូវអះអាងដើម្បីផ្តល់ជាមូលដ្ឋាន ឬហេតុផលសម្រាប់ការសន្និដ្ឋានដែលផ្អែកលើទស្សនវិស័យ និងការគិតដោយខ្លួនឯងតែមួយគត់។

[46] ភស្តុតាងជាក់ស្តែង នោះគឺការចាក់បញ្ចូលជាលើកទី២ ដោយធនាគារពិភពលោកក្នុងឆ្នាំ២០១៨ "គម្រោងកែលម្អការអប់រំគុណភាពឧត្តមសិក្សា" ដែលមានទឹកប្រាក់រហូតដល់ ៩២,៥ លានដុល្លារសហរដ្ឋអាមេរិក។

និង *ការជំរុញ* ឲ្យមានការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន មិនមែនជាមួយស្វ័យឆ្លុះបញ្ចាំង រៀនសូត្រ និងរបត់របបនៃការគិត (Paradigm Shift) ទេ។ ក្នុងន័យនេះ មិនមែនមានន័យថាមកពីមិនមានភស្តុតាងសិក្សាជាន់ខ្ពស់ ទទ្បីកម្ម ឬភស្តុតាងច្បាស់លាស់ ដែលអាចប្តូរធនាគារពិភពលោកនោះទេ តែធនាគារពិភពលោកខ្លួនឯងទេ ដែលត្រូវតែដូរអ្វីៗទាំងអស់ដើម្បីធានាឲ្យបានលោកទស្សនៈរបស់ខ្លួន។ ក្នុងនាមជាអ្នកសិក្សាជាន់ខ្ពស់ដែលមានការបារម្ភ យើងត្រូវតែសួរខ្លួនឯងថា៖ តើផ្លូវណាដែលនៅបើកសម្រាប់យើងអាចប្តូរដំណើរការរបស់ស្ថាប័ន "អភិវឌ្ឍន៍" ដ៏មានអំណាចជាងគេលើពិភពលោកមួយនេះបាន? ហើយវានឹងត្រូវការរយៈពេលប៉ុន្មានទៀត? ព្រោះថាធនាគារពិភពលោក នៅពេលនេះ មានបំណងប្តូរឧត្តមសិក្សារបស់ខ្លួន ដែលជាផ្នែកមួយនៃសកម្មភាពកំពុងបន្តបង្កើតសេដ្ឋកិច្ចពុទ្ធិសាកល។

*សេចក្តីថ្លែងការណ៍៖ ពុំមានជម្លោះផលប្រយោជន៍ដែលអាចកើតមានឡើងទេ តាមរយៈរបាយការណ៍របស់អ្នកនិពន្ធ។*

## ឯកសារយោង


Anderson-Levitt, K. 2012. "Complicating the Concept of Culture." Comparative Education 48 (4): 441– 454.

Auld, E., and P. Morris. 2016. "PISA, Policy and Persuasion: Translating Complex Conditions into Education 'Best Practice'." Comparative Education 52 (2): 202–229.

Ayres, D. 2000. Anatomy of a Crisis: Education, Development and the State in Cambodia, 1953–1998. Honolulu: University of Hawaii Press.

Beintema, N. M., and W. Kabir. 2006. "Agricultural Science and Technology Indicators: Bangladesh." ASTI Country Brief, Bangladesh. Accessed January 23, 2016. http://www.asti.cgiar.org/pdf/Bangladesh_CB34.pdf

Brehm, W. 2017. "Historical Memory and Educational Privatization: A Portrait from Cambodia." Ethnography and Education 1–17. doi:10.1080/17457823.2017.1387065.

Brehm, W. 2018, in press. "Global Summitry and Clientelism in Cambodian Higher Education Governance." Higher Education Governance in Asia: Policy Approaches, Innovations and Transitions.

Brehm, W. C., and I. Silova. 2010. "The Ignorant Donor: A Radical Re-imagination of International Aid, Development, and Education." Current Issues in Comparative Education 13 (1): 27–34.

Broad, R. 2006. "Research, Knowledge, and the 'Art of Paradigm Maintenance': The World Bank's Development Economics Vice-Presidency (DEC)." Review of International Political Economy 13 (1): 387–419.

Development Research Forum in Cambodia. 2010. Scoping Study: Research Capacities of Cambodia's Universities. Phnom Penh:

DRF. Dichter, T. W. 2003. Despite Good Intentions: Why Development Assistance to the Third World Has Failed. Boston: University of Massachusetts Press.

Ear, S. 2013. Aid Dependence in Cambodia: How Foreign Assistance Undermines Democracy. New York: Columbia University Press.

Easterly, W. 2006. The White Man's Burden: Why the West's Efforts to Aid the Rest Have Done So Much Ill and So Little Good. London: Oxford University Press.

Edwards Jr., D. B. 2012. "The Approach of the World Bank to Participation in Development

and Educational Governance: Trajectories, Frameworks, and Results." In Education Strategy in the Developing World: Revising the World Bank's Education Policy, edited by C. Collins, and A. Wiseman, 249–273. New York: Emerald.

Edwards Jr., D. B. 2013. "International Processes of Educational Policy Formation: An Analytical Framework and the Case of Plan 2021 in El Salvador." Comparative Education Review 57 (1): 22–53.

Edwards Jr., D. B. 2015. "Rising from the Ashes: How the Global Education Policy of Community-based Management was Born from El Salvador's Civil War." Globalisation, Societies and Education 13 (3): 411–432.

Edwards Jr., D. B. and I. Storen. 2016. "The World Bank and Educational Assistance: History, Theory, Research." In Oxford Research Encyclopaedia of Education, edited by G. Noblit. Oxford: Oxford University Press.

Ferguson, J. 1990. The Anti-Politics Machine: Development, Depoliticization, and Bureaucratic Power in Lesotho. Cambridge: Cambridge University Press.

Haraway, D. 1988. "Situated Knowledges: The Science Question in Feminism and the Privilege of Partial Perspectives." Feminist Studies 14 (3): 575–599.

Hartog, P. 1923. "First Commencement Address." Cited on the University of Dhaka. Accessed January 23, 2016. http://www.du.ac.bd/main_menu/the_university/about.

Heyneman, S. 2003. "The History and Problems in the Making of Education Policy at the World Bank, 1960–2000." International Journal of Educational Development 23 (3): 315–337.

Higher Education Quality Enhancement Project [HEQEP]. 2013. "Joint Interim Impact Assessment Study Report, Ministry of Education [Bangladesh], University Grants Commission of Bangladesh, and HEQEPU of the World Bank, Dhaka."

Jones, P. 2007. World Bank Financing of Education: Lending, Learning, and Development. 2nd ed. Oxon: Routledge.

Kamat, S. 2012. "The Poverty of Theory: The World Bank's System Approach to Education Policy." In The World Bank and Education: Critiques and Alternatives, edited by S. Klees, J. Samoff, and N. Stromquist, 33–48. Rotterdam: Sense.

Kipnis, A. 2011. Governing Educational Desire: Culture, Politics, and Schooling. Chicago: University of Chicago.

Klees, S., and D. B. Edwards Jr. 2014. "Knowledge Production and Technologies of Governance." In World Yearbook of Education 2014: Governing Knowledge: Comparison, Knowledge-based Technologies and Expertise in the Regulation of Education, edited by T. Fenwick, E. Mangez, and J. Ozga, 31–43. New York: Routledge.

Klees, S., J. Samoff, and N. Stromquist, eds. 2012. The World Bank and Education. Rotterdam: Sense Publishers.

Marquis, C. 2000. Innovation Funds for Universities. Washington, DC: World Bank.

McNamara, V. 2007. "Trends in Higher Education Eligibility and Enrollments." Report prepared for the Higher Education Vision 2020, August. Phnom Penh: unpublished.

MoEYS-DHE (Ministry of Education, Youth, and Sport – Department of Higher Education). 2011. Development and Innovation Grants, Implementation Manual. Phnom Penh: MoEYS-DHE.

Mundy, K. 2002. “Retrospect and Prospect: Education in a Reforming World Bank.” International Journal of Education Development 22: 483–508.

Orivel, A. 2008. “Vision, Strategy and Human Resource Development Plan for MoEYS Higher Education.” Report prepared for Cambodia Education Sector Support Project. Phnom Penh: unpublished.

Rappleye, J. 2011a. “Catalyzing Educational Development or Institutionalizing International Influence? Donors, Civil Society, and Policy Formation in Nepal.” Globalisation, Societies and Education 9 (1): 27–49.

Rappleye, J. 2011b. “Different Presumptions about Progress, Divergent Prescriptions for Peace: Connections Between Conflict, ‘Development, and Education in Nepal.” In Education, Conflict, and Development, edited by J. Paulson, 51–92. Oxford: Symposium Books.

Rappleye, J. 2018 Forthcoming. “Origins of the Faith: The Untold Story of Hugh Wood, American Development Assistance in the 1950s, and Nepal’s Modern Education System.” In The Long 1950s: Nepal in the World, edited by O. Pratyoush, P. Ramesh, and M. Liechty. NewYork: Routledge.

Rappleye, J., and H. Komatsu. 2017. “How to Make Lesson Study Work in America and Worldwide: A Japanese Perspective on the Onto-cultural Basis of (Teacher) Education.” Research in Comparative and International Education 12 (4): 398–430.

Rist, G. 1997. The History of Development: From Western Origins to Global Faith. London: Zed Books.

Robertson, S. 2012. “The Strange Non-Death of Neo-Liberal Privatization in the World Bank’s Education Strategy 2020.” In The World Bank and Education, edited by S. Klees, J. Samoff, and N. Stromquist, 189–205. Rotterdam: Sense.

Schütz, A. [1932] 1967. The Phenomenology of the Social World. Chicago: Northwestern University Press.

Sloper, D. 2004. “Technical Assistance Contributed (for Higher Education)”. Report prepared for the World Bank (internal), July. Phnom Penh: unpublished.

Sobe, N., and J. Kowlczyk. 2014. “Exploding the Cube: Revisioning ‘Context’ in the Field of Comparative Education.” Current Issues in Comparative Education 16 (1): 6–12.

Steiner-Khamsi, G. 2004. “Social Network Analysis and the Diffusion of Innovation Revisted: The Maris O’ Rourke Effect in International Education.” Paper presented at the Conference of the German Education Research Association, Zurich, March.

Steiner-Khamsi, G. 2012. “For All by All? The World Bank’s Global Framework for Education.” In The World Bank and Education, edited by S. Klees, J. Samoff, and N. Stromquist, 3–20. Rotterdam: Sense.

Un, L. 2012. “A Comparative Study of Education and Development in Cambodia and Uganda from Their Civil Wars to the Present.” Ph.D thesis submitted to the Faculty of Social and Behavioral Sciences,

Amsterdam Institute for Social Science Research.

Un, L. 2013. “(Re-)Building Education Systems as a Contribution to Growth and Well-being: Comparing Uganda and Cambodia.” In Asian Tigers, African Lions: Comparing the Development Performance of Southeast Asia and Africa, edited by B. Berendensen, T. Dietz, H. K. Nordholt, and R. Van Der Veen, 475–497. Leiden: Brill.

Verger, A. 2012. “Framing and Selling Global Education Policy: the Promotion of Public–Private Partnerships for Education in Low-Income Contexts.” Journal of Education Policy 27 (1): 109–130.

Verger, A., D. B. Edwards, and H. K. Altinyekan. 2014. “Learning from All? The World Bank, Aid Agencies, and the Construction of Hegemony in Education for Development.” Comparative Education 50 (4): 381–399.

Wade, R. 1996. “Japan, the World Bank, and the Art of Paradigm Maintenance: The East Asian Miracle in Political Perspective.” The New Left Review1 (217):1–36. https://newleftreview.org/issues/I217/articles/robert-wade-japan-the-world-bank-and-the-art-of-paradigm-maintenance-the-east-asian-miracle-in-political-perspective.

Weaver, C. 2008. Hypocrisy Trap: The World Bank and the Poverty of Reform. Princeton, NJ: Princeton University Press.

World Bank. 1994. Higher Education: Lessons of Experience. Washington, DC: World Bank.

World Bank. 2002. Constructing Knowledge Societies: New Challenges for Tertiary Education. Washington, DC: World Bank. Accessed January 25, 2015. http://siteresources.worldbank.org/INTAFRREGTOPTEIA/Resources/Constructing_Knowledge_Societies.pdf.

World Bank. 2010. Higher Education Quality and Capacity Improvement Project: Project Appraisal Document [PAD]. Washington, DC: World Bank.

World Bank. 2014. "Bangladesh and Cambodia Collaborate on Higher Education Development," World Bank Blog. Accessed 15 December 2015. http://blogs.worldbank.org/endpovertyinsouthasia/bangladesh-and-cambodia-collaborate-higher-education-development

Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center